ISSN 1560-7615

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី៥ លេខ៤ | តុលា - ធ្នូ ឆ្នាំ២០០១ | តម្លៃ: ១.៥០០៛

# ការវាយតំលៃពីការកាន់កាប់ដីធ្លីនៅក្នុងជនបទកម្ពុជា

**រដ្ឋាភិបាលមានគំនិតផ្តួចផ្តើមថ្មីមួយយ៉ាងធំក្នុងការចេញប័ណ្ណកម្មសិទ្ធិចំពោះដីធ្លីទាំងអស់នៅកម្ពុជា ។ ប៉ុន្តែក្នុងនេះ មានបញ្ហាខាងបច្ចេកទេស និងសង្គម-កិច្ចជាច្រើនដែលត្រូវដោះស្រាយ ។ លោក សូ សុវណ្ណារិទ្ធ, លោក ច័ន្ទ សុផល, និង លោក Sarthi Acharya បានខិតខំពិនិត្យពីបញ្ហាមួយចំនួននៅក្នុងអត្ថបទនេះ ។***

## បញ្ហាចោទ

ពីឆ្នាំ១៨៨៤ ដល់ ១៩៨៩ ដីធ្លីនៅកម្ពុជាត្រូវបានគ្រប់គ្រងដោយច្បាប់ផ្សេងៗ ការធ្វើសមូហភាវូបនីយកម្មច្រើនបែបច្រើនយ៉ាង និងការធ្វើឯកជនភាវូបនីយកម្ម ។ ប៉ុន្តែវិធីជាប្រពៃណីនៃការកាន់កាប់ និងគ្រប់គ្រងដីធ្លីដែលជាការចាប់យកដីតាមគន្លងនង្គ័ល និងដែលក្នុងនេះអ្នកប្រើប្រាស់ដីចាប់យកដីតាមចំនួនដែលខ្លួនត្រូវការដើម្បីចិញ្ចឹមជីវិតឱ្យបានមួយរស់ (ដោយមិនប៉ះពាល់ដល់សិទ្ធិអ្នកដទៃ) នៅមានអនុវត្តនៅឡើយដោយកសិករ និងសហគមន៍ទាំងឡាយនៅក្នុងភូមិ ។ ប៉ុន្តែនៅពេលទំនើបភាវូបនីយកម្ម និងការអភិវឌ្ឍន៍ចូលមកដល់ ក្រុមអ្នកជាប់ពាក់ព័ន្ធនឹងដីធ្លីបានកើនឡើងជាបន្តបន្ទាប់ថែមទៅលើកសិករជីវព្រឹត្តិ (subsistence farmers) គឺមានជាអាទិមជ្ឈដ្ឋានខាងពាណិជ្ជកម្ម និងអាជីវកម្ម, បុគ្គលិកខាងយោធា និងរដ្ឋបាលស៊ីវិល, ស្ថាប័នរដ្ឋ ... ។ នៅក្នុងដំណើរការនេះ ប្រព័ន្ធគ្រប់គ្រងដីតាមបែបប្រពៃណី បានទទួលការប៉ះទង្គិចយ៉ាងខ្លាំង ហើយទំនាស់ផលប្រយោជន៍ដ៏ធ្ងន់ធ្ងរជាច្រើនក៏បានផុសឡើង ។ ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាលបាន កសាងនូវគោលនយោបាយដ៏ធំធេងមួយដើម្បីចុះបញ្ជី និងផ្តល់ប័ណ្ណកម្មសិទ្ធិលើដីធ្លីទាំងអស់ក្នុងប្រទេសកម្ពុជា ។ អត្ថបទនេះធ្វើការវាយតំលៃពីប្រព័ន្ធគ្រប់គ្រងដីធ្លី ដោយផ្អែកលើទិន្នន័យដែលមានស្រាប់ និងការចុះសិក្សាដល់ទីកន្លែង និងរាយការណ៍ពីការប្រើប្រាស់និងការគ្រប់គ្រងដីខ្លះៗដែលបានធ្វើហើយ ។ អត្ថបទនេះគូសបញ្ជាក់ផងដែរពីបញ្ហាមួយចំនួនដែលត្រូវដោះស្រាយនៅពេលដាក់អនុវត្តគោលនយោបាយថ្មី ។



ក្រៅពីកសិករតូចតាច មានបុគ្គលជាច្រើនទៀតបានទាមទារដីធ្លីដែរ ដែលជួនកាលបានបង្កនូវភាពតានតឹងឡើង ។ ក្នុងរូបភាពនេះ កសិករជាច្រើននាក់កំពុងធ្វើសកម្មភាពរួមគ្នានៅទីក្រុងភ្នំពេញ ដើម្បីទាមទារឱ្យមានដំណោះស្រាយចំពោះពួកគេ ។

## ស្ថានភាពជាក់ស្តែងនៃការប្រើប្រាស់ និងការគ្រប់គ្រងដីធ្លី

ប្រទេសកម្ពុជាមានផ្ទៃដីសរុប ១៨១.០៣៥គីឡូម៉ែត្រក្រឡា ក្នុងនេះ ៥៩%គ្របដណ្តប់ដោយព្រៃឈើ, ២១% ជាដីកសិកម្ម, ១៧%ជាវាលស្មៅ និងព្រៃកំពោតផ្សេងៗ, ហើយនៅសល់ពីនេះគឺតំបន់ទីក្រុង ដីលិចទឹក និងផ្ទាំងថ្ម (ក្រាហ្វិក ១) ។ ពីឆ្នាំធ្វើអង្កេត១៩៩២-៩៣ ដល់ ១៩៩៦-១៩៩៧ ដីព្រៃបានថយចុះជាង ១%, ឯដីកសិកម្មបានកើនឡើងប្រហែល ១% ប៉ុន្តែ

---

* លោក សូ សុវណ្ណារិទ្ធិ និង លោក ចន្ទ័ សុផល ជាអ្នកស្រាវជ្រាវ ឯលោក Sarthi Acharya ជានាយកស្រាវជ្រាវនៅ វបសអ ។ អត្ថបទនេះផ្អែកលើរបាយការណ៍ពីរស្តីពី *ការកាន់កាប់ដីនៅកម្ពុជា: ការវិភាគលើទិន្នន័យចុងក្រោយ* (Chan *et al* 2001) និង *ការវាយតំលៃបញ្ហាសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (So *et al* 2001) ។

## មាតិកា

ការវាយតំលៃពីការកាន់កាប់ដីធ្លីនៅក្នុងជនបទកម្ពុជា.............................. ១
ការជួយគ្នាទៅវិញទៅមក: លំនាំអន្តរកម្មក្រៅផ្លូវការ.............................. ៦
ប្រាក់ចំណូលរបស់ពលករខាយរងគ្រោះ .............................................១០
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស .....................................១៤
— ស្ថានភាពក្នុងប្រទេស.....................................១៧
— សន្ទស្សន៍សេដ្ឋកិច្ច ..................................... ២០
សន្ទានុក្រម ............................................................................... ២៣
ពត៌មានថ្មីៗពី វបសអ .......................................................................២៤

ក្រាហ្វិក ១ បំណែងចែកផ្ទៃដីនៅប្រទេសកម្ពុជា
( ផ្ទៃក្រឡាសរុប ១៨១ ០៣៥ គម² )




ប្រភព: Chan *et al* (2001)

ក្នុងនេះគេគិតថា ព្រៃឈើបានបាត់បង់គុណភាពក្នុងកំរិតគួរឱ្យកត់សំគាល់ (RGC 2001) ។ តួលេខខាងលើត្រូវបានប៉ាន់ប្រមាណតាមរូបថតពីយន្តហោះ និង ផ្កាយរណប ពីព្រោះអង្កេតទ្រង់ទ្រាយធំខាងសុរិយោដីមិនទាន់បានធ្វើនៅឡើយទេនៅក្នុងប្រទេសកម្ពុជា ហើយទិន្នន័យក្រោយឆ្នាំ១៩៩៦-៩៧ ក៏មិនអាចរកបានដែរ ។

នៅដើមទសវត្សរ៍១៩៩០ នៅចំពោះមុខការលំបាកធ្ងន់ធ្ងរខាងហិរញ្ញវត្ថុ ដោយសារសង្គ្រាមយូរអង្វែង និងភាពឯកោ រដ្ឋាភិបាលបានផ្តល់ជាសម្បទាននូវតំបន់ធំៗជាច្រើនទៅឱ្យក្រុមហ៊ុនឯកជន ។ តាមតួលេខដែលចុះនៅក្នុងឯកសារផ្សេងៗស្តីពីសម្បទានព្រៃឈើ ព្រៃសម្បទានមានទំហំ ៨លានហិកតា ឬ ៤០%នៃផ្ទៃប្រទេស ។ ប៉ុន្តែការគណនាល្អិតល្អន់ បានបង្ហាញថា ផ្ទៃដីនៅក្រោមរបបសម្បទានព្រៃឈើមិនដែលធំលើសពី ៦,៤លានហិកតាទេ ទោះនៅពាក់កណ្តាលទសវត្សរ៍១៩៩០ ដែលមានសម្បទានច្រើនបំផុតក៏ដោយ ។ មកដល់ឆ្នាំ២០០១ តួលេខបានថយចុះមកត្រឹម ៤,២១លានហិកតា ដោយសារការលុបចោលសម្បទានជាច្រើន ។ ប៉ុន្តែក្នុងប៉ុន្មានឆ្នាំចុងក្រោយ សម្បទានដីកសិកម្មបានកើនឡើង គឺពី ០,៦៦លានហិកតាក្នុងឆ្នាំ១៩៩៩ ដល់ ០,៨៣លានហិកតាក្នុងឆ្នាំ២០០១ ។ ចំពោះសម្បទានឡូត៍នេសាទទឹកសាប ដែលមានទាំងធុនតូច មធ្យម និងធំ គឺមានទំហំសរុបចូលគ្នាទាំងអស់ប្រហែល ១លានហិកតា ។ ក្នុងនេះរដ្ឋាភិបាលមានគោលនយោបាយថ្មីសំដៅកាត់បន្ថយទំហំសម្បទានឡូត៍នេសាទ និងផ្ទេរទៅឱ្យការប្រើប្រាស់ជា សាធារណៈវិញ ដើម្បីបង្កើនធនធានត្រីសំរាប់ប្រជាជនក្រីក្រនៅជនបទ ។ ការផ្តល់សម្បទានមិនមែនសុទ្ធតែជាគោល នយោបាយខុសឆ្គងនោះទេ ។ ប៉ុន្តែបញ្ហាកើតមានឡើងនៅពេលណាដែលកិច្ច សន្យាគ្មានតម្លាភាព, មានការប្រើប្រាស់សិទ្ធិខុសធ្វើឱ្យខូចខាតដល់ប្រព័ន្ធ អេកូឡូស៊ី, មានការកេងប្រវ័ញ្ចលើចំណូលរដ្ឋ, ឬមានការប៉ះពាល់ដល់យុទ្ធសាស្ត្រកិច្ចចិញ្ចឹមជីវិតរបស់ប្រជាជនក្រីក្រ ។ក្នុងរឿងនេះ ប្រទេសជាតិ នឹងបានចំណេញច្រើន បើសិនពតិមានផ្សេងៗស្តីពីសម្បទានត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

ចំពោះការគ្រប់គ្រងដីព្រៃវិញ គឺមាន ៤,២១លានហិកតាជាព្រៃសម្បទាន និង ៣,២០លានហិកតាជាព្រៃបំរុងទុក ។ ដីព្រៃដែលជាកម្មសិទ្ធិរបស់រដ្ឋ និងដែលមិនមែនជាព្រៃសម្បទាន ឬព្រៃបំរុងទុក មានចំនួន ៣,៣២លានហិកតា ក្នុងនេះមួយភាគគឺជាដីបានមកពីការលុបសម្បទានហើយមន្ត្រីមួយចំនួនបានបញ្ជាក់ថា នឹងត្រូវដាក់បញ្ចូលជាព្រៃបំរុងទុកវិញ ។ ឡូត៍នេសាទគ្របដណ្តប់ប្រហែល ១លានហិកតា, ដីដាំដុះរបស់ប្រជាកសិករមាន ២,៧១លានហិកតា, ដីដាំដុះដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់អោយជាសម្បទានកសិកម្មមានប្រហែល ០,៨៣លានហិកតា, ឯដីមានគ្រាប់មីនមានប្រហែល ០,១លានហិកតា ។ ដូច្នេះក្រោយបានដកចេញនូវដីក្នុង តំបន់ទីក្រុង, ដីលិចទឹក និងផ្លូវថ្នល់, ដីដុះកំពោត និងដីគ្មានព្រៃឈើផ្សេងៗ, ផ្ទៃដីមិនប្រើប្រាស់ដែលមិនទាន់ប្រកាសថាទុកប្រើការអ្វីជាក់លាក់ ឬមានកម្មសិទ្ធិជាផ្លូវការក្រៅពីកម្មសិទ្ធិរដ្ឋ មានចំនួនប្រហែល ១,៧៣លានហិកតា ។ ដីនេះអាចយកទៅបែងចែកជាឡូត៍ដើម្បីផ្តល់ឱ្យអ្នកគ្មានដីធ្លី, កសាងមជ្ឈមណ្ឌលឧស្សាហកម្ម/ទីក្រុង, ឬពង្រីកការដាំដុះជាលក្ខណៈពាណិជ្ជកម្ម *ដោយមិនធ្វើឱ្យប៉ះពាល់ដល់ការប្រើប្រាស់ដីដែលមានស្រាប់* ។ ប៉ុន្តែមានចំណុចមួយគួរប្រុងប្រយ័ត្ន: ដីនេះមួយចំណែកប្រហែលស្ថិតក្រោមរបបសម្បទានកសិកម្មដែលខាងយោធាបានផ្តល់ឱ្យគេរួចហើយ ដូច្នេះត្រូវតែដកយក ចេញ បើសិនគេធ្វើការបែងចែកដីដែលនៅសល់ ។

អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (SES) ឆ្នាំ១៩៩៩ បានបង្ហាញថា ដីកសិកម្មមានសរុប ២,៨៨លានប្លង់ គឺត្រូវជា ១,៣៧ប្លង់សំរាប់គ្រួសារនិមួយៗក្នុងប្រទេសកម្ពុជា ហើយដីមួយប្លង់ៗមានទំហំជាមធ្យមតូចទេ ប្រហែល ០,៥០ហិកតា ។ ចំនួនគ្រួសារនៅជនបទដែលគ្មានដីកសិកម្មមានប្រហែល ១២-១៥% ទៅតាមប្រភពទិន្នន័យផ្សេងៗដែលគេយកមកប្រើ (កន្លងមកមានយ៉ាងតិច ៧អង្កេតធំៗដែលទីភ្នាក់ងារនានាបានធ្វើឡើងដើម្បីបំរើគោលដៅខុសៗគ្នា) ដោយសារមានការប្រែប្រួលខុសគ្នាទៅតាមតំបន់ ឬក្រុមមុខសព្វាជាក់លាក់ ។

**_អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (SES) ឆ្នាំ១៩៩៩ បានបង្ហាញថា ដីកសិកម្ម មានសរុប ២,៨៨លានប្លង់ គឺត្រូវជា ១,៣៧ប្លង់សំរាប់គ្រួសារនិមួយៗក្នុង ប្រទេសកម្ពុជា ហើយដីមួយប្លង់ៗមានទំហំជា មធ្យមតូចទេ ប្រហែល ០,៥០ហិកតា ។_**

ទំហំជាមធ្យមនៃដីកសិកម្មកាន់កាប់ក្នុងចំណោមប្រជាជនធ្វើកសិកម្មគឺប្រហែល ១ ទៅ ១,៣ហិកតាក្នុងមួយគ្រួសារ ទៅតាមតំបន់និងតាមក្រុមមុខសញ្ញា ។ ទាំងអ្នករស់នៅក្នុងទីក្រុង និងអ្នកនៅជនបទ គឺជាអ្នកកាន់កាប់ដីកសិកម្ម ។ ទំហំដីតូច គួបផ្សំនឹងការប្រើប្រាស់បច្ចេកវិទ្យាទំនើបកំរិតទាប គឺជាមូលហេតុចំបងនៃភាពក្រីក្រ ក្នុងតំបន់ជនបទ ។

គេបានស្មានថា ក្នុងប្រទេសកម្ពុជា ចំនួនដីឡូត៍លំនៅដ្ឋានមានសរុបទាំងអស់ ២.០២៥.១៦០ប្លង់ ក្នុងនេះមានទាំង ដីឡូត៍ ដែលប្រជាជនកាន់កាប់ជាធម្មតា និងដីឡូត៍ដែលមានទំនាស់ក្នុងកំរិតណាមួយ ។ ដីលំនៅដ្ឋានមានទំហំជាមធ្យម ៨៨៨ម៉ែត្រក្រឡា, នៅក្នុងតំបន់ជនបទ វាមានទំហំ ៩១៥ម៉ែត្រក្រឡា ។ ផ្ទៃដីជា

ច្រើនក្នុងដីលំនៅដ្ឋាន មានដាំដំណាំជាចំការ ដូច្នេះវាបានរួមចំណែកដល់សន្តិសុខស្បៀងក្នុងគ្រួសារ ។ គិតជាសរុបអ្នកគ្មានដីធ្លីសោះមានប្រហែល ៣% ហើយស្ថិតនៅក្នុងតំបន់ទីក្រុងសឹងតែទាំងអស់ ។

គេឃើញមានការយល់ឃើញជាទូទៅថា ភាពក្រីក្រនៅជនបទកើតចេញពីភាពគ្មានដីធ្លី ។ ប៉ុន្តែសំនុំទិន្នន័យលើសេដ្ឋកិច្ចទាំងមូលមិនបានបញ្ជាក់គាំទ្រគំនិតនេះទេ ។ តាមពិតទៅ សព្វថ្ងៃមានការក្រខ្សត់ខ្លាំងណាស់នូវទិន្នន័យច្បាស់លាស់ និងសព្វជ្រុងជ្រោយ ស្តីពីរឿងដីធ្លីនៅកម្ពុជា ។

## ការចុះពិនិត្យដល់កន្លែង

មានការយល់ឃើញជាទូទៅថា នៅពេលបែងចែកដីក្នុងឆ្នាំ១៩៨៩ ការបែងចែកត្រូវបានធ្វើឡើងដោយមានលក្ខណៈស្មើភាពគួរសម ។ កម្មសិទ្ធិត្រូវបានផ្តល់ឱ្យចំពោះដីលំនៅដ្ឋានមិនធំជាង ២000ម៉ែត្រក្រឡា, សិទ្ធិកាន់កាប់ផ្តល់ឱ្យលើដីដាំដុះមិនធំជាង ៥ហិកតា, និងសិទ្ធិប្រើប្រាស់ក្រោមរបប សម្បទានលើដីចំការដែលធំជាង ៥ហិកតា ។ ក្រៅពីនេះកម្មសិទ្ធិត្រូវបានផ្តល់ឱ្យពលរដ្ឋដែលកាន់កាប់ផ្ទះក្នុងក្រុងភ្នំពេញ ។ ប៉ុន្តែប្រហែលមួយទសវត្សរ៍ក្រោយមក គេឃើញមានការមិនសប្បាយចិត្តជាទូទៅពីរឿងគ្មានដីធ្លី និងលក្ខណៈមិនស្មើភាព ហើយបញ្ហានេះត្រូវបានលើកមកពិភាក្សានៅក្នុងអត្ថបទសារពត៌មាន និងសំណេរខាងសិក្សាស្រាវជ្រាវ (William 1999; Kato 1999) ជាច្រើន ។ ប៉ុន្តែក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ គេពិបាកនឹងមើលឃើញពីផលប៉ះពាល់នៃការផ្ទេរកម្មសិទ្ធិដីធ្លី ទៅលើការកាត់បន្ថយភាពក្រីក្រទេ។

> ***ក្នុងតំបន់ជាច្រើន ប័ណ្ណកម្មសិទ្ធិត្រឹមត្រូវមួយ អាចអស់សោហ៊ុយដល់ទៅ ៣០០-៤០០ដុល្លារ ដែល-សុទ្ធតែជាការបង់ប្រាក់ក្រៅផ្លូវការសឹងតែទាំងអស់ ។***

តាមកន្លែងនានាដែលមានសកម្មភាពពាណិជ្ជកម្មច្រើន លំនាំនៃការប្រើប្រាស់ដីបានប្រែប្រួលយ៉ាងខ្លាំង ។ ការប្រែប្រួលនេះគឺជាលទ្ធផលនៃកំណើនតំរូវការពីសំណាក់ក្រុមមនុស្សមានផលប្រយោជន៏ខុសៗគ្នាដូចជា ក្រុមហ៊ុនឯកជន, ស្ថាប័នរដ្ឋ, បុគ្គលមានតួនាទីនិងអំណាចដូចជា មន្ត្រីរាជការស៊ីវិល និងយោធាជាដើម ។ តំរូវការដីធ្លី ក៏បានកើនឡើងផងដែរក្នុងចំណោមប្រជាជននៅជនបទ ដោយសារកំណើនយ៉ាងខ្ពស់នៃចំនួនប្រជាជន និងការហាមឃាត់ផ្សេងៗចំពោះលទ្ធភាពរបស់ប្រជាជនក្នុង ការប្រើប្រាស់ធនធានខាងព្រៃឈើ និងត្រី ។ ការប្រែប្រួលក្នុងលំនាំប្រើប្រាស់ដី បានធ្វើឱ្យប្រែប្រួលដល់ការយល់ឃើញរបស់ប្រជាជន ពីរឿងសិទ្ធិលើដីធ្លី ។ ឥឡូវនេះ មានការ អនុវត្តន៏កម្មសិទ្ធិ និងការគ្រប់គ្រងដីធ្លីពីរបែបខុសគ្នាបានផុសឡើង ដោយ សារមានដីធ្លីកាន់តែច្រើនឡើងដែលធ្លាក់ទៅក្នុងដៃបុគ្គលនិងស្ថាប័នផ្សេងៗ មកពីក្រៅសហគមន៍ និងដែលសំរាប់បំរើគោលដៅផ្សេងទៀតក្រៅពីកសិកម្ម ជីវព្រឹត្តិ ។ នៅក្នុងមូលដ្ឋាន ប្រជាជនក្នុងសហគមន៏កសិករគេទទួលស្គាល់សិទ្ធិប្រើប្រាស់ដីទៅតាមរបៀបរបបជាប្រពៃណី និងទំនៀមទំលាប់ ចំណែកឯអ្នកមកពីក្រៅសហគមន៏គេទទួលស្គាល់កម្មសិទ្ធិទៅតាមច្បាប់ និងនីតិវិធីជាផ្លូវការដែលរដ្ឋបានកំណត់ឡើង ។ ប៉ុន្តែរបៀបរបបពីរបែបខុសគ្នាស្តីពីការកាន់កាប់ និងគ្រប់គ្រងដីធ្លីមិនអាចចុះសំរុងគ្នាទេ ហើយការប្រទាំងប្រទើសជាញឹកញយរវាងរបៀបរបបទាំងពីរនេះ បានផ្តល់ឱកាសឱ្យអ្នកមានឥទ្ធិពលអាចយកប្រៀបលើប្រជាជនទន់ខ្សោយបាន (So *et al* 2001) ។

ទីផ្សារដីធ្លីមានសកម្មភាពខ្លាំងនៅក្នុងតំបន់ជាប់នឹងផ្លូវថ្នល់ ឬនៅជិតទីប្រជុំជន ឬទីផ្សារ ហើយនៅទីនោះមានតំរូវការខ្ពស់នូវឯកសារផ្លូវការបញ្ជាក់កម្មសិទ្ធិដីធ្លី ពីព្រោះវាជួយសំរួលដល់ការផ្ទេរកម្មសិទ្ធិ កំណត់ព្រំដឹងបានច្បាស់លាស់ និងជួយទប់ស្កាត់នូវទំនាស់ជាមួយអ្នកទាមទារផ្សេងៗ ។ ប៉ុន្តែដោយ សារតំលៃដ៏ខ្ពស់នៃប័ណ្ណកម្មសិទ្ធិ (ភាគច្រើនជាការបង់ប្រាក់ក្រៅផ្លូវការ) ការលក់ដូរដីធ្លីជាច្រើនត្រូវបានដោះស្រាយសំរួលនៅកំរិតរដ្ឋបាលមូលដ្ឋាន តាមរយៈការប្រគល់បង្កាន់ដៃទទួលពាក្យសុំកាន់កាប់អចលនវត្ថុ, ឬកិច្ចសន្យាមិនពេញលក្ខណៈច្បាប់រវាងអ្នកទិញនឹងអ្នកលក់, ដែលទាំងអស់នេះមិនអាចយកទៅសំអាងមុខច្បាប់បានទេ ។ មានតែប្រជាជនមានធនធានហិរញ្ញវត្ថុគួរសម និងមានទំនាក់ទំនងខាងនយោបាយទេ ដែលមានលទ្ធភាពនិងសុខចិត្តចំណាយដើម្បីបានប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ ។ នៅតាមតំបន់ដែលមានការដាំដុះជាលក្ខណៈជីវព្រឹត្តិភាគច្រើន និងនៅឆ្ងាយពីផ្លូវថ្នល់ ទីក្រុង ឬទីផ្សារ, ប្រជាជនទាំងឡាយ ឬមួយត្រូវពឹងផ្អែកលើបង្កាន់ដៃ ឬមួយពឹងផ្អែកលើស្ថាប័នខាងសង្គមកិច្ចនៅក្នុងសហគមន៏ ដើម្បីបញ្ជាក់ពីសិទ្ធិរបស់ខ្លួនក្នុងការប្រើប្រាស់ដី ។ ប៉ុន្តែទោះនៅតំបន់នេះក៏ដោយ ក៏ការចូលមកដល់នៃទំនើបភាវូបនីយកម្ម បានបង្កឱ្យមានកំណើនតំរូវការនូវឯកសារជាលាយលក្ខណ៏អក្សរខ្លះៗ ពីព្រោះប្រជាជនចង់ធានាថា ការផ្ទេរមតិក ឬការផ្ទេរកម្មសិទ្ធិ អាចធ្វើទៅបានដោយស្រួលនិងគ្មានការរអាក់រអួល ។

មន្ត្រីរដ្ឋាភិបាល និងមន្ត្រីជ្រើសតាំងតាមការបោះឆ្នោតច្រើនជាន់ច្រើនថ្នាក់មានតួនាទីក្នុងការគ្រប់គ្រងដីធ្លី ទៅតាមបែបបទមួយដែលមានលក្ខណៈប្រមូលផ្តុំជាខ្លាំង ។ សំណើសុំប័ណ្ណកម្មសិទ្ធិត្រូវឆ្លងកាត់យ៉ាងតិចប្រាំពីរទៅប្រាំបីការិយាល័យ ដែលមានតាំងពីនៅភូមិ, ឃុំ, ស្រុក, ខេត្ត, និងនៅ រាជធានី ។ ការអង្កេត និងការវាស់វែងស៊ីពេលច្រើនណាស់ហើយដំណើរការរិតតែអូសបន្លាយដោយសារកង្វះធនធានមនុស្ស និងសំភារៈ ។ ភាគច្រើននៃប្រជាជននៅជនបទទាំងកសិករ និងមិនមែនកសិករ មិនសូវចុះស្មាមនឹងប្រព័ន្ធរដ្ឋបាលទេ ។ ពួកគេព្យាយាមជៀសវាងពីប្រព័ន្ធនេះដោយបែរទៅប្រើប្រាស់របៀបរបបជាប្រពៃណី និងទំនៀមទំលាប់ ឬបើទាល់ណាស់ទៅទាក់ទងតែត្រឹមស្ថាប័នមូលដ្ឋានប៉ុណ្ណោះ ។ ប៉ុន្តែមានអ្នកខ្លះបានជៀសវាងប្រព័ន្ធផ្លូវការ ដោយសារចង់គេចវេសពីការបង់ពន្ធដារផងដែរ ។

ប្រព័ន្ធគ្រប់គ្រងដីធ្លីមិនគ្រាន់តែ មានពីររបៀបរបបប៉ុណ្ណោះទេ ប៉ុន្តែតួអង្គនានាក្នុងជួររដ្ឋាភិបាលខ្លួនឯង ជាពិសេសនៅកំរិតមូលដ្ឋាន បានចូលរួមធ្វើឱ្យវាមាននិរន្តរភាព ។ អ្នកជាប់ពាក់ព័ន្ធផ្សេងគ្នាមានការយល់ដឹងខុសគ្នាពីច្បាប់និងបទប្បញ្ញត្តិខាងដីធ្លី ហើយពួកអ្នកការពារច្បាប់ខ្លួនឯង (តុលាការ និងយន្តការដោះស្រាយវិវាទ) ក៏ពុំមានការយល់ដឹងច្បាស់លាស់ និងស្របគ្នាពី

ច្បាប់ដីធ្លីដែរ ។ ការទទួលស្គាល់ជាលក្ខណៈជាក់ស្តែងចំពោះបែបបទអនុវត្តន៍ខុសៗគ្នាក្នុងការគ្រប់គ្រងដីធ្លី បានធ្វើឱ្យច្បាប់ពិតប្រាកដអនុវត្តមិនបានសមស្រប ។ វិធានជាច្រើនដែលមានន័យមិនច្បាស់លាស់ និងអនុវត្តន៍បានច្រើនបែបច្រើនយ៉ាង (ក្នុងការលក់ដូរដីធ្លី) បានរួមចំណែកធ្វើឱ្យអំពើពុករលួយកើនឡើង ហើយប្រាក់បៀវត្សរ៍មិនប្រាកដនិយមរបស់មន្ត្រីរាជការបានញ៉ាំងឱ្យបញ្ហានេះរិតតែធ្ងន់ធ្ងរថែមទៀត ។ ក្នុងតំបន់ជាច្រើន ប័ណ្ណកម្មសិទ្ធិត្រឹមត្រូវមួយអាចអស់សោហ៊ុយដល់ទៅ ៣០០-៤០០ដុល្លារ ដែលសុទ្ធតែជាការបង់ប្រាក់ក្រៅផ្លូវការសឹងតែទាំងអស់ ។ ដូចយើងអាចស្មានបានថា ប្រជាជនក្រីក្រ កំរ ឬមិនដែលបានប័ណ្ណត្រឹមត្រូវទេ ពីព្រោះពួកគេពុំមានការគាំទ្រខាងផ្លូវច្បាប់ ហើយក៏ពុំមានធនធានដើម្បីដោះស្រាយរំលងច្បាប់ដែរ ។ ក្នុងនេះ ស្ត្រីងាយទទួលរងគ្រោះខ្លាំងណាស់ ពីព្រោះមិនសូវមានធនធានសំរាប់យកមកប្រើប្រាស់ការពារសិទ្ធិរបស់ខ្លួន ។

ចំនួន និងប្រភេទនៃទំនាស់ដីធ្លីកំពុងកើនឡើង ពីព្រោះអ្នកមានផលប្រយោជន៍ផ្សេងៗគ្នាកំពុងប្រជែងដណ្តើមដី ។ សព្វថ្ងៃនេះ ទំនាស់ដីធ្លីកើតមានកាន់តែច្រើនឡើងរវាងប្រជាជនអ្នកភូមិទល់នឹងអ្នកមកពីក្រៅសហគមន៍ (ក្រុមហ៊ុនឯកជន, ស្ថាប័នរដ្ឋ ...) ហើយវាទាមទារនូវស្ថាប័នសំរុះសំរួល ឬកាត់ក្តី កាន់តែច្រើនឡើងដែរ ។ ការប្រឹងប្រែងជាថ្មីក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិ វានឹងបង្កើនថែមទៀតនូវតំរូវការដោះស្រាយវិវាទ ។ តាមមើលទៅកំណើននេះ វាធំលើសលុបពេកចំពោះយន្តការរដ្ឋ ដែលសព្វថ្ងៃកំពុងវត់មិនទាន់កំណើនសំណុំរឿងពាក្យបណ្តឹងស្រាប់ទៅហើយ ដោយសារកង្វះខាតទាំងខាងថវិកា និងធនធានមនុស្ស ។ ចំពោះធនធានមនុស្ស គឺមានតំរូវការយ៉ាងធំនូវការបណ្តុះបណ្តាលខាងច្បាប់ និងនីតិវិធី ។ មួយចំណែកទៀត គ្មានអ្វីចំលែកទេដែលមហាជនជន ជាពិសេសប្រជាជនក្នុងសហគមន៍កសិករនៅជនបទ គេច្រើនយល់ឃើញថា ប្រព័ន្ធដោះស្រាយវិវាទជាផ្លូវការ ពុំមានលក្ខណៈយុត្តិធម៌ល្អទេ ពីព្រោះវាលំអៀងទៅខាងពួកជនដែលមានធនធាន និងអំណាច ព្រមទាំងរាំងស្ទះដល់ការចូលរួមពីសំណាក់ប្រជាជនទន់ខ្សោយនៅក្នុងសង្គមទៀតផង ។ ជំនឿរបស់ប្រជាជនចំពោះប្រព័ន្ធផ្លូវការ ក៏ចោទបញ្ហាដែរដោយសារគេមានពត៌មាន និងការយល់ដឹងមិនគ្រប់គ្រាន់ពីច្បាប់ និងនីតិវិធីដែលគ្រប់គ្រងដីធ្លី ។ វិបត្តិនៃទំនុកចិត្តចំពោះដំណើរការដោះស្រាយវិវាទដូចដែលកំពុងកើតមានសព្វថ្ងៃ គឺជាបញ្ហាដ៏ធំមួយចំពោះអភិបាលកិច្ច ។

## ការព្រួយបារម្ភធំៗនៅតំបន់ជនបទ

គេឃើញមានការព្រួយបារម្ភជាទូទៅលើបញ្ហាធំៗបួនៈ ១-កំណើនវិសមភាពខាងដីធ្លី ២-ភាពគ្មានដីធ្លី ៣-កង្វះសុវត្ថិភាពក្នុងការកាប់កាប់ដី និង ៤-កំណើនទំនាស់ទាក់ទិននឹងដីធ្លី ។

*វិសមភាពខាងដីធ្លីៈ* អង្កេត SES ឆ្នាំ១៩៩៩ បានបង្ហាញ Gini coefficient នៃវិសមភាព ទំហំ ០,៥៧ សំរាប់ដីកសិកម្ម។ អង្កេតឆ្នាំ១៩៩៥-៩៦ របស់គណៈកម្មការទន្លេមេគង្គ បានបង្ហាញ Gini coefficient នៃវិសមភាពដីធ្លីទំហំ ០,៦១ រីឯអង្កេតធ្វើដោយអង្គការ WFP និង UNICEF ក្នុងឆ្នាំ១៩៩៨ និង ២០០០ បានបង្ហាញ Gini coefficient មានទំហំមិនដល់ ០,៥០ ទេ។ មូលហេតុមួយនៃវិសមភាពក្នុងការកាន់កាប់ដីធ្លីគឺ សំពាធខាងប្រជាសាស្ត្រៈ ពីឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩៨ ប្រជាជនកើនឡើងប្រហែល ៣០% (NIS 1999; Biddulph 2000) ប៉ុន្តែផ្ទៃដីដាំដុះបានកើនឡើងយឺតជាង ហើយចំនួនមុខរបរក៏នៅមានតិចមុខដែរ ។ ដោយហេតុថា កំណើនប្រជាជន, អត្រាមរណភាព, និងអត្រាផ្សេងទៀត, ប្រែប្រួលខុសគ្នាពីគ្រួសារមួយទៅគ្រួសារមួយ, គ្រួសារមួយចំនួនបានពុះចែកដី ឬលក់ដី, ឯខ្លះទៀតបានទិញដីថែម, ដូច្នេះហើយវិសមភាពក៏កើតមានឡើង ។ ហេតុផលទីពីរ ជាប់ទាក់ទងដល់ប្រជាជនជាច្រើនដែលមិនទាន់បានតាំងលំនៅដ្ឋាននៅឡើយ ។ ប្រជាជនជាច្រើនដែលធ្វើមាតុភូមិនិវត្តន៍ក្នុងឆ្នាំ១៩៩២-៩៣ មិនបានទទួលដីធ្លីទេ ។ ហេតុផលមួយគឺក្នុងតំបន់ដែលគេចង់រស់នៅ ដីធ្លីមានម្ចាស់អស់ទៅហើយ ឬមានគ្រាប់មីន ឬមានទំនាស់ ។ ប្រជាជនទាំងនេះត្រូវស្នាក់លើដីរបស់សាច់ញាតិ, ធ្វើការ ពុះចែកដីមួយចំនួន, ហើយវិសមភាពក៏កើតមានឡើង ។ ទីបី ប្រព័ន្ធឥណទានជាផ្លូវការនៅទន់ខ្សោយនៅឡើយ ដូច្នេះកសិករត្រូវពឹងផ្អែកលើឥណទានក្រៅផ្លូវការមានការប្រាក់ខ្ពស់ ។ ក្នុងករណីមានការខូចខាតផលដំណាំ កសិករជាច្រើនដែលមិនសូវមានធនធាន ត្រូវលក់ដីមួយចំណែក ឬលក់ទាំងអស់ទៅឱ្យអ្នកធូរធារដើម្បីសងបំណុល ។ ដោយមូលហេតុនេះ ដីកាន់កាប់របស់អ្នកខ្លះបានរីកធំឡើង ឯដីអ្នកខ្លះទៀតក៏បានរួមតូច ។ ទីបួន គេបានកត់សំគាល់ថា ប្រព័ន្ធសុខាភិបាលសាធារណៈទន់ខ្សោយ បានបង្ខំឱ្យប្រជាជនប្រើប្រាស់សេវាព្យាបាលឯកជនដែលមានតំលៃខ្ពស់នៅពេលខ្លួនមានជំងឺ ។ ជាច្រើននាក់បានលក់ដីមួយចំណែកឬទាំងអស់របស់ខ្លួនដើម្បីបង់ថ្លៃព្យាបាល ។ ទីប្រាំ ការទិញដីសំរាប់ទុកលក់យកចំណេញរបស់ជនមួយ ចំនួនតូចបានធ្វើឱ្យវិសមភាពកើនឡើង ។ ផលចំណេញ នៃការលូតលាស់នៅក្នុងទសវត្សរ៍ចុងក្រោយនេះ ភាគច្រើនបំផុតវាបានទៅដល់អ្នកនៅភ្នំពេញ និងតំបន់ទីក្រុងធំៗផ្សេងទៀត (Curtis 1998) ។ ចំពោះពួកអ្នកមាន ក្រោយពីអស់លទ្ធភាពធ្វើវិនិយោគក្នុងវិស័យសណ្ឋាគារ និងភោជនីយដ្ឋានហើយ គេក៏បែរទៅវិនិយោគខាងដីធ្លីវិញ ពីព្រោះមិនសូវមានច្រកផ្សេងទៀត ។ ហើយលទ្ធផលមួយដែលគេមិនចង់បានគឺ ការផ្ទេរដីធ្លីពីប្រជាជននៅជនបទ (ភាគច្រើនជាអ្នកក្រីក្រ) ទៅពួកអ្នកមាននៅក្នុងទីក្រុង, ក៏បានផុសឡើង ។

*ភាពគ្មានដីធ្លីៈ* តួលេខស្តីពីភាពគ្មានដីធ្លី បានលើកពីខាងដើមរួចហើយ ។ ភាពគ្មានដីធ្លីកើតមានចំពោះគ្រួសារមានស្ត្រីជាមេគ្រួសារច្រើនជាងចំពោះគ្រួសារមានបុរសជាមេគ្រួសារ ។ មូលហេតុនៃភាពគ្មានដីធ្លី វាប្រហាក់ប្រហែលគ្នានឹងមូលហេតុនៃវិសមភាពក្នុងការបែងចែកដីធ្លីដែរៈ សំពាធប្រជាសាស្ត្រកើនខ្ពស់, របរចិញ្ចឹមជីវិតពុំមានច្រើនមុខ, ប្រជាជនមិនទាន់បានតាំងលំនៅជាប់លាប់ (ក្នុងនេះមានប្រជាជនមាតុភូមិនិវត្តន៍ផង), ឥណទានមានការប្រាក់ខ្ពស់, សេវាសុខាភិបាលសាធារណៈគុណភាពអន់ដែលបង្ខំឱ្យប្រជាជនទៅប្រើសេវាឯកជនមានតំលៃថ្លៃ, និងការទិញដីទុកលក់យកចំណេញដោយជនមួយចំនួនតូច ។ ភាពគ្មានដីធ្លីមានមូលហេតុផ្សេងខ្លះទៀតដូចជា កង្វះពលកម្ម ពិសេសក្នុងគ្រួសារមានស្ត្រីជាមេគ្រួសារ, ដំណើការធ្វើសមាហរណកម្មមិនទាន់ចប់សព្វគ្រប់ក្នុងតំបន់មួយចំនួន, និងសកម្មភាពដោះមីនធ្វើមិនបានលឿនជាដើម ។ ដោយហេតុថា ដីកាន់កាប់មានទំហំតូច ដូច្នេះការលក់ដីវាធ្វើឱ្យអស់ដីរលីងក្នុងករណីជាច្រើន ។ ម្ចាស់ដីតូចៗ គឺជា

ប្រជាជនដែលងាយនឹងក្លាយជាអ្នកគ្មានដីធ្លី ។

*កង្វះសុវត្ថិភាពក្នុងការកាប់កាប់ដីៈ* តាមពត៌មានពីនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្នុងចំណោមអ្នកដាក់ពាក្យសុំ ប្រហែល ៤,៥លាននាក់ មានមិនលើសពី ១៤%ទេដែលបានទទួលប័ណ្ណបញ្ជាក់កម្មសិទ្ធិដីជាផ្លូវការ ។ រឿងសំខាន់មួយទៀតគឺ ក្រោយមានបង្កាន់ដៃបញ្ជាក់ការទទួលពាក្យសុំកាន់កាប់អចលនវត្ថុហើយ មានការលក់ដូរ ឬពុះចែកដី ដែលមិនសុទ្ធតែត្រូវបាន រាយការណ៍ជូនដល់អាជ្ញាធរមានសមត្ថកិច្ចនោះទេ ។ ការផ្ទេរដីកសិកម្មដោយ គ្មានរាយការណ៍ កើតមានក្នុងតំបន់ជនបទច្រើនជាងក្នុងតំបន់ទីក្រុង ។ ក្នុង ចំណោមកសិករ ក៏មានការភ័ន្តច្រឡំមួយទៀតដែរៈ កសិករភាគច្រើនហាក់ដូចមិនបានដឹងទេថា អ្វីទៅជាប័ណ្ណបញ្ជាក់កម្មសិទ្ធិដីធ្លីត្រឹមត្រូវ ។ នៅក្នុងប្រវត្តិសាស្ត្រ ប្រព័ន្ធកាន់កាប់ដីធ្លីនៅកម្ពុជាគឺជាប្រភេទ "ទូលាយ" ដែលក្នុងនេះពុំមានការផ្តល់កម្មសិទ្ធិដីជាក់លាក់ឱ្យប្រជាជនទេ ។ ក្នុងពេលថ្មីៗនៅពេលប្រព័ន្ធសេដ្ឋកិច្ចទីផ្សារចូលមកដល់ កេរ្តិ៍ដំណែលនេះក៏បង្កើតនូវបញ្ហាអសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ។ នៅពេលមានការធ្វើពាណិជ្ជកម្មកាន់តែខ្លាំងឡើង អ្នកដែលធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធទីផ្សារមិនទាន់បានស៊ីបល្អ ក៏មានការបារម្ភកាន់ច្រើនឡើងពីរឿងអសុវត្ថិភាព ។

*ទំនាស់ដីធ្លីៈ* មានការយល់ឃើញជាទូទៅថា ទំនាស់រឿងព្រំប្រទល់ដីដែលដោះស្រាយមិនទាន់ដាច់ស្រេច និងការតវ៉ាទាមទារពីរឿងកម្មសិទ្ធិដី កំពុងកើនឡើង ។ ទំនាស់ដីធ្លី មិនមែនមានតែនៅក្នុងប្រទេសកម្ពុជាទេ, វាកើតមាននៅគ្រប់ទីកន្លែងក្នុងពិភពលោក ។ នៅកម្ពុជាបញ្ហានេះកើតឡើងដោយសារៈ ១-មូលដ្ឋានដោះស្រាយនៅទន់ខ្សោយ ២-ប្រព័ន្ធផ្លូវច្បាប់មិនច្បាស់លាស់ និងមានតំលៃខ្ពស់ និង ៣-កង្វះយន្តការដោះស្រាយទំនាស់ដែលមិនប្រកាន់បក្សពួក និងស័ក្តិសិទ្ធិ ។ ដោយហេតុថា អ្នកមានធនធានគេ អាចពត់បត់បែនប្រព័ន្ធផ្លូវច្បាប់បាន ដូច្នេះអ្នកក្រក៏ត្រូវបាត់បង់ដី ហើយ សភាពការណ៍នេះបានធ្វើឱ្យស្ថានការណ៍នយោបាយពុំមានស្ថិរភាពល្អទេ ។

## ផ្លូវដើរនៅខាងមុខ

សំរាប់ការងារគ្រប់គ្រងដីធ្លី មានការជូនមតិមួយចំនួនដូចតទៅៈ

១- វាមានសារៈសំខាន់ណាស់ដែលអាជ្ញាធរមានសមត្ថកិច្ចត្រូវក្តាប់ឱ្យបានច្បាស់លាស់ពីសភាពការណ៍ដ៏ស្មុគស្មាញទាក់ទិននឹងដីធ្លី និងត្រូវត្រៀមខ្លួនដោះស្រាយបញ្ហាមិនប្រក្រតីផ្សេងៗដែលមានស្រាប់ ឬដែលអាចកើតមានជាយថាហេតុ មុននឹងចាប់ផ្តើមដំណើរការផ្តល់ប័ណ្ណកម្ម សិទ្ធិ ។ ក្នុងរឿងនេះ ការពង្រឹងការគ្រប់ គ្រងដីធ្លី តាមបែបវិមជ្ឈការ អាចជាចំណុចផ្តោតសំខាន់ជាងគេ ។ ថ្នាក់ស្រុកគួរជាកន្លែងធ្វើបញ្ចប់នូវបែបបទចុះបញ្ជី ពីព្រោះនៅជិតភូមិ ។ ការពង្រឹងសមត្ថភាពអាជ្ញាធរមូលដ្ឋាន និងការបង្កើតគណៈកម្មាធិការកំរិតភូមិ និងឃុំ (អាចមាន NGO ចូលរួមផង) គឺជាសមាសធាតុមួយយ៉ាងសំខាន់នៃការធ្វើ វិមជ្ឈការ ។

២- វាមានសារៈសំខាន់ណាស់ដែលគ្រប់ករណីនៃទំនាស់ដីធ្លី ត្រូវតែដោះស្រាយតាមវិធីមួយដែលស្របតាមស្មារតី និងខ្លឹមសារនៃច្បាប់ស្តីពីកម្មសិទ្ធិដីធ្លី ។ ការដោះស្រាយវិវាទអាចធ្វើតាមប្រព័ន្ធវិមជ្ឈការដើម្បីឱ្យវាស៊ីគ្នាទៅនឹងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ ។ ក្នុងនេះត្រូវប្រឹងប្រែងជាអតិបរមាដោះស្រាយនូវករណីបណ្តឹងនានា ដោយប្រើប្រាស់យន្តការក្នុងមូលដ្ឋានឬសហគមន៍ ក្នុងនេះមានទាំងករណីបណ្តឹងដែល ជាប់ទាក់ទងដល់អាជ្ញាធរ និងក្រុមហ៊ុនផ្សេងៗផង ។ គណៈកម្មាធិការ ដោះស្រាយបាតុភាពដីធ្លី ដែលមានសមាជិកជាជនស៊ីវិលទាំងអស់ និងមានជំហរមិនប្រកាន់បក្សពួក នឹងមានលទ្ធភាពអាចដោះស្រាយទំនាស់បានដោយស័ក្តិសិទ្ធិ ។ ការផ្តល់ច្រើនថែមទៀតនូវថវិកានិងធនធានមនុស្សដល់កំរិតមូលដ្ឋាន នឹងជួយសំរួលដល់ដំណើរការនេះ ។

៣- ក្នុងទសវត្សរ៍ទើបកន្លងផុតទៅ គេបានរៀបចំការតាំងទីលំនៅថ្មីឱ្យដល់ប្រជាជនមាតុភូមិនិវត្តន៍ច្រើននាក់ណាស់ ។ សំរាប់ប្រជាជនភៀសសឹក និងអ្នកគ្មានដីធ្លី ក៏គួរប្រឹងប្រែងធ្វើដូច្នេះដែរ ដើម្បីពង្រឹងសន្តិភាព ស្ថិរ ភាព និងកាត់បន្ថយភាពក្រីក្រ ។ នៅក្នុងតំបន់ជនបទ ដីធ្លីមានគ្រប់គ្រាន់សំរាប់ដោះស្រាយតំរូវការរបស់អ្នកគ្មានដីធ្លី ។ គោលនយោបាយស្តីពីការស្តារ និងតាំងទីលំនៅជាថ្មីមួយដែលមានលក្ខណៈច្នៃប្រឌិតថ្មី និងដែលថ្លឹងថ្លែងបានល្អ រវាងតំរូវការនិងផលប្រយោជន៍របស់ប្រជាជន ព្រមទាំងគោលដៅនៃការអភិវឌ្ឍន៍រយៈពេលវែងផង នឹងអាចជួយដោះស្រាយបញ្ហាបាន ។

៤- តំរូវការទទួលស្គាល់នូវសិទ្ធិរបស់ប្រជាជនដើម និងសិទ្ធិនារី មានសារៈសំខាន់ខ្លាំងណាស់ ។ ត្រូវមានវិធីសាស្ត្រសំរាប់ការពារលទ្ធភាពរបស់ប្រជាជនដើមក្នុងការប្រើប្រាស់ និងគ្រប់គ្រងដីរួម ព្រមទាំងដោះស្រាយផងដែរនូវគោលដៅអភិវឌ្ឍន៍ជាទូទៅនានា ដើម្បីលើកកំពស់កំរិតជីវភាពក្នុងតំបន់ទាំងនោះ ។ ដូចគ្នាដែរ ត្រូវមានបទប្បញ្ញត្តិច្បាប់សំរាប់ការពារសិទ្ធិរបស់ស្ត្រីទៅលើដីធ្លី ក្នុងករណីមានការលែងលះ ឬបន្ត មតិក ។ លើសពីនេះទៀត ត្រូវមានច្បាប់ធានានូវសិទ្ធិស្ត្រី ដើម្បីបាន ទទួលនូវដំណោះស្រាយទំនាស់មួយដែលមានយុត្តិធម៌ និងមិនប្រកាន់បក្សពួក ។ មួយចំណែកទៀត ត្រូវមានកិច្ចសហការយ៉ាងសកម្មរវាង រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីផ្តល់ជូនស្ត្រី និងប្រជាជនដើមនូវពត៌មានស្តីពីសិទ្ធិរបស់ពួកគេនៅក្នុងក្របខ័ណ្ឌនៃច្បាប់ដីធ្លីនិងប្រព័ន្ធសំរាប់ទ្រទ្រង់ច្បាប់នេះ ។

៥- ការពង្រឹងថវិកាចំណាយប្រតិបត្តិការសំរាប់រដ្ឋបាលគ្រប់កំរិតដែលជាប់ទាក់ទងដល់ការគ្រប់គ្រងដីធ្លី តាមរយៈការផ្ទេរថវិកាផ្ទៃក្នុងរដ្ឋាភិបាល និងការផ្តល់ថវិកាបន្ថែមបានពីចំណូលប្រមូលពីការយកកំរៃលើអ្នក ប្រើប្រាស់ នឹងអាចជួយយ៉ាងច្រើនដល់អភិបាលកិច្ចល្អខាងដីធ្លី ។ ចំពោះពន្ធដារវិញ បើសិនវាមានលក្ខណៈជឿនលឿន វានឹងធ្ងន់ស្រាលស្មើៗគ្នាទៅតាមលទ្ធភាពរបស់ប្រជាជន ។

# ការជួយគ្នាទៅវិញទៅមក៖ លំនាំអន្តរកម្មក្រៅផ្លូវការខាងសង្គមកិច្ចក្នុងភូមិកម្ពុជាមួយនៅជិតឧទ្យានអង្គរ

**លោក គីម សេតារា ជាអ្នកស្រាវជ្រាវនៅ វបសអ ពិនិត្យមើលលើប្រព័ន្ធសង្គមនៃការជួយគ្នាទៅវិញទៅមកនៅតាមភូមិដ្ឋានខ្មែរ ។ ទង្វើនៃការជួយគ្នានេះនៅតែជាយន្តការគន្លឹះ ក្នុងការថែរក្សាចំណងសាមគ្គីភាពនៅក្នុងសហគមន៍នៅកម្ពុជានាពេលបច្ចុប្បន្ន ប៉ុន្តែទំរង់ការនេះបានចាប់ផ្តើមផ្លាស់ប្តូរទៅតាមលំនាំនៃសេដ្ឋកិច្ចប្រើប្រាក់កាសនៅក្នុងឆ្នាំ១៩៩០ ។***

## និដ្ឋភាពរួម

គេឃើញមានការជជែកវែកញែកជាច្រើនស្តីពីចរិតនៃការជួយគ្នាទៅវិញទៅមកនៅក្នុងប្រទេសកម្ពុជា ។ ទីមួយ គេឃើញមានអ្នកស្រាវជ្រាវមួយក្រុមបានជជែកវែកញែកថា នៅក្រោយរយៈពេលខ្មែរក្រហមកាន់កាប់ និងសង្គ្រាមស៊ីវិល ហេដ្ឋារចនាសម្ព័ន្ធសង្គមទាំងមូលត្រូវបានបំផ្លាញចោលអស់ (Ovesen et al 1996) ។ គំនិតប្រហែលគ្នាមួយទៀតរបស់លោកស្រី Frings បានលើកថា ដោយសារបទពិសោធន៍របស់ខ្លួនក្នុងសង្គមពីមុនៗ, ប្រជាជនកម្ពុជាមិនយកចិត្តទុកដាក់ពីសុខទុក្ខរបស់ប្រជាជនផងគ្នាទេ ហើយទោះបីជាប់សាច់ញាតិនឹងគ្នាក៏ដោយ ក៏គេមិនជួយដោយទទេៗនោះដែរ ហើយក៏មិនគិតទេថា ខ្លួនគេមានកាតព្វកិច្ចខាងផ្លូវចិត្តត្រូវជួយគ្នា (Frings 1994) ។ ការស្រាវជ្រាវខាងជាតិពន្ធវិទ្យានៅក្នុងរយៈពេលមុនសង្គ្រាម (Ebihara 1968 and Delvert 1961) ) បានរកឃើញថា ចំណងសាមគ្គីក្នុងសង្គមក្នុងភូមិកម្ពុជានាពេលនោះមានតែក្នុងរូបភាពមិនផ្លូវការ ។

***តាមលទ្ធផលនៃការស្រាវជ្រាវ ខ្ញុំមានជំនឿថា ក្រោយសង្គ្រាមស៊ីវិល ២៥ឆ្នាំនេះមក ចំណងសាមគ្គីក្នុងសង្គមនៅក្នុងភូមិ បានវិលត្រឡប់មកតាមលំនាំមុនពេលមានសង្គ្រាមវិញហើយ ។***

ឯកសារផ្សេងៗទៀតស្តីពីប្រទេសកម្ពុជា ក្នុងទសវត្សរ៍១៩៩០ បានឆ្លុះបញ្ចាំងថា បែបបទផ្សេងៗនៃការជួយគ្នាទៅវិញទៅមកបានផុសឡើងវិញក្រោយពេលរបបខ្មែរក្រហមដួលរលំទៅ ហើយវាមានលំនាំដូចគ្នានឹងកាលពីពេលមុនសង្គ្រាមដែរ (see Collins 1998; Ledgerwood 1998; Vijghen 1991 ។

នៅក្នុងទសវត្សរ៍ក្រោយពេលរបបខ្មែរក្រហមដួលរលំទៅ លោក John Vijghen បានសិក្សាស្រាវជ្រាវក្នុងតំបន់វាលទំនាបភាគកណ្តាលប្រទេសក្នុងខេត្តកំពង់ឆ្នាំង ស្តីពីការអភិវឌ្ឍន៍សហគមន៍ និងបញ្ហាខ្ចីប្រាក់ ។ គាត់រកឃើញថា គ្រួសារមានៗបានឱ្យប្រាក់ខ្ចីដល់សាច់ញាតិរបស់ខ្លួន និងអ្នកឯទៀតសំរាប់ព្រឹត្តិការណ៍សំខាន់ៗក្នុងសង្គម ដោយផ្អែកលើ "កិត្តិយស" ។ តំរូវការបង់ការប្រាក់ប្រែប្រួលទៅតាមកំរិតចំណងទាក់ទងជាបងប្អូនឬមិត្តភ័ក្តិ ហើយការប្រាក់មានកំរិតទាប ឬគ្មានសោះ ។ ប្រជាជនរង់ចាំការកាត់សងវិញជាស្រូវនៅពេលច្រូតកាត់ (Vijghen 1991: 1920) ។ គួរកត់សំគាល់ថា ពួកគេខ្ចីប្រាក់តែក្នុងស្ថានភាពចាំបាច់បំផុតដូចជា មង្គលការ, ការព្យាបាលជំងឺ, បុណ្យសព, ទិញគោ...។ ការដោះដូរបែបនេះទាមទារនូវទំនុកចិត្ត និងចំណងសាមគ្គីភាព ក្នុងក្រុមកំរិតខ្ពស់ ។

ឯកសារក្រោយមកទៀតរបស់លោក William Collins ស្តីពីតួនាទីរបស់តួអង្គផ្សេងៗក្នុងសង្គមស៊ីវិលនៅខាងពាយព្យប្រទេស បានរកឃើញថា មាន ការដោះដូររវាងក្រុមផ្សេងៗដូចជាការ "ជួយគ្នាទៅវិញទៅមក" ក្នុងការងារ ស្រែចំការ, សង់ផ្ទះ, ដោះដូរគោ, ដោះដូរកំលាំងអូសទាញ, ដាំស្លពេលមាន ការជប់លៀង និងពិធីបុណ្យផ្សេងៗក្នុងសហគមន៍ ។ ភស្តុតាងទាំងអស់ នេះបានបង្ហាញថា ការជួយគ្នាទៅវិញទៅមកឃើញមានជាក់ស្តែងទាំងពីមុន និងនៅក្រោយទសវត្សរ៍១៩៧០ ។

## ការស្រាវជ្រាវ

ដោយប្រើប្រាស់វិធីសាស្ត្រសិក្សាខាងជាតិពន្ធវិទ្យា នៅពាក់កណ្តាលឆ្នាំ ២000 ខ្ញុំបានចុះសិក្សាដល់ទីកន្លែងនៅក្នុងភូមិមួយជិតក្រុងសៀមរាប ក្នុងពេលកំពុងមានការជជែកវែកញែកដូចលើកខាងលើស្តីពីចំណងសាមគ្គីក្នុងសង្គម និងការបំបែកខ្លួនតូចៗ ។ ការស្រាវជ្រាវនេះបានរកឃើញថា ទីមួយ បែបបទផ្សេងៗនៃការជួយគ្នាទៅវិញទៅមក*ជាទូទៅ*និង *មានតុល្យភាព* នៅមាននៅឡើយនៅក្នុងភូមិ ។ ទីពីរ ខ្ញុំបង្ហាញថា បែបបទខ្លះៗនៃការជួយគ្នាទៅវិញទៅមក*ជាទូទៅ* និង *មានតុល្យភាព* មានតួនាទីយ៉ាងសំខាន់ក្នុងការរក្សាចំណងសាមគ្គីក្នុងសង្គមក្នុងចំណោមអ្នកភូមិ ហើយចំណងសាមគ្គីនេះនឹងជួយទ្រទ្រង់ជីវភាពសេដ្ឋកិច្ចនៅជនបទ ទាំងនៅកំរិតភូមិ និងកំរិតគ្រួសារ ។ ទីបី ខ្ញុំមានជំនឿថា ការផ្លាស់ប្តូរដ៏សំខាន់មួយកំពុងកើតមានឡើងដែលអាចធ្វើឱ្យប្រែប្រួលដល់ប្រព័ន្ធជួយគ្នាទៅវិញទៅមក ដោយមានតុល្យភាព (មិនមែនបំផ្លាញវាទេ) នៅក្នុងភូមិ ពីព្រោះបច្ចុប្បន្នប្រជាជនជាច្រើននាក់បានបំរើការងារ យកប្រាក់កំរៃ ។ ការងារស្រាវជ្រាវខាងជាតិពន្ធវិទ្យានឹងជួយបំភ្លឺពីបែបបទបច្ចុប្បន្ននៃការជួយគ្នាទៅវិញទៅមក និងការពឹងផ្អែកគ្នាទៅវិញទៅមកនៅក្នុងស្រទាប់មហាជន ។ តាមលទ្ធផលនៃការស្រាវជ្រាវ ខ្ញុំមានជំនឿថា ក្រោយសង្គ្រាមស៊ីវិល ២៥ឆ្នាំនេះមក ចំណងសាមគ្គីក្នុងសង្គមនៅក្នុងភូមិ បានវិលត្រឡប់មកតាមលំនាំមុនពេលមានសង្គ្រាមវិញហើយ ។ ខ្ញុំបានពិនិត្យពីបែបបទដែលប្រជាជនជួយគ្នា និងសហការគ្នាទៅវិញទៅមក ជាពិសេសខ្ញុំបានពិនិត្យពីទំនាក់ទំនងខាងសង្គមកិច្ចនៅកំរិតគ្រួសារ ក្រុមញាតិ ក្រុមសាសនា និងក្រុមនយោបាយ ព្រមទាំងពិនិត្យពីអត្ថន័យខាងវប្បធម៌ដែលទ្រទ្រង់ដល់ឥរិយាបទប្រជាជន ។ ខ្ញុំបានស្រាវជ្រាវផងដែរ ពីការយល់ឃើញតាមបែបពុទ្ធសាសនានៃ *ការសាងកុសល, និពា្ទ,* និង *កម្ម* ដោយបានផ្តោតលើការស្វែងយល់ពីទំនាក់ទំនងខាងវប្បធម៌នានាដូចជា ជំនឿ, បុណ្យទាន, តំលៃផ្សេងៗ, គំនិត, និងអារម្មណ៍ ។ ឯកសារនេះសិក្សា

* អត្ថបទនេះ បានដកស្រង់ចេញពីសារណាសំរាប់អនុបណ្ឌិតរបស់ខ្ញុំនៅ សាកលវិទ្យាល័យ Northern Illinois ឆ្នាំ២០០១ ។

អង្កេតពីក្រុមក្រៅផ្លូវការផ្សេងៗនៃប្រជាជនដើម និងពិនិត្យនូវប្រព័ន្ធជួយគ្នាទៅវិញទៅមកជាទូទៅនៅក្នុងគ្រួសារ, បងប្អូន, និងការជួយគ្នាទៅវិញទៅមកក្នុងចំណោមអ្នកភូមិ ។ តាំងពីដើមរៀងមក គេតែងទទួលស្គាល់ថាប្រព័ន្ធទាំងនេះមានឥទ្ធិពលយ៉ាងខ្លាំងទៅលើជីវិតរស់នៅរបស់ប្រជាជនកម្ពុជា។ ដើម្បីស្រាយបង្ហាញពីទំនាក់ទំនងជួយគ្នាទៅវិញទៅមក ខ្ញុំបានពិនិត្យពីអន្តរកម្មនៅក្នុងភូមិ និងក្នុងគ្រួសារ ។ ការសង្កេតពីបែបបទផ្សេងៗនៃការជួយគ្នាទៅវិញទៅមកក្នុងភូមិ នឹងជួយបំភ្លឺពីដំណើរការនៃប្រព័ន្ធជួយគ្នាទៅវិញទៅមក ។ បែបបទទាំងនេះមានដូចជាពួកអ្នកភូមិប្រមូលគ្នាសង់ផ្ទះ, ជួយដល់អ្នកគ្មានផ្ទះសំបែង និងស្ត្រីមេម៉ាយនៅក្នុងភូមិ, ដោះដូរពលកម្ម គ្នាក្នុងការងារធ្វើស្រែ, កសាងផ្លូវស្ពានក្នុងភូមិ ។ល។ ដោយការសិក្សានេះ មានកិរិតតូចដូច្នេះមិនអាចយកមកអះអាងជាទូទៅពីចរិតនៃចំណងសាមគ្គីក្នុងសង្គមនៅតាមភូមិក្នុងទូទាំងប្រទេសកម្ពុជាបានទេ ។

ក្នុងឯកសារនេះ ការវិភាគពីការជួយគ្នាទៅវិញទៅមកនៅក្នុងជីវភាពរស់នៅក្នុងភូមិកម្ពុជា បានផ្អែកលើឯកសារជាច្រើនស្តីពីប្រភេទផ្សេងៗនៃការ ជួយគ្នាទៅវិញទៅមក (ជាទូទៅ និងតុល្យភាព) និងបែបបទនៃការជួយគ្នា ទៅវិញទៅមក បានបង្កើតនូវទំនាក់ទំនងនៅក្នុងភូមិ (Sahlins 1972)។

## វិធីសាស្ត្រ និងទីតាំងភូមិ

សំរាប់ការងារស្រាវជ្រាវនេះ ខ្ញុំបានចំណាយពេលជាងពីរខែនៅក្នុងភូមិ ដើម្បីធ្វើសំភាសន៍ស៊ីជំរៅ និងធ្វើអង្កេតតាមការចូលរួម ។ លើសពីនេះទៀត ខ្ញុំបានជួបស្គាល់ពួកអ្នកភូមិចំនួន ៧ឆ្នាំកន្លងមកហើយ ដោយសារពីមុន ខ្ញុំធ្លាប់បានធ្វើការនៅក្នុងអង្គការជួសជុលប្រាសាទនៅអង្គរ ។ ខ្ញុំបានប្រើប្រាស់បច្ចេកទេសធ្វើសំភាសន៍ពាក់កណ្តាលរៀបរយ (semi-structured interview:

***ទំនាក់ទំនងជួយគ្នាជាទូទៅក្នុងចំណោមសាច់ញាតិឈរលើមូលដ្ឋានពីរ: ១-សមាជិកគ្រួសារម្នាក់ៗមាន "កាតព្វកិច្ច" ជួយដល់សាច់ញាតិរបស់ខ្លួនដើម្បីកែលំអស្ថានភាពសេដ្ឋកិច្ច និង ២-បុគ្គលម្នាក់ៗត្រូវធានាដល់សុខុមាលភាពនៃសាច់ញាតិ***

ការសំភាសន៍ស្រង់ពត៌មានមិនតាមលំដាប់បញ្ជីសំនួរ) ជាមួយប្រធានភូមិ អ្នកចាស់ទុំ, មេគ្រួសារ, ប្រជាជនមាតុភូមិនិវត្តន៍, និងអ្នកភូមិមួយចំនួនដែលធ្វើការក្នុងអង្គការផ្សេងៗនៃគំរោងជួសជុលប្រាសាទក្នុងឧទ្យានអង្គរ ។ ដោយហេតុថា ការស្រាវជ្រាវនេះផ្តោតលើទំនាក់ទំនងនៃការជួយគ្នាទៅវិញទៅមកក្នុងគ្រួសារ ខ្ញុំបានកសាងទំនាក់ទំនងយ៉ាងល្អជាមួយគ្រួសារពីរ: គ្រួសារទី មួយ ជាជនមាតុភូមិនិវត្តន៍ពីមកទល់ដែនថៃ ឯគ្រួសារទីពីរ ជាគ្រួសារធូរធារមួយនៅ ក្នុងភូមិ ។

តំបន់សិក្សាគឺ ភូមិអង្គរក្រៅ ក្នុងឃុំគោក ចក ស្រុកសៀមរាប ខេត្តសៀមរាប ។ ភូមិ នេះពឹងផ្អែកយ៉ាងធ្ងន់ធ្ងរលើការធ្វើស្រូវ និងដំណាំផ្សេងៗ, ចិញ្ចឹមសត្វ, នេសាទ, លក់កំលាំងពលកម្ម ឬលក់ដូរតូចតាចនៅ ក្រុងសៀមរាប ។ យុទ្ធសាស្ត្ររកចិញ្ចឹមជីវិតចំបងមួយរបស់អ្នកភូមិ គឺពលកម្មយកប្រាក់កំរៃ ។ បុរសជាច្រើននៅក្នុងភូមិបានទៅធ្វើការជាមួយអង្គការខាងជួសជុលប្រាសាទផ្សេងៗដែលធ្វើសកម្មភាពក្នុងឧទ្យានអង្គរ ។ សព្វថ្ងៃនេះមាន ៤០៤គ្រួសាររស់នៅក្នុងភូមិ ដោយប្រមូលផ្តុំគ្នាក្នុងកូនភូមិតូចៗពីរគឺ កូនភូមិខាងកើត និងកូនភូមិខាងលិច។ ភូមិបែងចែកជា ២៣ក្រុម មានប្រជាជនសរុប ២.១៥៣នាក់ ក្នុងនេះ ប្រុសមាន ១.០៤៤នាក់, ស្រីមាន ៩៦៧នាក់ និងមនុស្សអាយុលើសពី ១៨ឆ្នាំ ៤៣៩នាក់ ។ ភូមិនេះជាភូមិចាស់គឺមានតាំងពីមុនឆ្នាំ១៩៧៥ ហើយមានប្រវត្តិនិយាយតៗគ្នាថា កើតមានតាំងពីសម័យអង្គរម្លេះ ។ ភូមិនេះគ្មានវត្តទេ ប៉ុន្តែដូចភូមិតូចៗឯទៀតក្នុងតំបន់នោះដែរ ប្រជាជនតែងទៅធ្វើបុណ្យនៅវត្តក្នុងបរិវេណអង្គរ ។ ភូមិនេះស្ថិតនៅចំងាយ ១៧គ.ម. ពីខាងជើងទីរួមខេត្តសៀមរាប ហើយប្រជាជនតែងទៅផ្សារឯទីរួមខេត្ត ដើម្បីទិញទំនិញធំៗសំរាប់តំរូវការក្នុងគ្រួសារ ។ មធ្យោបាយធ្វើដំណើរចំបងៗគឺមាន ម៉ូតូ និង កង់ ។

## ការជួយគ្នាទៅវិញទៅមកនៅក្នុងភូមិ

*ទំនាក់ទំនងក្នុងគ្រួសារ:* ការចុះដល់ភូមិរបស់ខ្ញុំបានរកឃើញថា ទំនាក់ទំនងក្នុងគ្រួសារ និងរវាងសាច់ញាតិ មានសារៈសំខាន់ជាគន្លឹះនៅក្នុងភូមិ អង្គរក្រៅ ។ ការទទួលស្គាល់គ្នារវាងសាច់ញាតិ មានជាអាទិ ការស្រឡាញ់រាប់អានគ្នាទៅវិញទៅមក, ការទុកចិត្តគ្នា, ការទទួលខុសត្រូវ, ជំនួយទ្រទ្រង់, កិច្ចការពារ, និងមនោសញ្ចេតនាជាបងប្អូន ។ នៅក្នុងអត្ថបទនេះ ខ្ញុំខិតខំ ពិពណ៌នាពីទំនាក់ទំនងរវាងសាច់ញាតិទាំងជាចំហ និងមិនចំហ, ហើយជាពិសេស នឹងពិនិត្យពីកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមករវាងបង-ប្អូន និងរវាងឪពុកម្តាយ-កូនប្រុសស្រី ដែលមានសារៈសំខាន់ជាមូលដ្ឋានសំរាប់ធានាស្ថិរភាពសេដ្ឋកិច្ចក្នុងក្រុមគ្រួសារ ។ អ្នកភូមិយល់ឃើញថា ទំនាក់ទំនងទាំងនេះមានចរិតដូចគ្នានឹងកាលពីសម័យមុនសង្គ្រាម ។ នៅពេលខ្ញុំចុះធ្វើការនៅក្នុងភូមិ ខ្ញុំបានផ្តោតជាសំខាន់លើគ្រួសារពីរខុសគ្នាដែលបានពិពណ៌នារួចហើយ ។

ក្នុងករណីទាំងពីរនៃទំនាក់ទំនងក្នុងគ្រួសារ យើងឃើញថា បែបបទនៃការជួយដល់សាច់ញាតិនៅមានច្រើននៅឡើយនៅក្នុងភូមិ ។ ទំនាក់ទំនងក្នុងគ្រួសារមានលក្ខណៈជាការជួយគ្នាជាទូទៅ ប៉ុន្តែវាបានចាប់ផ្តើមប្រែប្រួលខ្លះហើយ ដោយសារការចូលមកដល់នៃសេដ្ឋកិច្ចប្រើប្រាក់កាស ។ ទំនាក់ទំនងជួយគ្នាជាទូទៅក្នុងចំណោមសាច់ញាតិ ឈរលើមូលដ្ឋានពីរ: ១-សមាជិកគ្រួសារម្នាក់ៗមាន "កាតព្វកិច្ច" ជួយដល់សាច់ញាតិរបស់ខ្លួនដើម្បីកែលំអ ស្ថានភាពសេដ្ឋកិច្ច និង ២-បុគ្គលម្នាក់ៗត្រូវធានាដល់សុខុមាលភាពនៃសាច់ញាតិនានារបស់ខ្លួន ។

ការស្រាវជ្រាវរបស់ខ្ញុំបានបង្ហាញថា ការជួយគ្នាទៅវិញទៅមក កើតមានឡើងក្នុងគ្រប់គ្រួសារនៅក្នុងភូមិ ទាំងអ្នកក្រីក្រ និងអ្នកធូរធារ ។ ប៉ុន្តែទំហំនៃ ការជួយគ្នានេះ វាជាប់ទាក់ទងនឹងទំហំធន ធាន និងចិត្តស្រឡាញ់រាប់អានរបស់បុគ្គល ម្នាក់ៗចំពោះសាច់ញាតិរបស់ខ្លួន ។[1] សកម្មភាពជួយគ្នាទៅវិញទៅមកក្នុងគ្រួសារមិនមែនមានតែក្នុងការស្រាវជ្រាវរបស់ខ្ញុំនៅក្នុងភូមិនេះទេ ប៉ុន្តែមានបង្កប់នៅក្នុងគ្រប់ទំនាក់ទំនងក្នុងគ្រួសារកម្ពុជាទាំងអស់ ។

*សកម្មភាពជួយគ្នាទៅវិញទៅមកនៅក្នុងភូមិ:* ក្រៅពីទំនាក់ទំនងក្នុងគ្រួសារ មានចំណងសាមគ្គីនៅក្នុងសហគមន៍រវាងអ្នកជិតខាងគ្នានិង មិត្តភ័ក្តិ ដោយសារការបានចូលរួមជាច្រើនឆ្នាំនៅក្នុងបណ្ដាញខាងសង្គមកិច្ច ផ្សេងៗ ។ ទោះបីក្នុងរយៈពេលដែលខ្ញុំស្នាក់នៅក្នុងភូមិ គេបានរៀបចំពិធីបុណ្យផ្សេងៗតែពីរ-បីលើកក៏ដោយ ក៏វាបានបង្ហាញពីអារម្មណ៍ច្បាស់លាស់របស់ប្រជាជនថា សហគមន៍នេះគឺជាសហគមន៍ខ្លួន និងការមានភក្ដីភាព ចំពោះសហគមន៍ ។ គ្រួសារនានាជួយគ្នាទៅវិញទៅមកក្នុងការងារកសិកម្ម, សង់ផ្ទះ, ឱ្យប្រាក់កាស ឬស្រូវអង្ករខ្ចីដោយមិនយកការប្រាក់, ជួយជាពេល វេលា ស្បៀង និងបច្ច័យដល់វត្ត, ជួយធ្វើការងារក្នុងគ្រួសារដូចជាមើលក្មេង នៅពេលដែលឪពុក-ម្ដាយជាប់រវល់, និងជួយដាំស្ល ឬធ្វើរោងនៅពេលមានបុណ្យទាន ។ សកម្មភាពបែបនេះយូរៗទៅ (អាចច្រើនតំណមនុស្ស) បានបង្កើតនូវទំនាក់ទំនងល្អក្នុងសហគមន៍ មិត្តភាព និងការទុកចិត្តគ្នា ។ ដោយសារចំរដូវភ្លៀង ខ្ញុំមិនសូវឃើញមានសកម្មភាពសង់ផ្ទះទេ ប៉ុន្តែមានការសង់ស្ពានមួយ, ជួសជុលថ្នល់, ជួសជុលផ្ទះ, ជួសជុលទំនប់មួយ, ជួយចូលរួមក្នុង ពិធីបំបួសកូនប្រធានឃុំ, និងជួយដោះស្រាយទំនាស់ដីធ្លីមួយរឿង ។[2] អ្នកផ្ដល់ពត៌មានជាច្រើននាក់ក៏បានរាយការណ៍ពី បែបបទផ្សេងទៀតនៃការជួយគ្នាទៅវិញទៅមក ដូចជាក្នុងការងារធ្វើស្រែ, ក្នុងពេលមានបុណ្យទាន ឬមានគ្រោះអាសន្នជាដើម ។ ខ្ញុំបានពិនិត្យឃើញសកម្មភាពជួយគ្នាទៅវិញទៅមកជាទូទៅមួយចំនួនទៀតក្នុងភូមិដូចជា ការជីកអណ្ដូង និងស្រះទឹក, ការកសាងសាលារៀន, ការរានដី, ការឱ្យខ្ចីស្រូវអង្ករ ឬប្រាក់កាស ដោយមិនយកការប្រាក់... ។

*ឥទ្ធិពលនៃពុទ្ធសាសនាទៅលើទំនាក់ទំនងជួយគ្នាទៅវិញទៅមក:* ពុទ្ធសាសនាមានឥទ្ធិពលយ៉ាងច្រើនទៅលើសកម្មភាពជួយគ្នាទៅវិញទៅមកនៅក្នុងសង្គមកម្ពុជា ។ ការយល់ឃើញតាមបែបពុទ្ធសាសនាមានបង្កប់នៅក្នុងពិធីបុណ្យពុទ្ធសាសនាផ្សេងៗដូចជា ពិធីបំបួស នាគ, កឋិនទាន, ពិធីបង្កក់ឆ្អឹប, និងនៅក្នុង ទស្សនៈស្ដីពីគុណ ។ អត្ថបទជាប់ទាក់ទងនឹងទ្រឹស្ដីពុទ្ធសាសនាស្ដីពីការជួយគ្នាទៅវិញទៅមកមានសរសេរនៅក្នុងឯកសារផ្សេងគ្នារបស់ Ebihara 1962, Kalab 1968, ដែលខ្ញុំមិន អាចពិពណ៌នាឱ្យបានអស់នៅក្នុងអត្ថបទនេះ ។

***សកម្មភាពជួយគ្នាទៅវិញទៅមកដោយមាន តុល្យភាព វាជួយបង្កើតប្រាក់ចំណូលដល់បុគ្គល ពង្រឹងចំណងសាមគ្គីក្នុងសង្គម និងជួយកាត់បន្ថយ ភាពក្រីក្រ ទោះបីជាវាបានប្រែប្រួលរូបរាងខ្លះ ដោយសារសេដ្ឋកិច្ចប្រើប្រាក់កាស គំនិតផ្ដួចផ្ដើម របស់បុគ្គលការជួបទាក់ទងផ្ទាល់ ទំនាក់ទំនងសាច់ញាតិ និងកាតព្វកិច្ចក៏ដោយ ។***

## ការជួយគ្នាទៅវិញទៅមកមានតុល្យភាព

ការជួយគ្នាទៅវិញទៅមកមានតុល្យភាព ឃើញមានជារឿយៗនៅក្នុងការងារធ្វើស្រែ ។ នៅក្នុងភូមិចុះស្រាវជ្រាវ ប្រជាជនដោះដូរពលកម្មគ្នាក្នុងការងារធ្វើស្រែ ពីព្រោះវាជាមធ្យោបាយតែមួយដើម្បីរៀបចំដីឱ្យបានទាន់ពេលនៅក្នុងរដូវភ្លៀង ។ អ្នកភូមិក៏មានឱ្យខ្ចី ឬសុំខ្ចី ប្រាក់កាស ឬស្រូវអង្ករ ដល់សាច់ញាតិឬមិត្តភ័ក្តិជិតដិតដោយគ្មានការប្រាក់, និងមានការចិញ្ចឹមសត្វ ប្រវាស់គ្នា ពីព្រោះអ្នកភូមិខ្លះគ្មានប្រាក់សំរាប់ទិញគោឬជ្រូកទេ ។ សកម្មភាពជួយគ្នាទៅវិញទៅមកដោយមានតុល្យភាព បានជួយបង្កើតប្រាក់ចំណូលដល់បុគ្គល ពង្រឹងចំណងសាមគ្គីក្នុងសង្គម និងជួយកាត់បន្ថយភាពក្រីក្រ ទោះបី ជាវាបានប្រែប្រួលរូបរាងខ្លះដោយសារសេដ្ឋកិច្ចប្រើប្រាក់កាស គំនិតផ្ដួចផ្ដើមរបស់បុគ្គល ការជួបទាក់ទងផ្ទាល់ ទំនាក់ទំនងសាច់ញាតិ និងកាតព្វកិច្ច ក៏ដោយ ។ ដូច្នេះការជួយគ្នាទៅវិញទៅមកដោយមានតុល្យភាព ឃើញមានពិតមែន ទោះបីវាបានប្រែប្រួលខ្លះៗដោយសារមានការប៉ះទង្គិចពីសេដ្ឋកិច្ចប្រើប្រាក់កាសក៏ដោយ ។

*ការដោះដូរពលកម្មក្នុងការងារធ្វើស្រែ (ប្រវាស់ និងចូលដៃ):* ខ្ញុំបានពិនិត្យឃើញប្រជាជនដោះដូរពលកម្មគ្នាក្នុងការងារភ្ជួររាស់ ដកស្ទូង និងច្រូតកាត់ ។ ប្រវាស់សំដៅដល់ការព្រមព្រៀងច្រើនបែបយ៉ាងរវាងគូភាគី ឬបុគ្គល ពីរនាក់ ក្នុងការដោះដូរពលកម្ម និងសំភារៈ ដើម្បីម្នាក់ៗអាចធ្វើការដាំដុះទៅបាន ។ នេះជាវិធីចែករំលែក ឬផ្ដល់ឱ្យគ្នានូវអ្វីដែលខ្លួនមានជាថ្នូរនឹងអ្វីដែលខ្លួនត្រូវការ ហើយវាផ្អែកជាសំខាន់លើគោលការណ៍នៃការជួយគ្នាទៅវិញទៅមក ។ ការធ្វើស្រែប្រវាស់គឺជាបែបបទមួយដែលក្នុងនេះ ប្រជាជនដោះដូរការប្រើប្រាស់ដីស្រែជាមួយនឹងមួយភាគនៃផលស្រូវ ។ កសិករដែលមានដីស្រែច្រើន ទាក់ទងឱ្យកសិករឯទៀតដាំដុះលើដីខ្លួន ដោយទាមទារយកផលស្រូវមួយចំនួននៅពេលច្រូតកាត់ ។ ប្រព័ន្ធមួយទៀតនៃការដោះដូរពលកម្មកសិកម្ម គឺការចូលដៃ (ឬយកដៃ) ដែលជាការដោះដូរពលកម្មគ្នាស្មើទៅស្មើមកតាមពេលកំណត់ជាក់លាក់ ។

*ការខ្ចីស្រូវអង្ករ និងធនាគារស្រូវ:* អ្នកភូមិជាច្រើនពុំមានស្រូវអង្ករគ្រប់គ្រាន់សំរាប់ហូបទេ

ហើយទៅសុំខ្ចីស្រូវពីសាច់ញាតិ ឬអ្នកជិតខាងដោយគ្មាន ការប្រាក់ ។ នៅពេលប្រជាជនជួបស្ថានភាពធ្ងន់ធ្ងរខ្លាំង ពួកគេច្រើនទៅសុំខ្ចី ប្រាក់ពីមិត្តភ័ក្តិ ឬសាច់ញាតិ ភាគច្រើនដោយគ្មានបង់ការប្រាក់ទេ ។ នៅក្នុងភូមិមានកម្មវិធីធនាគារស្រូវមួយដែរដែលរៀបចំឡើងដោយ NGO ប៉ុន្តែប្រជាជននៅតែចូលចិត្តខ្ចីបុលពីសាច់ញាតិ និងមិត្តភ័ក្តិដដែល ។ ហេតុផលមួយគឺថា ជាប្រពៃណីនៅពេលប្រជាជនខ្វះស្រូវអង្ករធ្ងន់ធ្ងរហើយត្រូវខ្ចីបុល គេតែងទៅសុំខ្ចីជាដំបូងពីសាច់ញាតិ បើមិនបានទេ ទើបគេទៅសុំខ្ចីពីមិត្តភ័ក្តិជិតស្និទ្ធរបស់ពួកគេ ។

*ពលកម្មស៊ីឈ្នួល:* នៅក្នុងភូមិមានពលកម្ម ស៊ីឈ្នួលជាច្រើន ។ វិធីនេះអាចបកស្រាយ ថា ជារូបភាពមួយនៃការជួយគ្នា ទៅវិញទៅមកដោយមានតុល្យភាព ។ ដើម្បីជួល ពលករ គេត្រូវចងសម្ព័ន្ធភាពជាមួយប្រជាជន មួយចំនួនភាគច្រើនជាប្រជាជនក្នុងភូមិជា មួយគ្នា ។ គ្រប់ៗគ្នាត្រូវកសាងសម្ព័ន្ធភាពនេះតាមចំណងទាក់ទងរយៈពេលវែង ។ អ្នក ខ្លះជួយភ្ជួរស្រែឱ្យគ្រួសារស្រីមេម៉ាយ ហើយជាការតបស្នង ស្រីមេម៉ាយមកជួយវិញក្នុងការងារដកស្ទូង ឬច្រូតកាត់ ។ ការស្រាវជ្រាវនេះបានរកឃើញថា មានអ្នកភូមិជាច្រើនបានជួលពលកម្មដោយប្រាក់កាស ។ អ្នកភូមិច្រើនគ្នាដែលខ្ញុំបានសន្ទនាជាមួយមានមតិថា ពលកម្មស៊ីឈ្នួលប្រសើរជាងនិងមានប្រសិទ្ធិភាពខ្ពស់ជាងពលកម្មប្រវាស់ដៃ ពីព្រោះចំពោះពលកម្មស៊ីឈ្នួល ម្ចាស់ដីមិនចាំបាច់ផ្តល់បាយទឹកឱ្យពលករទេ ហើយក៏មិនចាំបាច់សងពលកម្មទៅឱ្យអ្នកមកជួយខ្លួនវិញដែរ ។ ប៉ុន្តែនៅក្នុងរដូវដាំដុះ និងច្រូតកាត់ មិនសូវមានប្រជាជនលក់ពលកម្មច្រើននាក់ទេ ដូច្នេះហើយអ្នកភូមិបានកសាងឡើងនូវក្រុមតូចមួយសំរាប់ការជួលពលកម្ម ។ នៅក្នុងការងារនេះ សមាជិកក្រុមទាំងអស់ត្រូវស្មោះត្រង់នឹងគ្នា និងផ្តល់លទ្ធភាពឱ្យសមាជិកក្រុមគ្រប់គ្នាអាចប្រើប្រាស់បាននូវចំណងទាក់ទងនេះ ។ ដូច្នេះគោលគំនិតនៃការជួលពលកម្ម ក៏ជារូបភាពមួយទៀតដែរនៃការជួយគ្នាទៅវិញទៅមក ។

*ការចិញ្ចឹមសត្វប្រវាស់:* ការដោះដូរពលកម្មមួយទៀតគឺការ “ ចិញ្ចឹមសត្វប្រវាស់” ។ ជាញឹកញយ អ្នកភូមិចិញ្ចឹមជ្រូក ឬគោប្រវាស់គ្នា ។ តាមធម្មតាអ្នកភូមិដែលមានម៉ាស៊ីនកិនស្រូវ គេអាចចិញ្ចឹមជ្រូកបានច្រើនក្បាល ពីព្រោះគេបានកន្ទក់ពីការកិនស្រូវ ។ ការយកស្រូវទៅកិននៅរោងម៉ាស៊ីនមិនចាំបាច់បង់ប្រាក់ទេ ពីព្រោះម្ចាស់រោងម៉ាស៊ីនគេយកកន្ទក់ ។ ការចិញ្ចឹមជ្រូកជាការងាររបស់ស្ត្រី ហើយតាមធម្មតាគឺកូនស្រីជាអ្នកទទួលបន្ទុក ។ ការប្រវាស់ជ្រូកច្រើនធ្វើឡើងក្នុងរង្វង់សាច់ញាតិ ។ ឧទាហរណ៍ បើបុគ្គលណាម្នាក់មានមេជ្រូកដែលមានកូនច្រើន គេឱ្យកូនជ្រូកខ្លះទៅសាច់ញាតិ ហើយទៅអនាគតបើសិនបុគ្គលនោះត្រូវការកូនជ្រូក គេអាចសុំពីសាច់ញាតិមកវិញខ្លះបាន ។ ក្នុងការប្រវាស់គោ តាមធម្មតាម្ចាស់គោយកមេគោមកវិញនៅពេលវាមានកូនទី២ដែលត្រូវបានទៅម្ចាស់គោដែរ ពីព្រោះនៅពេលនោះកូនគោទី១ ដែលត្រូវបានទៅអ្នកចិញ្ចឹមប្រវាស់ វាធំល្មមអាចរស់នៅបែកពីមេបានហើយ ។ វិធីប្រវាស់គោក្របីមានប្រសិទ្ធិភាពល្អ ក្នុងការជួយឱ្យអ្នកក្រីក្រមានគោប្រើប្រាស់នឹងគេ ។ ការប្រវាស់គោភាគច្រើនធ្វើឡើងរវាងសាច់ញាតិ និងមិត្តភ័ក្តិជិតស្និទ្ធនៅក្នុងភូមិ ប៉ុន្តែមានគ្រួសារខ្លះក៏ចិញ្ចឹមគោប្រវាស់ជាមួយមិត្តភ័ក្តិក្នុងភូមិផ្សេងដែរ ។ ក្នុងករណីនេះអ្នកចិញ្ចឹមប្រវាស់ត្រូវទទួលបន្ទុកចិញ្ចឹម និងថែទាំគោឱ្យបានល្អ ។ ម្ចាស់គោតែងមកមើលគោម្តងម្កាល ហើយបើសិនជាគេឃើញថា អ្នកនោះចិញ្ចឹមថែទាំគោមិនបានល្អ គេមានសិទ្ធិយកគោទៅវិញ ។

## សេចក្តីសន្និដ្ឋាន

គោលដៅចំបងនៃការស្រាវជ្រាវនេះ គឺរួមចំណែកដល់ការស្វែងយល់ពីបែបបទផ្សេងៗនៃការជួយគ្នាទៅវិញទៅមកនៅក្នុងជនបទកម្ពុជា ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សាចំណងសាមគ្គីក្នុងសង្គម និងជួយទ្រទ្រង់ដល់សេដ្ឋកិច្ចនៅជនបទ ។ ខ្ញុំបានរាយការណ៍ហើយពីបែបបទផ្សេងៗនៃការជួយគ្នាទៅវិញទៅមក*ជាទូទៅ* និង *មានតុល្យភាព* ។ បែបបទនេះប្រហាក់ប្រហែលគ្នានឹងបែបបទក្នុងសម័យមុនសង្គ្រាមដែរ ដូចមានបញ្ជាក់នៅក្នុងឯកសារជាច្រើន ។ វត្តមាននៃសកម្មភាពជួយគ្នាទៅវិញទៅមកក៏មានចុះនៅក្នុងឯកសារដែលទើបសរសេរក្នុងសម័យបច្ចុប្បន្ននេះដែរ ។ ការស្រាវជ្រាវរបស់ខ្ញុំបានបង្ហាញលទ្ធផលផ្ទុយគ្នាពីគំនិតរបស់អ្នកស្រាវជ្រាវមួយក្រុមដែលយល់ឃើញថា នៅក្រោយរយៈពេលមានសង្គ្រាមស៊ីវិល ២៥ឆ្នាំនេះ ចំណងសាមគ្គីក្នុងភូមិកម្ពុជាភាគច្រើនត្រូវបានបំផ្លាញចោលអស់ ។

គេអាចជជែកវែកញែកថា ការប្រែប្រួលខាងសេដ្ឋកិច្ច-សង្គមកិច្ច និងនយោបាយក្នុងរយៈពេល ២៥ឆ្នាំចុងក្រោយ បានធ្វើឱ្យបែបបទនៃការជួយគ្នាទៅវិញទៅមកកាលពីសម័យមុនសង្គ្រាម បានផ្លាស់ប្តូរមកដូចអ្វីដែលយើងកំពុងពិនិត្យឃើញក្នុងភូមិកម្ពុជានាពេលសព្វថ្ងៃនេះ ។ ការស្រាវជ្រាវនេះបានរកឃើញថា បែបបទជួយគ្នាទៅវិញទៅមកនៅក្នុងភូមិបានផ្លាស់ប្តូរហើយ ហើយឥទ្ធិពលនៃសេដ្ឋកិច្ចប្រើប្រាក់កាស គឺជាកត្តាដែលធ្វើឱ្យផ្លាស់ប្តូរដល់ចរិតនៃការជួយគ្នាទៅវិញទៅមកនៅក្នុងភូមិ ។ មនុស្សជាច្រើនចង់ធ្វើការងារ យកប្រាក់កំរៃដោយគួបផ្សំជាមួយការធ្វើស្រែដើម្បីដោះស្រាយការហូបចុក ក្នុងគ្រួសារ ពីព្រោះពួកគេមើលឃើញថា ប្រាក់កាសគឺជាជំរើសមួយសំរាប់ជំនួសការងារកសិកម្មដ៏ហត់នឿយ ។ ប៉ុន្តែសកម្មភាពជួយគ្នាទៅវិញទៅមកដោយមានតុល្យភាពនៅតែមានសារៈសំខាន់ស្នូលសំរាប់ពួកអ្នកភូមិ ។ ប្រជាជនតែងអនុវត្តការដោះដូរពលកម្ម ដើម្បីអាចភ្ជួររាស់ដកស្ទូងស្រែភ្លឺរបស់ខ្លួនបានទាន់ពេលទាន់រដូវភ្លៀង ។ ការដោះដូរពលកម្មសំរាប់ការងារធ្វើស្រែមានជាអាទិ ការប្រវាស់, ការចូលដៃ, ការឱ្យខ្ចីស្រូវអង្ករ ដែលត្រូវសងវិញជាពលកម្ម, និងការចិញ្ចឹមសត្វប្រវាស់ ។ ក្នុងពេលសព្វថ្ងៃ ការជួយគ្នាទៅវិញទៅមកដោយមានតុល្យភាពកំពុងផ្លាស់ប្តូរដោយសារឥទ្ធិពល នៃសេដ្ឋកិច្ចប្រើប្រាក់កាស ជាពិសេសនៅក្នុងការងារធ្វើស្រែរបស់ប្រជាជនស្រទាប់ក្រោម ក៏ប៉ុន្តែវាមិនបានបាត់បង់អស់នោះទេ ។ បន្តពីការសិក្សានេះ គួរមានការស្រាវជ្រាវថែមទៀតពីឥទ្ធិពលនៃសេដ្ឋកិច្ចប្រើប្រាក់កាស និងពលកម្មយកប្រាក់កំរៃទៅលើសហគមន៍កម្ពុជា ជាពិសេសលើប្រព័ន្ធធ្វើកសិកម្មតាមបែបប្រពៃណី ។

# ប្រាក់ចំណូលរបស់ពលករងាយរងគ្រោះៈ ការពិចារណាពីភាពក្រីក្រក្នុងក្រុងភ្នំពេញ

**តើស្រទាប់ពលករងាយរងគ្រោះក្នុងតំបន់ទីក្រុងបានទទួលប្រាក់ចំណូលច្រើនជាងពីកាលមុនឬយ៉ាងណា? លោកស្រី ប៊ុន ដូរីណា និង លោក Sarthi Acharya បានពិនិត្យពីលំនាំប្រាក់ចំណូលរបស់ស្រទាប់ប្រជាជនក្រីក្រក្នុងក្រុងភ្នំពេញនៅក្នុងទសវត្សរ៍ចុងក្រោយនេះ ។***

## សេចក្តីផ្តើម

អត្ថបទនេះបានធ្វើការផ្គុំ និងបន្សុំទិន្នន័យនានាស្តីពីប្រាក់ចំណូលពលករនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅទីក្រុង (urban informal sectors) ដើម្បីវាយតំលៃថា តើពលករទាំងនេះដែលភាគច្រើនជាជនចំណាកស្រុកបានកើនប្រាក់ចំណូលឬទេនៅក្នុងទសវត្សរ៍កន្លងទៅ ឬនិយាយមួយបែបទៀតថាតើចំណាកស្រុកគឺជាយុទ្ធសាស្ត្រមានជោគជ័យល្អឬទេ ក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ។ ក្រុងភ្នំពេញត្រូវបានជ្រើសយកមកសិក្សា ពីព្រោះវាជាទីក្រុងតែមួយដែលមានជនចំណាកស្រុកចូលមកច្រើនដើម្បីស្វែងរករបរចិញ្ចឹមជីវិតដែលមិនមែនជាសកម្មភាពធ្វើកសិកម្ម ។

នៅកម្ពុជា ស្ថិតិផ្លូវការស្តីពីប្រាក់កំរៃ និងប្រាក់ចំណូលអាចស្រង់បានពីអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (Socio-Economic Surveys: SES) និងអង្កេតពលកម្ម (Labour Surveys: LS) ។ ទិន្នន័យ SES មានសំរាប់ឆ្នាំ១៩៩៣, ១៩៩៧, និង ១៩៩៩, ឯទិន្នន័យ LS មានសំរាប់ឆ្នាំ១៩៩៧ និង ១៩៩៨ ។[១] តាំងពីឆ្នាំ១៩៩៨ មក វិបសអ ក៏បានប្រមូលទិន្នន័យប្រចាំត្រីមាសលើប្រាក់ចំណូលរបស់ពលករងាយរងគ្រោះជ្រើសរើសជាច្រើនប្រភេទក្នុងភ្នំពេញដែរ ។ ទិន្នន័យមិនបានគ្របដណ្តប់លើពលករគ្រប់ប្រភេទនៅក្នុងវិស័យខ្សោយៗនៃសេដ្ឋកិច្ចនោះទេ ប៉ុន្តែវាតំណាងឱ្យពលករទាំងនេះបានល្អគួរសមដែរ ។ និន្នាការនៃភាពក្រីក្រ គឺអាចវាយតំលៃតាមទិន្នន័យទាំងនេះបាន ពីព្រោះប្រាក់កំរៃរបស់ពលករក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៃទីផ្សារពលកម្ម ពិសេសក្នុងស្រទាប់អ្នកមានប្រាក់កំរៃកំរិតទាប កន្លងមកឃើញមានរូបភាពប្រហាក់ប្រហែលគ្នាជាច្រើន (ILO, 2000) ។ សំណុំទិន្នន័យទាំងអស់នេះ មិនមែន សុទ្ធតែបង្ហាញពីប្រាក់ចំណូល*ទាំងអស់*ដែលពលករ និងគ្រួសាររបស់គេរកបាននោះទេ ។ ដូច្នេះ ការសិក្សានេះគ្រាន់តែមានគោលដៅធ្វើការវាស់វែងពីលទ្ធភាពរបស់ការងារខ្លះៗក្នុងការផ្តល់ប្រាក់ចំណូលតែប៉ុណ្ណោះ ហើយកំរិតប្រាក់ចំណូលនេះវាជួយបំភ្លឺពីតំរូវការនៃការងារឬមុខរបរដែលមានកំរិតពាក់កណ្តាលជំនាញ/គ្មានជំនាញ នៅក្នុងរាជធានី ។

អត្ថបទនេះប្រើប្រាស់ទិន្នន័យប្រាក់ចំណូលបានពីប្រភពរដ្ឋាភិបាល និង វិបសអ ។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់បានពីប្រភពរដ្ឋាភិបាល ក៏ត្រូវបានយកមកប្រើប្រាស់ដែរ ហើយយើងមានជំនឿថា ការប្រមូលទិន្នន័យពីប្រភពច្រើនដូច្នេះ វាមិនធ្វើឱ្យមានការមិនស៊ីសង្វាក់គ្នាធ្ងន់ធ្ងរខាងស្ថិតិទេ ។

## និន្នាការនៃប្រាក់ចំណូលៈ ភស្តុតាងបានពី SES

កន្លងមក ធ្លាប់មានការសិក្សាអំពីប្រាក់ចំណូលរបស់ពលករ និងមានការផ្តល់មតិអំពីទំនាក់ទំនងរវាងភាពក្រីក្រ និងប្រាក់ចំណូលរួចមកហើយ ។ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចទី២ ត្រូវបានបញ្ជាក់យ៉ាងជាក់លាក់ច្បាស់លាស់ថា ការបែងចែកផលចំណេញ មិនបានទៅដល់ប្រជាជនជាទូទៅទេ (RGC 2001) ។

SES បីលើកត្រូវបានធ្វើឡើងជាបន្តបន្ទាប់ក្នុងឆ្នាំ១៩៩៣, ១៩៩៧, និង ១៩៩៩ ។ SES ឆ្នាំ១៩៩៣ មិនបានផ្តល់ការប៉ាន់ស្មានពីប្រាក់កំរៃប្រចាំថ្ងៃទេ ។ តាមអង្កេតនេះ ប្រាក់ចំណូល *គ្រួសារ* ជាមធ្យមក្នុងក្រុងភ្នំពេញគឺ ៥៣៥.៥៤២រៀលក្នុងមួយខែ រីឯប្រាក់ចំណូលប្រចាំខែនៃ *គ្រួសារនៅក្នុងបញ្ចភាគដែលមានចំណូលទាបជាងគេគឺ* ១១០.៤៦៥រៀល (RGC 1995) ។ ក្រោយពីបានកែតំរូវតាមអនុបាតចូលរួមពលកម្ម (labour participation ratio) តួលេខប្រាក់ចំណូលគឺ ៤៣.១៥០រៀលក្នុងពលករម្នាក់ក្នុងមួយខែ ឬប្រហែល ២.០០០រៀលក្នុងពលករម្នាក់ក្នុងមួយថ្ងៃសំរាប់ពលករ ២០%ដែលក្រីក្រជាងគេ (គណនាលើមូលដ្ឋានក្នុងមួយខែមាន ២៣-២៥ថ្ងៃធ្វើការ) ។ ដោយប្រើទិន្នន័យដដែលប្រាក់ចំណូលប្រចាំថ្ងៃនៃពលករម្នាក់ដែលគិតជារួមសំរាប់ *គ្រប់ស្រទាប់ប្រាក់ចំណូល* និងដែលបានពីការងារចំបងក្នុងវិស័យឯកជនត្រូវបានប៉ាន់ស្មានថា ស្ថិតក្នុងចន្លោះពី ៤.២០០រៀល ទៅ ៥.០០០ រៀល ឬទាបជាងនេះបន្តិចទៀតសំរាប់វិស័យសាធារណៈ ។ SES ឆ្នាំ១៩៩៧ បានបង្ហាញថា ប្រាក់ចំណូលប្រចាំខែរបស់ពលករម្នាក់ *ក្នុងតំបន់ទីក្រុង* (ធ្វើក្រប-ពុម្ព និងការងារជាប់ទាក់ទិន, ប្រក់ដំបូល, ក្រាលការ៉ូ) មានកំរិតពី ៤៤.១៥៨ ដល់ ១៦៤.៧៩២រៀល ហើយពុំឃើញមានការ គណនាដាច់ដោយឡែកសំរាប់ក្រុងភ្នំពេញ ឬសំរាប់បញ្ចភាគនិមួយៗ នៃកំរិតប្រាក់ចំណូលទេ ។ ដូច្នេះប្រាក់កំរៃប្រចាំថ្ងៃនៃពលករទាំងនេះគឺពី ៣.០០០ ដល់ ៧.០០០រៀល (RGC 1997) ។ ដោយហេតុថា ពីឆ្នាំ១៩៩៣-៩៧ អតិផរណាប្រចាំឆ្នាំជាមធ្យមមានប្រហែល ៧% ដូច្នេះកំរិតប្រាក់ចំណូលក្នុងពលករម្នាក់គិតតាមទិន្នន័យបានពី SES ឆ្នាំ១៩៩៧ ដោយគិតតាមកំរិតថ្លៃក្នុងឆ្នាំ១៩៩៣ និងដោយធ្វើមធ្យមភាគលើមុខរបរផ្សេងៗ គឺ ៧២.៣៤២រៀលក្នុងមួយខែ ឬប្រហែល ៣.៥០០រៀលក្នុងមួយថ្ងៃ ។

ក្នុងឆ្នាំ១៩៩៩ *ប្រាក់ចំណូលគ្រួសារជាមធ្យម* ក្នុងមួយខែនៅក្នុងទីក្រុងភ្នំពេញគឺ ១.១៣៩.៥៣៣រៀល ឬ ២១៩.៧៧១រៀលក្នុងមនុស្សម្នាក់ (RGC 1999) ។ សំរាប់*បញ្ចភាគទាបបំផុត* ប្រាក់ចំណូលគ្រួសារក្នុងមួយខែជាមធ្យមគឺ ៣៩០.៩៣៤រៀល ឬ ៧១.០៧៩រៀលក្នុងមនុស្សម្នាក់ ។ ដោយសារក្នុងរយៈពេលពីឆ្នាំ១៩៩៣-៩៧ អតិផរណាប្រចាំឆ្នាំមានប្រហែល ៧% និងពីឆ្នាំ១៩៩៧-៩៩ វាមានកំរិត ១១%, ដូច្នេះក្រោយធ្វើការកែតំរូវ

---

* អ្នកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ និង លោក Sarthi Achaya ជានាយកស្រាវជ្រាវនៅ វិបសអ ។ អ្នកនិពន្ធសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះ យោបល់ និងការណែនាំពី លោក ជា ហួត, លោក ចន្ទ័ សុផល, លោក សុក ហាច និង អ្នកស្រី ទេព សារ៉ាវី ។

ហើយ *ប្រាក់ចំណូលគ្រួសារប្រចាំខែជាមធ្យម* គឺ ៦៥៩.២៦៣រៀល គិតតាមកំរិតថ្លៃក្នុងឆ្នាំ១៩៩៣ ។ សំរាប់គ្រួសារ ២០% ដែលក្រីក្រជាងគេ ប្រាក់ចំណូលគិតតាមកំរិតថ្លៃឆ្នាំ១៩៩៣ គឺ ២២៦.៥៣៧រៀល ហើយក្រោយការ កែតំរូវតាមអនុបាតចូលរួមពលកម្ម គឺត្រូវជា ៨៩.៤៩១រៀលក្នុងពលករម្នាក់ក្នុងមួយខែ ឬ ៣.៥០០-៤.០០០រៀលក្នុងមួយថ្ងៃ ។

ចេញពីស្ថិតិទាំងនេះ មានពីរចំណុចដែលបានផុសឡើងយ៉ាងច្បាស់ ។ ទីមួយប្រាក់ចំណូលពិតប្រចាំថ្ងៃជាមធ្យមនៃប្រជាជន ២០%ដែលក្រីក្រជាងគេបានកើនប្រហែលពី២.០០០រៀលក្នុងឆ្នាំ១៩៩៣ ដល់ប្រហែល ៤.០០០រៀលក្នុងឆ្នាំ១៩៩៩ ។ ទីពីរ ប្រាក់ចំណូលគ្រួសារ*សរុប*ពិតជាមធ្យមប្រចាំខែ បានកើនពី ៥៣៩.៥៤២រៀល ដល់ ៦៥៩.២៦៣រៀល ក្នុងរយៈពេលដូចគ្នា ។ ទិន្នន័យ SES ឆ្នាំ១៩៩៧ ដែលគេបានផ្សព្វផ្សាយ គឺមិនអាចប្រៀបធៀបជាមួយនឹងទិន្នន័យឆ្នាំ១៩៩៣ ឬទិន្នន័យឆ្នាំ១៩៩៩ បានទេ ប៉ុន្តែដោយផ្អែកលើតួលេខគិតសរុប១ (aggregates) គេអាចទាញការសន្និដ្ឋានបានថាពីឆ្នាំ១៩៩៣ ដល់ ១៩៩៩ ពុំមានការកែលំអកំរិតប្រាក់កំរៃគួរឱ្យកត់សំគាល់ទេសំរាប់ស្រទាប់ក្រីក្រ នៃកំលាំងពលកម្ម ។

## ទិន្នន័យអង្កេតកំលាំងពលកម្ម

ការអង្កេតកំលាំងពលកម្ម ត្រូវបានធ្វើឡើងសំរាប់ ៥ត្រីមាស គឺត្រីមាសទី២, ត្រីមាសទី៣, និងត្រីមាសទី៤ នៃឆ្នាំ១៩៩៧, និងត្រីមាសទី២ និងត្រីមាសទី៤ នៃឆ្នាំ១៩៩៨ ។ ការអង្កេតទាំងនេះមិនបានប្រមូលពត៌មានពីតួលេខពិតប្រាកដនៃប្រាក់កំរៃរបស់អ្នកឆ្លើយសំភាសន៍ទេ គឺប្រមូលតែទិន្នន័យតាមស្រទាប់ប្រាក់ចំណូលប៉ុណ្ណោះ ។ ទិន្នន័យស្តីពីប្រាក់កំរៃ និងប្រាក់ចំណូល ត្រូវបានកែតំរូវតាមអតិផរណា និងស្រង់បញ្ចូលទៅក្នុងប្រភេទទាំង បួននៃពលករមានប្រាក់កំរៃទាបៈ បុរសអ្នកទទួលប្រាក់កំរៃ, ស្ត្រីអ្នកទទួលប្រាក់កំរៃ, បុរសអ្នកផ្តល់អាជីពខ្លួនឯង, ស្ត្រីអ្នកផ្តល់អាជីពខ្លួនឯង ។ គេ

**ក្រាហ្វិក១: ប្រាក់កំរៃ និងប្រាក់ចំណូលប្រចាំខែពិតជាមធ្យម, គិតតាមភេទ និងតាមស្ថានភាពធ្វើការងារ, ភ្នំពេញ, ពីត្រីមាសទី២ ១៩៩៧ ដល់ត្រីមាសទី៤ ១៩៩៨**




ប្រភពៈ LFSPP databases, NIS

ឃើញមានចំណុចមួយត្រូវប្រុងប្រយ័ត្នៈ ក្នុងចំណោមពលករទាំងនេះអាចមានទាំងអ្នកខ្លះដែលមិនមែនជាពលករងាយរងគ្រោះទេ, ដូច្នេះហើយទិន្នន័យអាចលំអៀងកើនខ្ពស់បន្តិច ។

ក្រាហ្វិក១ កត់ត្រាប្រាក់ចំណូលនៃពលករទាំងបួនប្រភេទ ក្នុង ៥ត្រីមាសនៃឆ្នាំ១៩៩៧-៩៨ ហើយវាបង្ហាញថា ពលករទាំងអស់បានធូរធារគួរឱ្យកត់សំគាល់នៅក្នុងត្រីមាសទី២ ឆ្នាំ១៩៩៧ នៅពេលធ្វើអង្កេត SES ឆ្នាំ១៩៩៧ ។ ប្រាក់ចំណូលពិតជាមធ្យមប្រចាំថ្ងៃនៃពលករបុរសអ្នកផ្តល់អាជីពខ្លួនឯងបានជិតដល់ ៧.៩០០រៀល, ពលករស្ត្រីអ្នកផ្តល់អាជីពខ្លួន ឯងបានប្រហែល ៦.៣៦៤រៀល, បុរសអ្នកទទួលប្រាក់កំរៃ បានប្រហែល ៤.៥៤៥រៀល, ស្ត្រីអ្នកទទួលប្រាក់កំរៃ បានប្រហែល ៣.៨៦៥រៀល ។[២] នៅក្នុងត្រីមាសទី៣ ឆ្នាំ១៩៩៧ ក្រោយការវាយប្រយុទ្ធក្នុងខែ កក្កដា ប្រាក់ចំណូលនៃពលករគ្រប់ប្រភេទបានធ្លាក់ចុះ ។ បន្ទាប់មកប្រាក់ចំណូលបានកើន បន្តិចវិញ ពិសេសក្រោយដំណាច់ឆ្នាំ១៩៩៧, ប៉ុន្តែរហូតដល់ចុងឆ្នាំ១៩៩៨ ការរើបឡើងវិញពេញលេញ ឃើញមានតែក្នុងចំណោមពលករទទួលប្រាក់កំរៃ ហើយក្នុងនេះវាកើតឡើងចំពោះពលករបុរស ច្រើនជាងចំពោះពលករស្ត្រី ។ ដោយឡែកពលករបុរសអ្នកផ្តល់អាជីពខ្លួនឯង មានប្រាក់ចំណូលធ្លាក់ចុះគំហុកជាងគេ ។

ក្នុងរយៈពេលពីឆ្នាំ១៩៩៧-៩៨ នៅពេលដែលប្រាក់ចំណូលជាតិធ្លាក់ចុះ ប្រាក់ចំណូលពិតនៃក្រុមពលករងាយរងគ្រោះនានា ក៏ធ្លាក់ចុះដែរ ។[៣]

## អង្កេតរបស់ វបសអ ស្តីពីពលករងាយរងគ្រោះ

ក្នុងឆ្នាំ១៩៩៨ វបសអ បានចាប់ផ្តើមធ្វើអង្កេតពីប្រាក់ចំណូលនៃពលករងាយរងគ្រោះ ។ ក្នុងពីរឆ្នាំដំបូង ទិន្នន័យត្រូវបានប្រមូលលើប្រាក់ចំណូលពលករងាយរងគ្រោះបួនក្រុមៈ អ្នកធាក់ស៊ីក្លូ, អ្នកលក់ដូរតូចតាច, អ្នកលីសែង, និងអ្នករើសអេតចាយ ។ នៅដើមឆ្នាំ២០០០ ក្រុមពលករងាយរងគ្រោះត្រូវបានពង្រីកដោយបញ្ចូលថែមនូវអ្នកបំរើតាមហាង, អ្នកស៊ីឈ្នួលធ្វើស្រែ, កម្មកររោងចក្រកាត់ដេរ, អ្នករត់ម៉ូតូឌុប, កម្មករសំណង់គ្មានជំនាញ, និងកម្មករសំណង់មានជំនាញ ។ ទោះបី ១០ក្រុមពលករនេះ មិនមែនជាបញ្ជីសព្វគ្រប់នៃពលករងាយរងគ្រោះគ្រប់ប្រភេទក៏ដោយ ក៏វាតំណាងឱ្យពលករមួយភាគធំដែរ ។ម្យ៉ាងវិញទៀត មុខរបរទាំងនេះក៏មិនមែនជាប្រភពចំណូលតែមួយរបស់ពលករនិងគ្រួសារគេដែរ ។ ប៉ុន្តែ និន្នាការនៃប្រាក់ចំណូលក្នុងពលករម្នាក់ វាជាអាំងឌីកាទ័រយ៉ាងល្អ ដែលបង្ហាញពីភាពក្រីក្រ និងកំរិតជីវភាព ។

ស្ថិតិទិន្នន័យតារាង១ កំនត់សំគាល់ទី១ ជាប់ទាក់ទិននឹងទំហំជាទឹកប្រាក់ (absolute levels) នៃប្រាក់កំរៃ និងប្រាក់ចំនូល ។ ក្នុងមុខរបរសឹងតែទាំងអស់ (ក្រៅពីសំណង់ចេញ) កំរៃមានទំហំពី ១-២ដុល្លារ (សីហា ២០០១) ហើយក្នុងករណីខ្លះ តិចជាង ១ដុល្លារផង ។[៤] អ្នកយ៉ាប់យ៉ឺនជាងគេ គឺអ្នកស៊ីឈ្នួលធ្វើស្រែ, អ្នករើសអេតចាយ, និងអ្នកបំរើតាមហាង ។ ប៉ុន្តែដោយក្នុងករណីជាច្រើន អ្នកបំរើតាមហាងបានទទួលរបបបាយទឹកពីម្ចាស់ហាង ដូច្នេះគេអាចសន្និដ្ឋានថា អ្នកស៊ីឈ្នួលធ្វើស្រែ និងអ្នករើសអេតចាយ គឺជាអ្នកក្រ

**តារាង១: និន្នាការនៃប្រាក់ចំណូលប្រចាំថ្ងៃរបស់ពលករងាយរងគ្រោះ គិតជារៀលតាមកំរិតថ្លៃឆ្នាំ១៩៩៤, ភ្នំពេញ, ១៩៩៨-២០០១**

| ខែ | អ្នកធាក់ស៊ីក្លូ | អ្នកលីសែង | អ្នកលក់ដូរតូចតាច | អ្នករើសអេតចាយ | អ្នកបំរើតាមហាង | អ្នកស៊ីឈ្នួលធ្វើស្រែ | កម្មករកាត់ដេរ | អ្នករត់ម៉ូតូឌុប | កម្មករសំណង់គ្មានជំនាញ | កម្មករសំណង់មានជំនាញ |
|---|---|---|---|---|---|---|---|---|---|---|
| Feb-98 | 9100 | 6905 | 5150 | 3415 | | | | | | |
| May-98 | 6696 | 5198 | 3264 | 2918 | | | | | | |
| Aug-98 | 5674 | 4342 | 4386 | 2401 | | | | | | |
| Nov-98 | 5490 | 4089 | 5322 | 2310 | | | | | | |
| Feb-99 | 8654 | 7860 | 7289 | 3401 | | | | | | |
| May-99 | 8437 | 7149 | 6092 | 2690 | | | | | | |
| Aug-99 | 7574 | 6701 | 5762 | 2705 | | | | | | |
| Nov-99 | 7403 | 5529 | 8164 | 2340 | | | | | | |
| Feb-00 | 8907 | 9613 | 7235 | 4370 | 2154 | 3212 | 8469 | 8464 | 8458 | 14603 |
| May-00 | 9013 | 7442 | 6758 | 4621 | 2360 | 3720 | 9616 | 11253 | 6417 | 14508 |
| Aug-00 | 8655 | 7342 | 6016 | 3809 | 2560 | 4043 | 9669 | 11050 | 7480 | 13551 |
| Nov-00 | 7380 | 6570 | 5760 | 3510 | 2925 | 3690 | 9338 | 9000 | 6750 | 10080 |
| Feb-01 | 7626 | 6789 | 5952 | 3627 | 3023 | 3813 | 9648 | 9300 | 6975 | 10416 |
| Apr-01 | 8898 | 6564 | 6869 | 2483 | 3023 | 3360 | 8719 | 11207 | 7683 | 9585 |
| Aug-01 | 8423 | 6964 | 6203 | 2498 | 3119 | 4185 | 10654 | 9820 | 5231 | 11509 |
| Quarterly trend growth rate [1] (%) | 1.40 | 2.10 | 2.70* | 0.90 | 6.30* | 1.90 | 1.70 | 0.90 | -4.10 | -6.50* |

[1]The trend growth rate has been calculated by estimating a semi-logarithmic equation, ln (wage)=a1+a2 (time) using the regression method. The growth rate is the estimated value of a2.

កំណត់សំគាល់: -ប្រាក់ចំណូលអ្នកបំរើតាមហាង គ្មានគិតរបបបាយទឹកម្ចាស់ហាងផ្តល់ឱ្យទេ ។ សំរាប់អ្នកបំរើតាមហាង និងកម្មករកាត់ដេរ ប្រាក់កំរៃប្រចាំថ្ងៃ ត្រូវបានគណនាតាមការកែតំរូវលើប្រាក់ខែដែលមាន ២៣-២៥ថ្ងៃធ្វើការក្នុងមួយខែ ដើម្បីអាចប្រៀបធៀបបានជាមួយទិន្នន័យពីមុនៗ ។ ចំពោះពលករឯទៀត ទិន្នន័យបញ្ជាក់ពីប្រាក់ចំណូលប្រចាំថ្ងៃជាក់ស្តែង ។ -Asterisks refer to statistical significance of the coefficient at 5 percent confidence. ប្រភព: វិបសអ ។

ជាងគេក្នុងចំណោមពលករ ។ ម្យ៉ាងទៀតដោយអ្នកស៊ីឈ្នួលធ្វើស្រែ និងអ្នករើសអេតចាយជាពលករមានកំរិតជំនាញទាបបំផុត ដូច្នេះវាជាសញ្ញាបង្ហាញថា ជំនាញល្អអាចនាំមកនូវចំនូលខ្ពស់ ។ ការស្រាវជ្រាវរបស់ វិបសអក៏បានបង្ហាញដែរថា ពលករគ្មានជំនាញភាគច្រើន គឺជាជនចំណាកស្រុកថ្មីមកពីជនបទ ។[៥] ប្រាក់ចំណូលទាបរបស់ពួកគេ គឺជាសញ្ញាបង្ហាញថា ភាពក្រីក្រនៅក្នុងទីក្រុង គឺជាការហៀរចូលនៃភាពក្រីក្រមកពីជនបទ ។

អត្រាកំណើននិន្នាការក្នុងប្រាក់ចំណូលពិតនៃពលករតាមប្រភេទនិមួយៗត្រូវបានគណនាក្នុងបន្ទាត់ក្រោមបំផុតនៃ តារាង១ ។ មានចំណុចបីដែលគួរកត់សំគាល់ ។ ទីមួយ ក្នុងចំណោមអត្រាកំណើននិន្នាការប្រចាំត្រីមាស សឹងតែគ្មានមួយណាសោះដែលធំលើសពី ១-២%នៅក្នុងរយៈពេលនេះ (មានខ្លះទាបជាង ១% ឬ អវិជ្ជមានផង ក្នុងរយៈពេល ៤ឆ្នាំនេះ) ។ មានតែប្រាក់ចំណូលអ្នកបំរើតាមហាងទេដែលមានអត្រាកំណើនប្រចាំត្រីមាសប្រហែល ៦% ។ ទីពីរ ក្នុងចំណោមអត្រាកំណើនវិជ្ជមាននៃប្រាក់ចំណូល មានតែប្រាក់ចំណូលអ្នកលក់ដូរតូចតាច និងអ្នកបំរើតាមហាងទេ ដែលមានមេគុណធំគួរកត់សំគាល់ខាងស្ថិតិ (statistically significant coefficients), ក្នុងករណីឯទៀត ទំនុកចិត្តចំពោះមេគុណទាំងនេះ គឺមិនគ្រប់គ្រាន់ទេសំរាប់បញ្ជាក់ថា អត្រាកំណើន *បានសំរេចជាក់ស្តែងមែន* ។ ទីបី កម្មករសំណង់មានជំនាញមាននិន្នាការអវិជ្ជមានក្នុងប្រាក់ចំណូលរបស់ខ្លួន គឺ -៦,៥% (កំរិតគួរកត់សំគាល់ខាងស្ថិតិ) ឯកម្មករសំណង់គ្មានជំនាញក៏មានការធ្លាក់ចុះប្រាក់ចំណូលដែរ ប៉ុន្តែនិន្នាការគ្មានលក្ខណៈគួរឱ្យកត់សំគាល់ខាងស្ថិតិទេ ។ សរុបមក តួលេខទាំងនេះវាបញ្ជាក់គាំទ្រការសន្និដ្ឋានពីខាងដើមដែលថា ប្រាក់ចំណូលរបស់ជនក្រីក្រ ឬមួយនៅទ្រឹង ឬមួយបានថយចុះ ហើយវាក៏បញ្ជាក់ថែមទៀតថា ប្រាក់ចំណូលជានៅទ្រឹងជាបន្តទៀតនៅក្នុងសហសវត្សរ៍ថ្មី ។[៦]

តាំងពីឆ្នាំ១៩៩៨ មក កំណើនប្រាក់ចំណូលជាតិពិតក្នុងមនុស្សម្នាក់មានកំរិតទាបៈ ក្នុងឆ្នាំ១៩៩៨ វាមានកំរិតអវិជ្ជមាន, ក្នុងឆ្នាំ១៩៩៩ វារើបដល់ ៣,៥%, ហើយក្នុងឆ្នាំ២០០០ វាធ្លាក់ដល់តិចជាង ២% វិញ ។ ក្នុងឆ្នាំ ២០០១ គេប៉ាន់ថា វាមិនលើសពី ១,៥-២% ទេ ។ ប្រាក់កំរៃផ្សេងៗកើនឡើងតែក្នុងករណីដែលចំណូលសរុបកើនឡើង ហើយវាកើនលឿននៅពេលដែលសមាសធាតុនៃកំណើនមានប្រើពលកម្មច្រើន ។ នៅក្នុងប្រទេសកម្ពុជាលក្ខខណ្ឌទាំងនេះបំពេញមិនសូវបានល្អទេ ។ វិស័យសាងសង់នៅស្ទើកមិនលូតលាស់, ឧស្សាហកម្មកាត់ដេរបានធ្លាក់កំណើនបន្តិច[៧] ហើយកំណើនយានយន្តឯកជន (ម៉ូតូ, រថយន្ត) ជាកត្តាប្រកួតប្រជែងយ៉ាងខ្លាំងចំពោះស៊ីក្លូ និងម៉ូតូឌុប ។ ដូចគ្នាដែរ ការធ្វើយន្តកម្មផ្សេងៗ បានច្រានចេញនូវកម្មករគ្មានជំនាញ និងអ្នកលីសែង ។ ប្រាក់កំរៃក៏ទទួលរងសំពាធសង្កត់ចុះដែរ ដោយសារមានចំណាកស្រុកកាន់តែច្រើនឡើងពីជនបទ ចូលមកក្រុងភ្នំពេញ ។

គ្មានការបែងចែកជាក់លាក់នូវកំរិតប្រាក់កំរៃដោយសារភេទទេ ប៉ុន្តែជំនាញទេគឺជាកត្តាកំណត់ប្រាក់កំរៃ ។ តារាង១ បង្ហាញថា អ្នករើសអេតចាយ (បុរស) និងអ្នកបំរើតាមហាង (ស្ត្រី) បានប្រាក់កំរៃទាបបំផុត, បន្ទាប់មកគឺកម្មករសំនង់គ្មានជំនាញ (ទាំងពីរភេទ) ។ ចំនែកឯកម្មករសំនង់មានជំនាញ (បុរស) អ្នករត់ម៉ូតូឌុប និងអ្នកធាក់ស៊ីក្លូ (បុរស) កម្មករកាត់ដេរ (ស្ត្រី) និងអ្នកលក់ដូរតូចតាច (ទាំងពីរភេទ) អាចរកប្រាក់កំរៃបានច្រើនជាង ។

## ការកាត់បន្ថយភាពក្រីក្រក្នុងក្រុង

ការនៅទ្រឹង ឬការធ្លាក់ចុះ នៃប្រាក់កំរៃរបស់ជនក្រីក្រនៅក្នុងក្រុង កើតចេញមួយចំណែកពីការធ្លាក់កំណើនសេដ្ឋកិច្ចក្នុងប៉ុន្មានឆ្នាំចុងក្រោយ ។ ប៉ុន្តែ

ក្រៅពីហេតុផលបែបបូរាណនេះ នៅមានស្ថានភាពជាក់ស្ដែងមួយទៀត ។ ស្ថានភាពនេះគឺមូលដ្ឋានតូចពេកនៃកំណើនសេដ្ឋកិច្ចដែលមិនមែនជាការធ្វើស្រែ (ឧស្សាហកម្មកាត់ដេរ, ទេសចរណ៍, វិស័យសាងសង់, និងវិស័យទូរគមនាគមន៍ដ៏តូច, ហើយវិស័យទាំងអស់នេះក៏មិនមែនសុទ្ធតែប្រើពលកម្មច្រើនដែរ ជាពិសេសពលកម្មចំណាកស្រុកចូលមកក្នុងក្រុង) ។ ក្នុងរឿងនេះ ក៏រិតជំនាញ និងការអប់រំ មានសារៈសំខាន់បំផុត ។ សកម្មភាពមិនមែនកសិកម្ម*ទាំងអស់* ត្រូវការនូវក៏រិតជំនាញខ្ពស់ជាងអ្វីដែលពលករមកពីជនបទ (ជនចំណាកស្រុក គ្មានជំនាញ) អាចផ្ដល់ឱ្យបាន ។ បន្ទាប់មក ស្ថានភាពប្រទេសកម្ពុជាដែលមានសកម្មភាពនគរូបនីយកម្មនៅជុំវិញទីក្រុងស្ទើលតែមួយ គឺជាឧបសគ្គយ៉ាងធំ ។ ទីក្រុងធំទី២ គឺមានប្រជាជនតែមួយភាគដប់នៃក្រុងភ្នំពេញប៉ុណ្ណោះ ។ ក្រៅពីក្រុងភ្នំពេញ គ្មានក្រុងណាទៀតទេ ដែល មានសក្ដានុពលគួរឱ្យកត់សំគាល់ក្នុងការស្រូបកំលាំងពលកម្មយកទៅប្រើនៅក្នុងវិស័យមិនមែនកសិកម្ម ហើយស្ថានភាពនេះបានធ្វើឱ្យបញ្ហាកាន់តែតឹងតែងឡើង ។ មួយចំណែកទៀត លទ្ធភាពនៃការផ្ដល់អាជីពដោយខ្លួនឯងកំពុងជួបការលំបាកយ៉ាងធំក្នុងពេលសព្វថ្ងៃ ដោយសារ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សង្គមកិច្ច និងសេដ្ឋកិច្ច មានសភាពយ៉ាប់យ៉ឺន ។ ដូច្នេះហើយ ខណៈដែលប្រទេសផ្សេងៗមានសហគ្រាសធុនតូចដែលផ្ដល់ការងារឱ្យមនុស្សជាច្រើនធ្វើ គេពុំឃើញមានករណីបែបនេះកើតឡើងនៅកម្ពុជាទេ ។

កសិកម្មនៅកម្ពុជា មិនបានដើរតាមគន្លងបូរាណរបស់អាស៊ីទេ ព្រោះគ្មានការប្រើពលកម្មធ្វើកសិកម្មប្រពលវប្បកម្មដូចគេ (សូមមើលឯកសារ Ishikawa 1981) ។ រីឯបញ្ហាដីធ្លីនៅជនបទ គឺកំពុងខិតខំដោះស្រាយនៅឡើយ ហើយនៅក្នុងដំណើរការនេះប្រជាជនមួយចំនួនបានក្លាយជាអ្នកគ្មានដីធ្លី ។ កំណើនយ៉ាងលឿននៃប្រជាជន ក៏បានរុញច្រានដំណើរការថែមមួយក៏រិតទៀតដែរ ។ សភាពការណ៍ទាំងអស់នេះបានធ្វើឱ្យប្រជាជនគ្មានដីធ្លីកើនឡើងដោយមានជាច្រើននាក់បានធ្វើចំណាកស្រុកមកកាន់តំបន់ទីក្រុង ដូច្នេះ ហើយភាពក្រីក្រនៅជនបទ ក៏បានហូរចូលមកតំបន់ទីក្រុង ។

វាមានសារៈសំខាន់ខ្លាំងណាស់ ដែលគេត្រូវធ្វើនគរូបនីយកម្មឱ្យបានច្រើនកន្លែង, ធ្វើវិមជ្ឈការឧស្សាហាភាវូបនីយកម្ម, ពង្រីកចំនួនមុខរបរ, និងបង្កើនយ៉ាងលឿននូវក៏រិតជំនាញរបស់កំលាំងពលកម្ម ។ ឯការអភិវឌ្ឍន៍កសិកម្មដែលប្រើពលកម្មច្រើនក៏មិនត្រូវបំភ្លេចចោលដែរ ។ ការប្រែប្រួលទាំងអស់នេះ គឺមិនអាចជៀសផុតទេ បើសិនជាគេចង់បញ្ឈប់ការរីករាលដាលនៃភាពក្រីក្រ ។

## កំណត់ពន្យល់

១ ពលករងាយរងគ្រោះត្រូវបានកំណត់និយមន័យថា ជាអ្នកដែលមានប្រាក់ចំណូលទាប និងមិនទៀងទាត់ ។ ពលករទាំងនេះងាយនឹងធ្លាក់ចុះក្រោមបន្ទាត់ក្រីក្រ ដោយសារការប៉ះទង្គិចបន្តិចបន្តួចខាងសេដ្ឋកិច្ច ។
២ តួលេខប្រចាំថ្ងៃ ត្រូវបានគណនាចេញពីតួលេខមធ្យមប្រចាំខែ ។
៣ អាំងឌីកាទ័រម៉ាក្រូសេដ្ឋកិច្ចបានបង្ហាញពីការធ្លាក់ចុះ ប៉ុន្តែគ្មានកត្តាអថេរអ្វីផ្សេងក្រៅពីប្រាក់ចំណូលពិតរបស់អ្នកក្រទេ ដែលបានធ្លាក់ចុះ (see Sok *et al* 2001) ។
៤ ធនាគារពិភពលោកបានកំណត់និយមន័យ *អ្នកក្រណាស់* ជាអ្នករកចំណូលបាន ស្មើ ឬតិចជាង ១ដុល្លារក្នុងមួយថ្ងៃ, និង *អ្នកក្រ* ជាអ្នករកចំណូលបាន ១ ទៅ ២ដុល្លារក្នុងមួយថ្ងៃ ។
៥ សូមមើល *របាយការណ៍ថ្មីៗស្ដីពីសេដ្ឋកិច្ចកម្ពុជា* លេខចេញផ្សាយនានាក្នុង ឆ្នាំ២០០១ របស់ វិបសអ ។
៦ ការវិភាគលំអិតថែមទៀតមិនបានធ្វើទេ ដោយហេតុថាកំរងទិន្នន័យមានរយៈពេលខ្លី ហើយទិន្នន័យសំរាប់បំពេញបន្ថែមផ្សេងទៀត ក៏មិនអាចរកបានទេលើមូលដ្ឋានប្រចាំត្រីមាស ។
៧ កំណើនប្រាក់កំរៃកម្មករកាត់ដេរ កើតចេញពីការធ្វើសកម្មភាពតវ៉ារួមគ្នា និងតាមច្បាប់កំណត់ ។

## ឯកសារយោង

ILO (2000), *Employment Creation in the Informal Economy*, Report of Workshop. *www.ilo.org/public/english/region/asro/newdelhi/surajrep.htm.*

Ishikawa, S. (1981), *Labour Absorption in Asian Agriculture,* (Bangkok: ILO-ARTEP).

RGC (Royal Government of Cambodia) (1995), *Report of*

**Consider an Annual Subscription to all CDRI Publications**

For one convenient fee, which includes delivery, it is now possible to receive all the publications CDRI produces in a calendar year. This subscription includes:

1. 4 to 6 Working Papers, each of which presents the results of one of CDRI's studies.
2. The collected papers from the annual Development Analysis Network (DAN) study which CDRI coordinates with 6 other DAN-member research institutes in Cambodia, Thailand, Laos, and Vietnam.
3. 4 issues of CDRI's quarterly journal, *Cambodia Development Review,* which publishes articles on the latest socio-economic research, key development issues and analysis of the Cambodian and regional economies.
4. 4-6 *Policy Briefs* which summarise findings and policy recommendations from important CDRI studies.
5. Monthly bilingual (English and Khmer) *Flash Reports* which provide a snap shot of the Cambodian and regional economies.
6. The *Annual Economic Review,* analyses trends in key sectors of the Cambodian economy and presents comprehensive analysis of economic development and refom policy, plus key indicators of economic performance.

A subscription to all of CDRI's publications for 2001 can be purchased anytime during the calendar year, and all materials published in 2001 prior to commencement of the subscription, will be shipped immediately.

For prices and more information, please contact CDRI Publications at the address on the back cover.

# តាមដានសេដ្ឋកិច្ច —— ស្ថានភាពក្រៅប្រទេស

តួលេខសេដ្ឋកិច្ចថ្មីបំផុតបានបង្ហាញអោយឃើញថា ពិភពលោកហាក់ដូចជាកំពុងជួបគ្រោះថ្នាក់នៃការធ្លាក់ចុះសេដ្ឋកិច្ច។ ទំនុកចិត្តរបស់អថិតិជនចំពោះសេដ្ឋកិច្ចអាមេរិកនៅតែខ្សោយ ដែលបណ្តាលអោយផ្សារហ៊ុនធ្លាក់ចុះតំលៃ ។ ក្នុងការព្យាយាមកែតំរូវវិទ្ធិនាការនេះ ធនាគារសហព័ន្ធអាមេរិកបានបន្តបន្ធូរគោលនយោបាយរូបិយវត្ថុរបស់ខ្លួន ដោយកាត់បន្ថយថែមទៀត ក្នុងពេលថ្មីៗនូវអត្រាការប្រាក់រយៈពេលខ្លី។ សំរាប់តំបន់អាស៊ីវិញ, លើកលែងតែប្រទេសចិនចេញ, គឺកំពុងតែប្រឈមមុខចំពោះស្ថានភាពសេដ្ឋកិច្ចដ៏លំបាកមួយ ។ សូម្បីតែប្រទេសមានសេដ្ឋកិច្ចខ្លាំងដូចជាសឹង្ហបូរីក៏ដោយ ក៏កំពុងប្រឈមមុខនឹងបញ្ហាដែរ ។ សព្វថ្ងៃអត្រាប្តូរប្រាក់នៅទីផ្សារអន្តរជាតិពុំមានលំនឹងល្អទេ ប៉ុន្តែជាទូទៅអត្រាអតិផរណារនៅមានកំរិតទាបល្មមនៅឡើយ ។

## កំណើនសេដ្ឋកិច្ចក្នុងពិភពលោក

ក្នុងមួយឆ្នាំកន្លងទៅនេះ សេដ្ឋកិច្ចអាមេរិកបានបន្តធ្លាក់ចុះក្នុង ៤ត្រីមាសជាប់ៗគ្នា ។ ដោយឡែកក្នុងត្រីមាសទី២ ឆ្នាំ ២០០១ វាមានកំណើនតែ ១,២%ប៉ុណ្ណោះ ធៀបនឹង ៦%កាលពីមួយឆ្នាំកន្លងទៅ ។ ស្ថានភាពសេដ្ឋកិច្ចនៅបណ្តាប្រទេសអភិវឌ្ឍន៏ឯទៀតក៏ប្រហែលគ្នាដែរ ។ ក្នុងត្រីមាសទី២ ឆ្នាំ ២០០១ សេដ្ឋកិច្ចនៅអាល្លឺម៉ង់ មានកំណើនតែ ០,៦%ប៉ុណ្ណោះ ធៀបនឹងឆ្នាំកន្លងទៅ ឯនៅជប៉ុនវាមានកំណើន ០,២% ។ ឯតួលេខផលិតកម្មឧស្សាហកម្មនៃប្រទេសទាំងនេះគឺកាន់តែយ៉ាប់យ៉ឺនថែមទៀត ។ នៅខែកក្កដា ផលិតកម្មឧស្សាហកម្មនៅអាមេរិកបានធ្លាក់ចុះ ៣,២% ហើយជប៉ុន នៅខែមិថុនាវាធ្លាក់ចុះ៨,៧% បើធៀបនឹងឆ្នាំមុន។ នៅអឺរ៉ុបក៏ដូចគ្នាដែរ ផលិតកម្មឧស្សាហកម្មគ្មានការលូតលាស់ទេក្នុងរយៈពេលនេះ ហើយនៅត្រីមាសទី៣ ខាងមុខ ក៏មិនសង្ឃឹមថា នឹងមានសញ្ញាល្អដែរ ។ សន្ទស្សន៏ទំនុកចិត្តនៃអ្នកប្រើប្រាស់នៅអាមេរិកបានធ្លាក់ចុះដោយមិននឹកស្មានដល់ ដែលនាំអោយមានការធ្លាក់ចុះយ៉ាងខ្លាំងដល់តំលៃផ្សារភាគហ៊ុនក្នុងទូទាំងពិភពលោកនៅខែកញ្ញា ឆ្នាំ២០០១។ ទស្សនាវដ្តី Financial Times បានចុះផ្សាយថា អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ បានព្រមាននៅក្នុងរបាយការណ៏សេដ្ឋកិច្ចពិភពលោកដែលចេញផ្សាយក្នុងខែកញ្ញារបស់ខ្លួន អំពីគ្រោះថ្នាក់យ៉ាងធំនៃការធ្លាក់ចុះសេដ្ឋកិច្ចជាលក្ខណៈសាកល ។

នៅក្នុង ៨ខែដើមឆ្នាំនេះ, ធនាគារសហព័ន្ធអាមេរិកបានបញ្ចុះអត្រាការប្រាក់រយៈពេលខ្លីរបស់ខ្លួនចំនួន ៧លើក ដែលសរុបទាំងអស់មកបានធ្វើឱ្យអត្រាការប្រាក់ថយចុះអស់ ៣,០% និងដែលជាការកាត់បន្ថយការប្រាក់ធំបំផុតក្នុងប្រវត្តិសាស្ត្រធនាគារសហព័ន្ធ ។ ប៉ុន្តែវិធានការនេះហាក់ដូចជាបានផលតិចតួចណាស់ក្នុងការស្រោចស្រង់សេដ្ឋកិច្ចអាមេរិក ។ តាមពិតទៅគោលនយោបាយរូបិយវត្ថុត្រូវការពេលវេលាមួយរយៈ ទើបអាចហុចលទ្ធផលបាន ហើយជាក់ស្តែង ការព្យាយាមរបស់អាមេរិកដើម្បីបញ្ចៀសការធ្លាក់ចុះសេដ្ឋកិច្ច និងធ្វើអោយសេដ្ឋកិច្ចរើបឡើងវិញយ៉ាងឆាប់រហ័ស គឺមិនបានជោគជ័យរហូតមកទល់ពេលនេះ ។ ការកាត់អត្រាការប្រាក់ វាមិនសូវមានប្រសិទ្ធិភាពដូចការរំពឹងទុក គឺមកពីមូលនិធិដែលធនាគារសហព័ន្ធអោយធនាគារឯទៀតខ្ចី មានរយៈពេលខ្លី ឬខ្ចីតែមួយថ្ងៃៗ ។ ដូច្នេះហើយការប្រាក់ទាក់ទិននឹងមូលនិធិនេះ វាមានឥទ្ធិពលតែតិចតួចទៅលើសេដ្ឋកិច្ច ពីព្រោះក្រុមហ៊ុន និងគ្រួសារប្រជាជនពុំមានជាប់ទាក់ទងដោយផ្ទាល់នឹងមូលនិធិនេះទេ ។ ឯយន្តការផ្សេងៗសំរាប់ផ្ទេរផលចំណេញនៃការកាត់បន្ថយអត្រាការប្រាក់លើមូលនិធិសហព័ន្ធទៅដល់សេដ្ឋកិច្ចនោះ វាមាន ដំណើរការយឺតណាស់ ។ ដើម្បីពន្យល់ពីប្រសិទ្ធិភាពនៃគោលនយោបាយរូបិយវត្ថុរបស់ធនាគារសហព័ន្ធទៅលើកំណើនសេដ្ឋកិច្ច ទស្សនាវដ្តី The Economist របស់ប្រទេសអង់គ្លេស បានចុះផ្សាយការសិក្សាមួយរបស់ធនាគារសហព័ន្ធដែលបង្ហាញថា ការបញ្ចុះការប្រាក់ធនាគារសហព័ន្ធ ១% នឹង ធ្វើឱ្យសេដ្ឋកិច្ចមានកំណើន ១,៧% ប៉ុន្តែនៅពីរឆ្នាំខាងមុខឯណោះ, តែបើ ត្រឹមមួយឆ្នាំខាងមុខវិញ កំណើនសេដ្ឋកិច្ចបានតែ ០,៦% ប៉ុណ្ណោះ។ ដូច្នេះ បើសិនជាមានតែត្រឹមគោលនយោបាយរូបិយវត្ថុប៉ុណ្ណោះ ការរើបសេដ្ឋកិច្ចអាមេរិកនឹងត្រូវការពេលវេលាមួយរយៈ ហើយក្នុងរយៈពេលនោះឧស្សាហកម្មកាត់ដេររបស់កម្ពុជាអាចធ្លាក់ចុះសកម្មភាព។

ដូចប្រទេសខាងលិចដែរ, ដៃគូសេដ្ឋកិច្ចកម្ពុជាស្ទើរទាំងអស់ រងការគំរាមកំហែងនៃការធ្លាក់ចុះសេដ្ឋកិច្ច ។ ទោះបី ប្រទេសមានសេដ្ឋកិច្ចខ្លាំងដូចសឹង្ហបុរីក៏រងគ្រោះដែរ ហើយមិនសូវមានលទ្ធភាពដោះស្រាយទៀតផងពីព្រោះនៅក្នុងនេះ តំរូវការខាងក្រៅគឺជាកត្តាកំនត់វាសនាសេដ្ឋកិច្ច ។ នៅត្រីមាសទីពីរ សេដ្ឋកិច្ចសឹង្ហបុរីបានធ្លាក់ទៅក្នុងសភាពគួរឱ្យបារម្ភ ដោយGDP មានកំណើនអវិជ្ជមាន (-០,៩%) ហើយផលិតផលឧស្សាហកម្មបានធ្លាក់ចុះ ១៣% ក្នុងខែមិថុនា ។ ប្រទេសតៃវ៉ាន់ក៏ដូចគ្នាដែរ កំណើន GDP ធ្លាក់ដល់ -២,៤% ហើយផលិតកម្មឧស្សាហកម្មធ្លាក់ចុះ ១០% ក្នុងត្រីមាសទីពីរ នេះ។ ស្រដៀងគ្នាដែរចំពោះ ម៉ាឡេស៊ី និងកូរ៉េខាងត្បូង ដែលមានកំណើន GDP ចុះជិតនិងដល់ ០% ហើយសន្ទស្សន៏ផលិតកម្មឧស្សហកម្មក៏ធ្លាក់ចុះយ៉ាងខ្លាំង ។ ការធ្លាក់ចុះខ្លាំងនៃផលិតកម្មឧស្សហកម្មក្នុងប្រទេសអាស៊ីទាំងនេះ បណ្តាលមកពីការធ្លាក់ចុះនៃតំរូវការទំនិញអេឡិចត្រូនិក ពិសេសពីសហរដ្ឋអាមេរិក។ ដូច្នេះហើយ លទ្ធភាពនៃការរើបឡើងវិញនៃផ្នែកវិនិយោគនៅកម្ពុជា (ដែលពឹងលើកំណែនសេដ្ឋកិច្ចនៃប្រទេសអាស៊ីឯទៀតៗ) ហាក់ដូចជាមានតិចតួចណាស់។

## អតិផរណាក្នុងតំបន់

ទោះបីជាសេដ្ឋកិច្ចធ្លាក់ចុះខ្លាំង ប៉ុន្តែអតិផរណានៅអាមេរិក, អឺរ៉ុប និងជប៉ុន ជាទូទៅមិនមានការផ្លាស់ប្តូរទេនៅត្រីមាសទីពីរ ឆ្នាំ២០០១ បើធៀបនឹងត្រីមាសមុន ។ ហើយនៅអាស៊ីក៏ដូចគ្នាដែរ លើកលែងតែប្រទេសឥណ្ឌូនេស៊ីដែលមានបញ្ហានយោបាយក្នុងប្រទេស ។ ការធ្លាក់ចុះសេដ្ឋកិច្ចក្នុងពិភពលោក និងការកាត់បន្ថយអត្រាការប្រាក់ បានបង្ហាញពីស្ថិរភាពនៃអត្រាអតិផរណាក្នុងពិភពលោក។

## អត្រាប្តូរប្រាក់នៅលើទីផ្សារអន្តរជាតិ

# តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស

ភាពមិនប្រាកដនៃអនាគតសេដ្ឋកិច្ច បាននាំអោយមានការជ្រួលច្របល់តំលៃអត្រាប្តូរប្រាក់នៅទីផ្សារអន្តរជាតិ ។ នៅដើមខែកញ្ញានេះ ប្រាក់ដុល្លារប្តូរនៅអត្រា ១,១០អឺរ៉ូ និង ១១៨យ៉េន, គឺចុះពី ១,១៥អឺរ៉ូ និង ១២០យ៉េន កាលពីដើមខែ មិថុនា ។ ប្រាក់ដុល្លារក៏បានចុះថ្លៃធៀបនឹងរូបិយ បណ្ណ័អាស៊ីដទៃទៀតក្នុងរយៈពេលដូចគ្នា ដោយប្តូរបាន ៤០បាត និង ១,៧៤ ដុល្លារសឹង្ហបុរី នៅដើមខែកញ្ញានេះ គឺចុះពី ៤៦បាត និង ១,៨២ដុល្លារសឹង្ហបុរី កាលពីដើមខែមិថុនា។

## ថ្លៃផលិតផលក្នុងទីផ្សារអន្តរជាតិ

ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារអន្តរជាតិក្នុងត្រីមាសទីពីរ ឆ្នាំ២០០១ បង្ហាញសញ្ញាច្របូកច្របល់ ក្នុងនេះអង្ករលេខមួយនៅបាងកកបានធ្លាក់ថ្លៃយ៉ាងខ្លាំង គឺចុះដល់ ១៧០ដុល្លារ/តោន ដែលកាលពីត្រីមាសមុនលក់ថ្លៃ ១៨២ដុល្លារ/តោន។ សំណែកសៀងក៏ដូចគ្នាដែរ, តែថ្លៃកៅស៊ូ និងប្រេងឆាមានស្ថិរភាព។ ទោះបីសេដ្ឋកិច្ចធ្លាក់ចុះ ក៏ថ្លៃប្រេងឆៅនៅឱុយបែ នៅតែកើនឡើងបន្តិចដោយលក់ ២៥ដុល្លារ/ធុងនៅត្រីមាសទីពីរ គឺកើនពី ២៤ដុល្លារ/ធុងកាលពីត្រីមាសមុន។

### តារាង១. កំនើន GDP ពិតនៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ១៩៩៩-២០០១ (កំណើនភាគរយធៀបនឹងឆ្នាំមុន)

| | 1999 | | 2000 | | | | 2001 | | 2000 | 2001* |
|---|---|---|---|---|---|---|---|---|---|---|
| | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q1-Q4 | Q1-Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | - | - | - | - | - | - | - | - | 4.0 | 4.0 |
| ឥណ្ឌូនេស៊ី | 0.5 | 5.8 | 3.2 | 4.1 | 5.1 | 5.2 | 4.0 | 3.5 | 4.8 | 4.0 |
| ម៉ាឡេស៊ី | 8.2 | 10.6 | 11.9 | 8.7 | 7.7 | 6.6 | 3.2 | 0.5 | 8.6 | 3.0 |
| សិង្ហបុរី | 8.2 | 7.1 | 9.1 | 8.0 | 10.4 | 10.5 | 4.5 | -0.9 | 9.9 | 2.0 |
| ថៃ | 7.7 | 6.5 | 5.2 | 6.6 | 2.6 | 3.1 | 1.8 | - | 4.3 | 2.5 |
| វៀតណាម | - | - | - | - | - | - | - | - | 6.8 | 5.0 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| ចិន | 7.0 | 6.8 | 8.1 | 8.3 | 8.2 | 7.3 | 8.1 | 7.8 | 8.0 | 7.5 |
| ហុងកុង | 4.4 | 8.7 | 14.1 | 10.8 | 10.8 | 6.8 | 2.5 | | 10.5 | 3.0 |
| កូរ៉េខាងត្បូង | 13.4 | 13.0 | 12.7 | 9.7 | 9.3 | 4.6 | 3.7 | 2.7 | 8.8 | 3.0 |
| តៃវ៉ាន់ | 5.1 | 6.8 | 7.9 | 5.4 | 6.6 | 4.1 | 1.1 | -2.4 | 6.0 | 2.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| Euro-11 | 2.2 | 3.1 | 3.8 | 3.9 | 3.3 | 3.0 | 2.5 | - | 3.4 | 2.0 |
| ជប៉ុន | 1.0 | 0.0 | 2.4 | 1.1 | 0.5 | 2.5 | 0.2 | - | 1.7 | 0.5 |
| សហរដ្ឋអាមេរិក | 4.3 | 4.6 | 5.3 | 6.1 | 5.2 | 3.4 | 2.7 | 1.2 | 4.9 | 1.5 |

*ប្រភព: IMF, * វិបសអ ធ្វើការប៉ាន់ស្មានដោយផ្អែកលើការព្យាករណ៍របស់ IMF, ADB, និង World Bank*

### តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ១៩៩៩-២០០១ (កំណើនភាគរយធៀបនឹងឆ្នាំមុន)

| | 1999 | | 2000 | | | | 2001 | | 2000 | 2001* |
|---|---|---|---|---|---|---|---|---|---|---|
| | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q1-Q4 | Q1-Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 1.8 | 0.0 | 0.1 | -2.3 | -1.4 | 0.5 | -0.8 | 0.1 | -0.8 | 1.0 |
| ឥណ្ឌូនេស៊ី | 6.6 | 1.7 | -0.6 | 6.1 | 5.7 | 8.8 | 9.1 | 11.1 | 3.7 | 8.0 |
| ម៉ាឡេស៊ី | 2.3 | 2.1 | 1.5 | 1.4 | 1.5 | 1.7 | 1.5 | 1.6 | 1.5 | 1.6 |
| សិង្ហបុរី | 0.9 | 1.5 | 1.1 | 0.8 | 1.5 | 2.0 | 1.7 | 1.7 | 1.4 | 1.7 |
| ថៃ | -1.0 | 0.1 | 0.8 | 1.6 | 2.2 | 1.6 | 1.8 | 2.6 | 1.5 | 2.5 |
| វៀតណាម | - | - | -1.7 | -2.4 | -2.2 | -0.4 | -1.4 | -.0.8 | -1.7 | 0.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | -1.3 | -0.8 | 0.1 | 0.1 | 0.3 | 0.6 | 1.3 | 1.6 | 0.3 | 1.0 |
| ហុងកុង | -5.9 | -4.1 | -5.1 | -4.4 | -2.9 | -2.2 | -1.8 | -1.3 | -3.7 | -1.5 |
| កូរ៉េខាងត្បូង | 0.7 | 1.3 | 1.5 | 1.4 | 3.2 | 2.9 | 4.3 | 5.3 | 2.3 | 4.5 |
| តៃវ៉ាន់ | 0.6 | 0.1 | 1.1 | 1.4 | 1.0 | 2.0 | -1.0 | -0.0 | 1.4 | 1.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| Euro-11 | 1.1 | 1.5 | 2.0 | 2.1 | 2.5 | 2.7 | 2.5 | 3.1 | 2.3 | 2.5 |
| ជប៉ុន | 0.0 | -1.0 | -0.7 | -0.7 | -0.7 | -0.5 | -0.1 | -0.5 | -0.6 | -0.5 |
| សហរដ្ឋអាមេរិក | 2.3 | 2.6 | 3.2 | 3.3 | 3.5 | 3.4 | 3.4 | 3.4 | 3.4 | 3.5 |

*ប្រភព: IMF, * វិបសអ ធ្វើការប៉ាន់ស្មានដោយផ្អែកលើការព្យាករណ៍របស់ IMF, ADB, និង World Bank*

# តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស

## តារាង៣. អត្រាប្ដូរប្រាក់ធៀបនឹងដុល្លារ នៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ១៩៩៩-២០០១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1999 | | 2000 | | | | 2001 | | 2000 | 2001* |
|---|---|---|---|---|---|---|---|---|---|---|
| | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q1-Q4 | Q1-Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3,885 | 3,808 | 3,822 | 3,845 | 3,912 | 3,906 | 3,925 | 3,932 | 3,871 | 3,975 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 7,531 | 7,193 | 7,391 | 8,287 | 8,712 | 9,297 | 9,780 | 11,242 | 8,422 | 9,500 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 |
| សឹង្ហបុរី (ដុល្លារសឹង្ហបុរី) | 1.69 | 1.67 | 1.69 | 1.72 | 1.73 | 1.74 | 1.75 | 1.81 | 1.72 | 1.75 |
| ថៃ (បាត) | 38.3 | 38.8 | 37.4 | 38.6 | 40.9 | 43.3 | 43.2 | 45.4 | 40.1 | 44.0 |
| វៀតណាម (ដុង) | 13,960 | 14,009 | 14,053 | 14,075 | 14,120 | | 14,556 | 14,670 | 14,168 | 14,600 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ុន) | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 |
| ហុងកុង (ដុល្លារហុងកុង) | 7.76 | 7.77 | 7.78 | 7.78 | 7.79 | 7.79 | 7.80 | 7.80 | 7.79 | 7.80 |
| កូរ៉េខាងត្បូង (វ៉ុន) | 1,195 | 1,173 | 1,125 | 1,116 | 1,115 | 1,167 | 1,272 | 1,306 | 1,131 | 1,300 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.2 | 32.0 | 30.7 | 31.7 | 32.8 | 32.1 | 32.4 | 34.6 | 31.8 | 34.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១១ (អឺរ៉ូ) | 0.95 | 0.96 | 1.01 | 1.07 | 1.10 | 1.15 | 1.08 | 1.15 | 1.09 | 1.10 |
| ជប៉ុន (យ៉េន) | 114 | 106 | 107 | 107 | 108 | 110 | 118 | 123 | 108 | 120 |

*ប្រភព:* IMF, * *វិបសអ ធ្វើការប៉ាន់ស្មានដោយផ្អែកលើការព្យាករណ៍របស់* IMF, ADB, *និង* World Bank

## តារាង៤. ថ្លៃផលិតផលនៅលើទីផ្សារពិភពលោក ពីឆ្នាំ១៩៩៩-២០០១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1999 | | 2000 | | | | 2001 | | 2000 | 2001* |
|---|---|---|---|---|---|---|---|---|---|---|
| | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q1-Q4 | Q1-Q4 |
| ឈើមូលប្រភេទរឹង - ម៉ាឡេស៊ី($/ម៣) | 196 | 199 | 189.4 | 192.7 | 192.1 | 186.0 | 171.0 | 163.8 | 190.1 | 170 |
| ឈើអារប្រភេទរឹង - ម៉ាឡេស៊ី ($/ម៣) | 632 | 643 | 641.0 | 633.2 | 592.7 | 529.8 | 507.0 | 492.2 | 599.2 | 500 |
| កៅស៊ូ - ម៉ាឡេស៊ី ($/តោន) | 573 | 689 | 729.9 | 744.4 | 712.2 | 696.6 | 632.0 | 628.9 | 720.7 | 630 |
| អង្ករ - បាងកក ($/តោន) | 247 | 225 | 239.8 | 204.5 | 185.4 | 185.1 | 182.0 | 164.7 | 203.7 | 180 |
| សណ្ដែកសៀង - សហរដ្ឋ ($/តោន) | 196 | 200 | 212.3 | 223.0 | 200.7 | 209.0 | 202.0 | 186.7 | 211.3 | 190 |
| ប្រេងកាតឆៅ Dubai ($/ធុង) | 20 | 23 | 24.3 | 25.0 | 27.6 | 27.5 | 24.0 | 25.1 | 26.1 | 25 |
| មាស - LONDON ($/fine ounce) | 259 | 296 | 290.2 | 280.2 | 276.5 | 269.2 | 264.0 | 266.4 | 279.0 | 265 |

*ប្រភព:* IMF * *វិបសអ ធ្វើការប៉ាន់ស្មានដោយផ្អែកលើការព្យាករណ៍របស់* IMF, ADB, *និង* World Bank

# តាមដានសេដ្ឋកិច្ច —— ស្ថានភាពក្នុងប្រទេស

ទោះជាសេដ្ឋកិច្ចនៅលើពិភពលោកបានធ្លាក់ចុះ ប៉ុន្តែសេដ្ឋកិច្ចកម្ពុជានៅតែបន្តមានសញ្ញាវិជ្ជមាននៅក្នុងឆមាសទីមួយ ឆ្នាំ២០០១ ។ ក្នុងនេះផលិតកម្មវិស័យកាត់ដេរអាចរក្សាលំនឹងបាន, វិស័យទេសចរណ៍បានកើនសកម្មភាព ចំណែកឯផ្នែកសាងសង់ និងផ្នែកកសិកម្ម បានកើនបន្តិចបន្តួច ។ តាមការប៉ាន់ស្មានរបស់ វិបសអ និងធនាគារអភិវឌ្ឍន៍អាស៊ី GDP នឹងកើនឡើងតែ ៤%ទេ ក្នុងឆ្នាំ២០០១ ។ រូបិយវត្ថុបន្តមានលំនឹងដោយក្នុងរយៈពេលនេះអត្រា អតិផរណា (ពត៌មានពីវិទ្យាស្ថានជាតិស្ថិតិ) មានកំរិត ០,១% និងអត្រាប្តូរប្រាក់ជាមធ្យម ៣.៩២០រៀលក្នុងមួយដុល្លារ ។ ប្រាក់រៀលមានភាពរឹងប៉ឹងទល់នឹងប្រាក់បាតថៃ ព្រមទាំងប្រាក់ដុងវៀតណាម ។ គេរំពឹងថា រដ្ឋាភិបាលនឹងបន្តនយោបាយរូបិយវត្ថុតឹងរឹងរបស់ខ្លួន និងរក្សាតុល្យភាពសារពើពន្ធ ។ ប៉ុន្តែលំហូរចូលនូវមូលធនបរទេសនៅតែមានកំរិតទាប ដោយសារការថយចុះវិនិយោគឯកជនដែលកើតមានតាំងពីឆ្នាំ១៩៩៩ មក ។ អ្នកវិនិយោគមួយចំនួនបានត្អូញត្អែរថា ឧស្សាហកម្មក្នុងស្រុកបានរងគ្រោះដោយសារមានការប្រកួតប្រជែងមិនត្រឹមត្រូវ និងកង្វះការជួយការពារពីសំណាក់រដ្ឋាភិបាល ។ ដូច្នេះវាជាបញ្ហាប្រឈមមួយយ៉ាងធំ ក្នុងការបង្កើនទំនុកចិត្តរបស់អ្នកវិនិយោគទុនឡើងវិញ ។

## សកម្មភាពសេដ្ឋកិច្ច

កង្វល់នៃការខ្វះខាតអង្ករ បន្ទាប់ពីការខូចខាតយ៉ាងធ្ងន់ដោយសារទឹកជំនន់ឆ្នាំ២០០០ មិនបានកើតមានដូចការគិតទុកទេ ។ វាហាក់ដូចជាការសង្គ្រោះមួយយ៉ាងល្អ ដែលការប្រមូលផលស្រូវប្រាំងក្នុងឆ្នាំ២០០១ បានទទួលទិន្នផលខ្ពស់ហួសពីការស្មាន ។ ប៉ុន្តែទឹកជំនន់ទន្លេមេគង្គក្នុងឆ្នាំ២០០១ ហាក់ដូចជាធំធេងដែរ ហើយកំពុងគំរាមកំហែងដល់ស្រូវដែលបានស្ទូងហើយ ។ តាមពត៌មានពីគណៈកម្មាការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មកដល់ត្រឹមថ្ងៃទី ២៩ សីហា ២០០១ ក្នុងចំណោមខេត្តទាំង ២៤ មាន ១០ខេត្តត្រូវបានប៉ះពាល់ដោយទឹកជំនន់ (ខេត្តប្រាំរងគ្រោះធ្ងន់ធ្ងរ) ដែលបានធ្វើអោយបាត់បង់ជីវិតមនុស្ស ៣៥នាក់ និងខូចខាតស្រូវ ៨៦ពាន់ហិកតា ។

ផលិតផលសំលៀកបំពាក់ដែលជាទំនិញនាំចេញចំបងរបស់កម្ពុជា ដូចជាមិនជឿនលឿនទៅមុខសោះក្នុងរយៈពេលបីត្រីមាសចុងក្រោយនេះ ។ ទោះជាយ៉ាងនេះក៏ដោយ តាមតួលេខក្រសួងពាណិជ្ជកម្ម ការនាំចេញក្នុងឆមាសទីមួយ ឆ្នាំ២០០១ មានទឹកប្រាក់សរុប ៥១៣,៨ លានដុល្លារ (កើន ២២% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន) ហើយ ៧៤% នៃចំនួននេះនាំចេញ ទៅសហរដ្ឋអាមេរិក និង ២៤%ទៅទីផ្សារអឺរ៉ុប ។ ទោះបីមានកង្វល់ពីការធ្លាក់ចុះនៅឆ្នាំខាងមុខក៏ដោយ ក៏វិស័យឧស្សាហកម្មកាត់ដេរនៅតែបន្តកើនឡើង និងនៅតែជាវិស័យនាំចេញចំបងគេ ។ ដើម្បីទប់ស្កាត់ការធ្លាក់ចុះ ប្រទេស កម្ពុជាត្រូវតែចូលក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO) យ៉ាងឆាប់តាមអាចធ្វើបាន ដើម្បីអាចពង្រីកទីផ្សាររបស់ខ្លួនទៅប្រទេសផ្សេងៗទៀត នៅលើពិភពលោក (ការដាក់កូតាសំរាប់នាំចេញសំលៀកបំពាក់ នឹងត្រូវលុបចោលទាំងស្រុងនៅឆ្នាំ២០០៥ ចំពោះសមាជិក WTO ទាំងអស់) ។ ថ្វីបើក្នុងពីរបីឆ្នាំចុងក្រោយនេះ កម្ពុជាបាននាំចេញសំលៀកបំពាក់ច្រើនទៅសហរដ្ឋអាមេរិក និងទីផ្សារអឺរ៉ុបក្រោមលក្ខខណ្ឌអនុគ្រោះពិសេសក៏ដោយ ក៏ប៉ុន្តែលទ្ធភាពពង្រីកទីផ្សារសំរាប់ផលិតផលកាត់ដេររបស់ខ្លួននៅថ្ងៃអនាគតវាអាស្រ័យលើតម្លៃថោកមានលក្ខណៈប្រកួតប្រជែង ។ ហើយក្នុងការពង្រីកទីផ្សារទៅកាន់បណ្តាប្រទេសអាស៊ានជាដៃគូដែលមានប្រជាជនជាង ៥០០ លាននាក់នោះ កម្ពុជាត្រូវតែមានយុទ្ធសាស្ត្រដ៏ខ្លាំងក្លាថែមទៀត ។ មួយចំណែកទៀត កម្ពុជាហាក់ដូចជានឹងជួបការលំបាកច្រើន ក្នុងការធ្វើពាណិជ្ជកម្មក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន AFTA ។

វិស័យទេសចរណ៍បានបន្តលូតលាស់ក្នុងឆមាសទីមួយ ឆ្នាំ២០០១ ហើយសង្ឃឹមថានឹងមានអនាគតល្អ ។ តាមទិន្នន័យ របស់ក្រសួងទេសចរណ៍ និងក្រសួងមហាផ្ទៃ ភ្ញៀវទេសចរបរទេសមកដល់កម្ពុជាតាមជើងយន្តហោះក្នុងឆមាសទីមួយ ឆ្នាំនេះ មានសរុប ២៣៥.០០០នាក់ ក្នុងនេះ ៧២%ចូលតាមព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង និង ២៨%ចូលតាមជើងហោះហើរអន្តរជាតិផ្ទាល់ទៅខេត្តសៀមរាប ។ ចំនួនទេសចរសរុបមកតាមយន្តហោះបានកើន ២៤%ធៀបនឹងឆមាសទីមួយ ឆ្នាំ២០០០ ។ សមាមាត្រនៃទេសចរដែលចូលមកតាមព្រលានយន្តហោះសៀមរាប នៅតែបន្តកើនឡើងយ៉ាងខ្លាំង (៨៩%ខ្ពស់ជាងឆមាសទីមួយ ឆ្នាំ២០០០) បើធៀបនឹងភ្ញៀវទេសចរមកតាមភ្នំពេញ ។ ជនជាតិ ជប៉ុន និងអាមេរិកាំង មានច្រើនជាងគេក្នុងចំណោមទេសចរមកទស្សនាអង្គរវត្ត ។ ម្យ៉ាងវិញទៀត ក្រសួងទេសចរបានអោយដឹងដែរថា ចំនួនភ្ញៀវទេសចរបរទេសចូលតាមផ្លូវគោក និងផ្លូវទឹក ក៏កើនឡើងសន្ធឹកដែរ ។ ក្នុងឆមាសទីមួយ ឆ្នាំ២០០១ ទេសចរប្រភេទនេះមានសរុប ២៩៨.០០០នាក់ គឺកើន ៣៣% ខ្ពស់ជាងរយៈពេលដូចគ្នាក្នុងឆ្នាំ២០០០ ។

ការធ្លាក់ចុះវិនិយោគផ្ទាល់ពីបរទេស នៅតែបន្តដាក់សម្ពាធលើវិស័យសំណង់ក្នុងទីក្រុងភ្នំពេញ ទោះបីមានសញ្ញាខ្លះៗ នៃកំណើនឡើងវិញក្នុងផ្នែកនេះនៅ ខែមេសា-មិថុនា ក៏ដោយ ។ ក្នុងឆមាសទីមួយ ឆ្នាំ២០០១ អ្នកដាក់ពាក្យសុំសាងសង់មានចំនួនសរុប ទាបធៀបជាងក្នុងកំឡុងពេលដូចគ្នាកាល ពីឆ្នាំមុន ។ តាមទិន្នន័យរបស់នាយកដ្ឋានសាងសង់ និងសូរិយោដី ទីក្រុង ភ្នំពេញ, ក្នុងឆមាសទីមួយ ឆ្នាំនេះ មានការអនុញ្ញាតអោយសាងសង់ ៣១៦ គំរោង ឯកាលពីឆមាសទីមួយ ឆ្នាំ២០០០ មានរហូតដល់ ៤៥០គំរោង ឯណោះ ។ នៅពេលវិនិយោគឯកជននៅតែមិនសូវមានសកម្មភាព គេពិបាកនឹងទស្សទាយថា តើវិស័យសាងសង់នឹងរើបឡើងវិញពេញលេញឬទេក្នុងពេលដ៏ខ្លីខាងមុខ ។

## អតិផរណា និង អត្រាប្តូរប្រាក់

នៅត្រីមាសទីពីរ ឆ្នាំ២០០១ អតិផរណានៅភ្នំពេញបានកើនឡើងបន្តិច ដោយសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់មានកំណើន ០,១% ។ ក្នុងរយៈពេលដូចគ្នាសន្ទស្សន៍ថ្លៃថាមពលកើន ១,៥% ចំណែកឯសន្ទស្សន៍ថ្លៃម្ហូបអាហារនៅតែមានអត្រាក្រោមសូន្យ (-២,២%) ។ តាមអង្កេតរបស់ វិបសអ អត្រាអតិផរណានៅតាមខេត្តបានថយចុះនៅត្រឹម ១,៣% (វាមានកំរិត ៤,៨%កាលពីត្រីមាសទីមួយ ឆ្នាំ២០០១) ។ ប្រាក់រៀលជាទូទៅមានលំនឹងល្អជាមួយប្រ

# តាមដានសេដ្ឋកិច្ច —— ស្ថានភាពក្នុងប្រទេស

ាក់ដុល្លារ (អត្រាប្តូរជាមធ្យម ៣.៩២៨រៀល/ដុល្លារ នៅក្នុងរយៈពេល ៦ខែដើមឆ្នាំ២០០១) និងបន្តឡើងថ្លៃធៀបនឹងប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម ។ ប្រាក់រៀលមានលំនឹងល្អចាប់តាំងពីការប្រកាសអោយប្រើ ច្បាប់ថ្មីស្តីពីហិរញ្ញវត្ថុនិងធនាគារ នៅដើមឆ្នាំ២០០១ ។

ថ្លៃប្រេងសាំងនៅភ្នំពេញបន្តមានលំនឹងក្នុងរយៈពេល ៦ខែជាប់គ្នា ដោយលក់ក្នុងថ្លៃ ២.១០០រៀល/លីត្រ, ឯប្រេងម៉ាស៊ូតបានឡើងថ្លៃបន្តិចនៅត្រីមាសទីពីរនេះ ដោយលក់ក្នុងថ្លៃ ១.៩៣៣រៀល/លីត្រ ។ ទោះបីជាមាសបានឡើងថ្លៃបន្តិចនៅទីផ្សារឡុងដុងក៏ដោយ ប៉ុន្តែនៅក្រុងភ្នំពេញមិនឃើញមានការប្រែប្រួលទេនៅពីរត្រីមាសចុងក្រោយនេះ គឺវាលក់នៅក្នុងថ្លៃ ៣២ដុល្លារ/ជី ។

## ស្ថានភាពក្រីក្រ ~ ប្រាក់ចំណូលរបស់ពលករ

ការលូតលាស់អាចកាត់បន្ថយភាពក្រីក្រតាមរយៈការបង្កើតការងារ និងប្រាក់ចំណូល ហើយការលូតលាស់នៃផ្នែកដែលប្រើកំលាំងពលកម្មច្រើនអាចជួយកាត់បន្ថយភាពក្រីក្រកាន់តែរហ័សថែមទៀត ។ ដូច្នេះគោលនយោបាយលើកទឹកចិត្តដល់ឧស្សាហកម្មប្រើកំលាំងពលកម្មច្រើន (ឧស្សាហកម្មកាត់ដេរសំលៀកបំពាក់, ស្បែកជើង និងឧស្សាហកម្មកែច្នៃម្ហូបអាហារ) គឺជាវិធានការដ៏ល្អសំរាប់ជួយដល់អ្នកក្រីក្រ ។ តាមការប៉ាន់ស្មាន មានប្រជាជនកម្ពុជាប្រមាណ ៣៦% រស់នៅក្រោមបន្ទាត់ក្រីក្រ ហើយភាពក្រីក្រនៅជនបទមានកំរិតខ្ពស់ជាងនៅតំបន់ទីក្រុង ។ មានប្រជាជនជាច្រើនបានធ្វើចំណាកស្រុកពីជនបទមកភ្នំពេញ ដោយសង្ឃឹមថា មានការងារល្អជាង ។ អង្កេតពលករងាយរងគ្រោះធ្វើដោយ វបសអ ក្នុងខែសីហា ឆ្នាំ២០០១ បានបង្ហាញអោយដឹងថា ២៦% នៃកម្មករចំណាកស្រុកមករកការធ្វើនៅភ្នំពេញ សុទ្ធតែបានខ្ចីប្រាក់គេដោយមានការប្រាក់ ឬបានខ្ចីប្រាក់ពីសាច់ញាតិ ។ ការអង្កេតបានបង្ហាញដែរថា ក្នុងខែសីហា ឆ្នាំ២០០១ ចំណូលប្រចាំថ្ងៃរបស់អ្នកធាក់ស៊ីក្លូ និងអ្នករត់ម៉ូតូឌុប បានធ្លាក់ចុះបន្តិចធៀបនឹងខែសីហាឆ្នាំមុន ។ អ្នកត្រូវប៉ះពាល់ខ្លាំងជាងគេគឺ កម្មករលីសែង, អ្នករើសអេតចាយ, កម្មករសំណង់មានជំនាញ និងគ្មានជំនាញ, ដោយចំណូលប្រចាំថ្ងៃរបស់ពួកគេធ្លាក់ចុះយ៉ាងខ្លាំងធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន (តារាង៥) ។

ចំណូលប្រចាំថ្ងៃរបស់អ្នករើសអេតចាយបានធ្លាក់ចុះ ៣៦% ពីខែសីហា ២០០០ ដល់ខែសីហា ២០០១ ដោយមូលហេតុ មានកំណើនជនធ្វើចំណាកស្រុកដែលភាគច្រើនមកពីខេត្តស្វាយរៀង និងព្រៃវែង និងដែលមកធ្វើជាអ្នករើសសំរាមដែរ ។ ដើម្បីដោះស្រាយតំរូវការចាំបាច់ខាងអាហារ និងថ្នាំពេទ្យខណៈពេលដែលចំណូលកំពុងធ្លាក់ចុះ, ៣៦%នៃអ្នករើសអេតចាយបានរាយការណ៍ថា ខ្លួនបានខ្ចីបុលពីឈ្មួញកណ្តាល (អ្នកទិញអេតចាយ) ដោយត្រូវបង់ការប្រាក់ប្រចាំខែ ពី៥-២៥% ។ ចំណូលប្រចាំថ្ងៃរបស់កម្មករលីសែងបានធ្លាក់ ២០% ធៀបនឹងខែសីហា ឆ្នាំមុន ។ កម្មករលីសែង ៨០នាក់ដែលបានឆ្លើយសំភាសន៍បានប្រាប់ថា ចំនួនកម្មករបានកើនឡើង ពិសេសកម្មករលីសែងវ័យក្មេង ហើយស្ទើរតែទាំងអស់ជាអ្នកមកពីខេត្តនានា ។ ក្នុងចំណោមកម្មករងាយរងគ្រោះប្រភេទផ្សេងទៀត កម្មករសំណង់មានជំនាញ និងគ្មានជំនាញ មានចំណូលប្រចាំថ្ងៃធ្លាក់ចុះ ១៧% និង ៣២% រៀងៗគ្នា ។ ការថយចុះវិនិយោគឯកជននិងការសាងសង់ បានធ្វើអោយប្រាក់ចំណូលក្រុមនេះធ្លាក់ចុះ ។ ខុសគ្នាពីក្រុមខាងលើ ចំណូលប្រចាំថ្ងៃរបស់កម្មករកាត់ដេរបានកើន ដល់ ៩.១៦៥ រៀល ក្នុងខែសីហា ឆ្នាំ២០០១ ដែលជាកំណើនខ្ពស់បំផុតតាំងពីចាប់ធ្វើអង្កេតក្នុងខែកុម្ភៈ ឆ្នាំ២០០០ មក ។ ទោះជាចំណូលកើនឡើង ក៏មានកម្មករមួយចំនួនប្រាថ្នាចង់ប្តូរការងាររបស់ខ្លួន ដោយមូលហេតុធ្វើការថែមម៉ោងច្រើនហួសប្រមាណ (១០-១២ ម៉ោងក្នុងមួយថ្ងៃ) ។ ចំណាយប្រចាំថ្ងៃជាមធ្យមរបស់កម្មករកាត់ដេរគឺប្រហែល ៣.០០០ រៀល (រាប់បញ្ចូលទាំងចំណាយលើអាហារ ឈ្នួលផ្ទះ និងគ្រឿងសំអាង) ហើយប្រាក់ដែលសន្សំបានទាំងអស់ គេផ្ញើទៅផ្គត់ផ្គង់គ្រួសារនៅឯជនបទ ។

## ការវិវត្តន៍នៃរូបិយវត្ថុ

សភាពការណ៍រូបិយវត្ថុបន្តមានលំនឹង ដោយរដ្ឋាភិបាលបន្តអនុវត្តគោលនយោបាយការគ្រប់គ្រងអត្រាប្តូរប្រាក់ប្រែប្រួល និងប្រព័ន្ធធនាគារពីរថ្នាក់របស់ខ្លួន ។ ការពង្រឹងគោលនយោបាយរូបិយវត្ថុនៅតែជាយុទ្ធសាស្ត្រគន្លឹះ សំរាប់ធ្វើអោយមានលំនឹងសេដ្ឋកិច្ច ។ តាមតួលេខផ្សព្វផ្សាយដោយ ធនាគារជាតិនៃកម្ពុជា នៅត្រីមាសទីពីរ ឆ្នាំ២០០១ ប្រាក់បញ្ញើរបស់រដ្ឋាភិបាលនៅធនាគារជាតិកើនឡើង ៤% បើធៀបនឹងត្រីមាសទីមួយ ។ម្យ៉ាងវិញទៀត ចលនាសាច់ប្រាក់រៀលបានស្ថិតនៅក្រោមការគ្រប់គ្រងល្អៈ សាច់ប្រាក់រៀលដែលបានបញ្ចេញទៅទីផ្សារ មានសរុប ៥១០ពាន់លានរៀល (តិចជាងត្រីមាសទីមួយ ប្រមាណ ២%) ។ ជាមួយគ្នានេះ ប្រាក់បញ្ញើរូបិយប័ណ្ណបរទេសបានកើនដល់ ១.៣៩០ពាន់លានរៀល គឺកើន ៧% បើធៀបនឹងត្រីមាសមុន ។ ប៉ុន្តែមកទល់ពេលនេះ មិនទាន់មានតួលេខផ្លូវការស្តីពីចរាចររូបិយប័ណ្ណបរទេសនៅក្រៅប្រព័ន្ធធនាគារនៅឡើយទេ ដោយសារសេដ្ឋកិច្ចប្រទេសកម្ពុជាបានប្រើប្រាស់ប្រាក់ដុល្លារយ៉ាងទូលំទូលាយ ហើយប្រជាជន




មួយចំនួនធំដែលមិនទាន់ជឿជាក់លើប្រព័ន្ធធនាគារ បានរក្សាទុកប្រាក់នេះនៅក្រៅធនាគារ ។

បើតាមអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ[១] នៅចុងខែមេសា ឆ្នាំ២០០១ ប្រទេសកម្ពុជាមានប្រាក់ទុនបំរុងបរទេសសរុប ៥១០លានដុល្លារ ។ ប្រ

# តាមដានសេដ្ឋកិច្ច —— ស្ថានភាពក្នុងប្រទេស

ាក់បំរុងនេះកើនឡើងខ្ពស់ជាងឆ្នាំកន្លងទៅបន្តិច ហើយមានកំរិត ស្មើនឹង ២,៧ខែ នៃតំលៃនាំចូលទំនិញនិងសេវារបស់ប្រទេសកម្ពុជា ។

**ហិរញ្ញវត្ថុសាធារណៈ**

ការអនុវត្តន៍ថវិការរបស់កម្ពុជាមានដំណើរការល្អក្នុងឆមាសទីមួយ ឆ្នាំ ២00១ ។ តាមតួលេខក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅ ៦ខែដើមឆ្នាំ២00១ ចំណូលក្នុងស្រុកសរុបរបស់រដ្ឋាភិបាលមានចំនួន ៧៦៦ពាន់លានរៀល គឺបានតិចជាងគោលដៅក្នុងផែនការ ៤% ប៉ុន្តែវាកើន ៨%ខ្ពស់ជាងកំរិតដែលទទួលបានក្នុងរយៈពេល ៦ខែដើមឆ្នាំ ២000 ។ ការពង្រឹងរដ្ឋបាលខាងពន្ធដារ និងខាងគយ ដែលជាចំណែកមួយនៃកំណែទំរង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានជំរុញអោយមានកំណើន ចំណូលពន្ធ និងចំណូលមិនមែនពន្ធ ក្នុងរយៈពេលនេះ ។ ចំណូលពន្ធ និងមិនមែនពន្ធបានកើនឡើង ៦% និង ១២% រៀងៗគ្នា បើធៀបនឹងឆមាសទីមួយ ឆ្នាំ២000 ។ ហើយកំណើននេះវាកើតចេញពីលទ្ធផលកាន់តែល្អប្រសើរក្នុងការប្រមូលអាករលើតំលៃបន្ថែម (VAT) ពន្ធលើប្រាក់បៀវត្ស, ពន្ធលើប្រាក់ចំណេញ និងអាករលើផលរបរ ។ គោលដៅសារពើពន្ធរបស់រដ្ឋាភិបាលក្នុង ឆ្នាំ២00១ គឺបង្កើនចំណូលឱ្យបាន ១២% នៃ GDP (១១,៥%នៃ GDP ក្នុងឆ្នាំ២000) ។ ដើម្បីសំរេចគោលដៅនេះ រដ្ឋាភិបាលនឹងដាក់អនុវត្តវិធានការប្រឆាំងអំពើរត់ពន្ធខ្លះទៀត ដូចជាការប្រើប្រព័ន្ធតែមដើម្បីយកពន្ធលើបារី និងការយកពន្ធ VAT នៅពេលដែលប្រេងម៉ាស៊ូតត្រូវបានលក់ចេញ ។[២]

ចំណាយសរុបក្នុងឆមាសទី១ ឆ្នាំ២00១ មានចំនួន ៩៧0ពាន់លានរៀល ដែលតិចជាងគោលដៅក្នុងផែនការ ១0% ។ ប៉ុន្តែរដ្ឋាភិបាលនៅតែតាំងចិត្តបង្កើនការចំណាយលើវិស័យជាអាទិភាពដូចជា អប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ និងកសិកម្ម ហើយកាត់បន្ថយចំណាយខាងសន្តិសុខ និងយោធា ។ ក្នុងឆមាសទីមួយ ឆ្នាំ២00១ ចំណាយលើអប់រំ និងសុខាភិបាលកើន ១១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំមុន ប៉ុន្តែចំណាយយោធាបានថយចុះ ២៦% ។ ក្នុងឆ្នាំ ២00១ ចំណាយសរុបរបស់រដ្ឋាភិបាលរំពឹងថានឹងមានចំនួន ១៧%នៃ GDP ។

**វិនិយោគទុន និង ទីផ្សារពលកម្ម**

កម្មវិធីឯកជនភាវូបនីយកម្មបានចាប់ផ្តើមនៅកម្ពុជាក្នុងដើមទសវត្សរ៍ ១៩៩0 ។ វាជាកន្សោមកំណែទំរង់ដ៏ធំមួយ ដែលផ្តោតលើការកសាងឡើងវិញ និងការកែលំអហេដ្ឋារចនាសម្ព័ន្ធខាងសេដ្ឋកិច្ច និងនយោបាយ តាមរយៈការទាក់ទាញវិនិយោគឯកជន និងវិនិយោគផ្ទាល់ពីបរទេស (FDI) ។ នៅក្នុងបរិដ្ឋានថ្មីនេះ ក្រុមហ៊ុនបរទេសជាច្រើនបានចូលមកវិនិយោគនៅកម្ពុជា ដែលមានតាំងពីវិស័យឧស្សាហកម្មប្រើទុនធំ (ទូរគមនាគមន៍ និងទេសចរណ៍) រហូតដល់វិស័យដែលប្រើកំលាំងពលកម្មច្រើន (ឧស្សាហកម្មកាត់ដេរ និងស្បែកជើង) ។ ជាលទ្ធផល ទុនបរទេសដែលហូរចូលមកកម្ពុជាបានកើនឡើងយ៉ាងខ្លាំងពីឆ្នាំ១៩៩៤ ដល់ ១៩៩៨ ។ តែជាអកុសល កំលាំងរបស់កម្ពុជាដើម្បីទាក់ទាញ FDI បានធ្លាក់ចុះក្នុងឆ្នាំ១៩៩៩ និងធ្លាក់កាន់តែធ្ងន់ធ្ងរថែមទៀត នៅឆ្នាំ២000 ។ តាមពត៌មានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC), វិនិយោគសរុបគិតជាទ្រព្យសកម្មជាប់លាប់ដែល CDC បានអនុម័តនៅឆ្នាំ២000 មានកំរិតទាបជាងឆ្នាំ១៩៩៩ ដល់ទៅ ៤៣% ហើយក្នុងឆ្នាំ២00១ នេះ នៅមិនទាន់ឃើញមានសញ្ញានៃការរើបឡើងវិញទេ ។ នៅឆមាសទី១ឆ្នាំ ២00១ CDC បានអនុម័តគំរោងវិនិយោគថ្មីចំនួន ១៧ គំរោង និងផ្តល់ការយល់ព្រមលើការពង្រីកគំរោងចាស់ចំនួន ៧គំរោង, ដែលមានតំលៃសរុបជាទ្រព្យសកម្មជាប់លាប់ ៣៩,២លានដុល្លារ ។ បើធៀបនឹងឆមាសទីមួយ ឆ្នាំ២000, ចំនួនគំរោងវិនិយោគធ្លាក់ចុះ ៥១% ហើយតំលៃជាទ្រព្យសកម្មធ្លាក់ចុះ ៦៥% ។ គេមានហេតុផលទាំងខាងក្រៅ និងខាងក្នុងដែលនាំអោយ FDI ធ្លាក់ចុះនៅកម្ពុជា ។ ហេតុផលខាងក្រៅគឺ ការធ្លាក់ចុះសេដ្ឋកិច្ចក្នុងទូទាំងពិភពលោក និងបញ្ហាសេដ្ឋកិច្ចនៃប្រទេសក្នុងតំបន់ ។ ហេតុផលខាងក្នុងគឺ ពុំមានការផ្សព្វផ្សាយខ្លាំងក្លាដល់អ្នកវិនិយោគទុន, ចំណាយប្រតិបត្តិការខ្ពស់, ផលិតភាពទាប, ច្បាប់ពាណិជ្ជកម្មទន់ខ្សោយ, និងពុំមានការធានាការពារគ្រប់គ្រាន់ដល់អ្នកវិនិយោគពីសំណាក់រដ្ឋាភិបាល ។ កិច្ចការពារដល់ឧស្សាហកម្មក្មេងខ្ចីក្នុងស្រុក ដើរតួសំខាន់សំរាប់ជួយទ្រទ្រង់ផលិតករក្នុងស្រុកអោយរស់បាន ។ ក្នុងនេះមានសហគ្រិនមួយចំនួនបានត្អូញត្អែរពីការចំណាយរដ្ឋបាលខ្ពស់ និងការប្រកួតប្រជែងមិនស្មើភាពគ្នារវាងទំនិញផលិតក្នុងស្រុកដែលត្រូវបង់ពន្ធ និងទំនិញរត់ពន្ធដែលមិនបង់ពន្ធ ។ ទំនិញរត់ពន្ធថែមទាំងធ្វើអោយបាត់បង់ ចំណូលរដ្ឋាភិបាលថែមទៀត ។ អ្នកវិនិយោគ ក្នុងស្រុក និងក្រៅស្រុកខ្លះ ដែលធ្លាប់ជួបប្រទះបរិស្ថានមិនអំណោយផល បែបនេះ គេមានការព្រួយបារម្ភជាខ្លាំងពីលទ្ធភាពអាចរស់ជីវិតបាននៃវិនិយោគរបស់ពួកគេនៅថ្ងៃអនាគត ។ ចំណែកអ្នកចង់មកវិនិយោគថ្មីៗទៀតវិញ ពួកគេអាចប្រកាន់តំរិយាបទ *"រង់ចាំមើលសិន"* ចំពោះការវិនិយោគទុននៅកម្ពុជា ។

**ជំនួយបរទេស និង បំណុលក្រៅប្រទេស**

តាមរបាយការណ៍របស់រដ្ឋាភិបាល នៅក្នុងការប្រជុំពិគ្រោះយោបល់ (CG Meeting) ដែលធ្វើនៅទីក្រុងតូក្យូកាលពីថ្ងៃទី ១២-១៣ ខែមិថុនាឆ្នាំ ២00១, សហគមន៍អន្តរជាតិ បានសន្យាផ្តល់ជំនួយ ៦១៥លានដុល្លារដល់ប្រទេសកម្ពុជាសំរាប់ឆ្នាំ២00១ ក្នុងនេះ ១១៨លានដុល្លារជារបស់ជប៉ុន, ៤0លានដុល្លារជារបស់សហរដ្ឋអាមេរិក, ២១លានដុល្លារជារបស់កូរ៉េខាង ត្បូង, ៥៥លានដុល្លារជារបស់អង្គការ NGOs និងសល់ពីនេះជារបស់អ្នកផ្តល់ជំនួយឯទៀតៗ ។ ចំណុចគួរកត់សំគាល់គឺ ជប៉ុនបានបង្កើនជំនួយជាមធ្យម ប្រចាំឆ្នាំរបស់ខ្លួនពី ១00លានដុល្លារ ដល់ ១១៨លានដុល្លារក្នុងឆ្នាំនេះ (មាន អំណោយ និងប្រាក់កំចីសម្បទាន), សហរដ្ឋអាមេរិកបានសន្យាច្រើនជាងឆ្នាំ កន្លងទៅ ២ដង, ហើយរដ្ឋាភិបាលកូរ៉េខាងត្បូងបានសន្យានូវចំនួនដ៏ខ្ពស់មួយ (កាលពីឆ្នាំ២000 សន្យាតែកន្លះលានដុល្លារប៉ុណ្ណោះ) ។ ផ្ទុយទៅវិញ សហគមន៍អឺរ៉ុប (រួមទាំងរដ្ឋាភិបាលអាល្លឺម៉ង់ផង) ដែលធ្លាប់ជាអ្នកផ្តល់ជំនួយសំខាន់ដល់កម្ពុជា គឺពុំបានប្រកាសការសន្យារបស់ខ្លួននៅក្នុងអង្គប្រជុំទេ ។ទោះជាយ៉ាងនេះក្តី ជំនួយសន្យាសរុបរបស់សហគមន៍អន្តរជាតិក្នុងឆ្នាំ២00១ មានចំនួន

# តាមដានសេដ្ឋកិច្ច —— សន្ទស្សន៍សេដ្ឋកិច្ច

## តារាង១. កម្ពុជា: សន្ទស្សន៍ម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ពីឆ្នាំ១៩៩៣-២000

| | 1993 | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000E |
|---|---|---|---|---|---|---|---|---|
| ផសស ថ្លៃបច្ចុប្បន្ន (ពាន់លានរៀល) | 6,080 | 6,220 | 7,200 | 8,330 | 9,150 | 10,600 | 11,640 | 12,000 |
| ផសស តំលៃបច្ចុប្បន្ន (លានដុល្លារ) | 2,160 | 2,420 | 2,925 | 3,155 | 3,050 | 2,790 | 3,050 | 3,110 |
| ផសស ក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំ (ដុល្លារ) | 225 | 245 | 284 | 295 | 276 | 244 | 259 | 257 |
| អត្រាកំនើននៃ ផសស ពិត (ថ្លៃថេរឆ្នាំ១៩៩៣) | 7.1 | 4.0 | 6.7 | 8.0 | 0.6 | 1.7 | 6.6 | 4.0 |
| កសិកម្ម | 5.5 | 5.2 | 10.3 | 2.0 | 2.8 | 0.9 | 1.3 | -2.7 |
| ឧស្សាហកម្ម | 12.7 | 4.8 | 9.0 | 19.3 | 0.4 | 14.0 | 8.9 | 12.7 |
| សេវាកម្ម | 6.9 | 2.6 | 2.4 | 10.5 | -1.5 | -2.1 | 11.0 | 6.6 |
| អតិផរណានៅត្រីមាសទី៤ (ជារៀល) | 41.0 | 17.8 | 3.5 | 9.0 | 9.1 | 12.6 | 0.0 | 0.5 |
| អត្រាប្តូរប្រាក់ រៀល/ដុល្លារ (មធ្យមភាគប្រចាំឆ្នាំ) | 2,814 | 2,569 | 2,462 | 2,641 | 3,000 | 3,800 | 3,820 | 3,860 |
| ចំនូលថវិកា (ភាគរយនៃ ផសស) | 4.8 | 9.5 | 8.9 | 9.0 | 9.6 | 8.9 | 11.3 | 11.8 |
| ចំនាយថវិកា (ភាគរយនៃ ផសស) | 10.0 | 16.2 | 16.7 | 17.3 | 13.8 | 14.7 | 16.6 | 17.5 |
| ឱនភាពថវិកាចរន្ត (ភាគរយនៃ ផសស) | -1.4 | -1.4 | -0.8 | -1.2 | 0.7 | -0.2 | 1.6 | 1.6 |
| ឱនភាពថវិកាទូទៅ (ភាគរយនៃ ផសស) | -5.2 | -6.7 | -7.7 | -8.3 | -4.1 | -5.8 | -5.3 | -5.6 |
| ទំនិញក្នុងស្រុកនាំចេញ (ភាគរយនៃ ផសស) | 7.4 | 10.6 | 10.8 | 11.4 | 17.9 | 21.8 | 24.8 | 36.4 |
| ទំនិញនាំចូលសំរាប់ប្រើប្រាស់ (ភាគរយនៃ ផសស) | 16.9 | 22.6 | 24.4 | 29.3 | 31.8 | 41.4 | 41.2 | 48.3 |
| ជញ្ជីងពាណិជ្ជកម្ម (ភាគរយនៃ ផសស) | -9.5 | -11.9 | -13.6 | -17.8 | -13.9 | -19.6 | -16.4 | -11.9 |
| តុល្យភាពគណនីចរន្ត (ភាគរយនៃ ផសស) | -5.2 | -10.6 | -14.0 | -16.8 | -12.1 | -17.8 | -13.6 | -8.7 |
| ការរួមចំនែកបរទេសដល់សេដ្ឋកិច្ច (ភាគរយនៃ ផសស) | 14.5 | 16.9 | 21.0 | 21.2 | 14.5 | 18.3 | 16.4 | 14.9 |
| សញ្ជ័យសរុប (ភាគរយនៃផសស) | 18.9 | 19.2 | 22.1 | 27.6 | 22.3 | 26.3 | 23.6 | 19.6 |
| ធនបំរុងបរទេសសរុប (ចំនួនខែនៃទំនិញនាំចូល) | 1.5 | 1.4 | 1.7 | 2.0 | 2.3 | 3.1 | 3.1 | 3.1 |
| ចំនួនប្រជាជន (ជាលាននាក់) | 9.6 | 9.9 | 10.3 | 10.7 | 11.1 | 11.4 | 11.8 | 12.1 |
| កំលាំងពលកម្ម (ភាគរយនៃចំនួនប្រជាជន) | 48.0 | 47.3 | 46.6 | 45.9 | 45.3 | 44.8 | 44.7 | 44.6 |

*ប្រភព: ទិន្នន័យរបស់រដ្ឋាភិបាល និងការព្យាករណ៍របស់ វិបសអ ។*

## តារាង២. គោលដៅនៃផលិតផលសំលៀកបំពាក់នាំចេញ ពីឆ្នាំ១៩៩៤-២០០១ (មធ្យមភាគប្រចាំត្រីមាស)

| | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | | | | 2001 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| សហរដ្ឋអាមេរិក | 0.0 | 0.02 | 0.1 | 26.8 | 74.1 | 121.5 | 154.0 | 187.7 | 220.4 | 187.9 | 189.3 | 192.9 |
| ប្រទេសឯទៀត | 1.0 | 6.6 | 19.6 | 30.0 | 20.5 | 17.0 | 41.3 | 37.6 | 78.8 | 77.3 | 62.8 | 68.8 |
| សរុប | 1.0 | 6.6 | 19.7 | 56.8 | 94.5 | 138.5 | 195.3 | 225.3 | 299.2 | 265.2 | 252.1 | 261.7 |
| | បំរែបំរួលភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | – | 560 | 200 | 187 | 66 | 47 | 47 | 64 | 98 | 100 | 29 | 16 |

*ប្រភព: នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, ក្រសួងពាណិជ្ជកម្ម ។*

## តារាង៣. ចំនួនអ្នកដំណើរតាមជើងហោះហើរអន្តរជាតិមកដល់ព្រលានយន្តហោះពោធិចិនតុង និងសៀមរាប ពីឆ្នាំ ១៩៩៤-២០០១

| | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | | | | 2001 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | អ្នកដំណើរគិតជាពាន់នាក់ | | | | | | | | | | | |
| ទិដ្ឋាការអ្នកទេសចរ | 27.9 | 38.7 | 55.3 | 46.3 | 38.1 | 44.9 | 64.7 | 55.8 | 56.0 | 66.6 | 64.6 | 53.2 |
| ទិដ្ឋាការអ្នកជំនួញ | 7.1 | 10.6 | 15.8 | 13.9 | 10.7 | 16.0 | 13.7 | 13.0 | 12.7 | 14.7 | 20.0 | 23.2 |
| ទិដ្ឋាការផ្លូវការរដ្ឋ | 3.3 | 3.9 | 3.2 | 3.6 | 4.4 | 8.8 | 3.4 | 3.5 | 4.3 | 5.0 | 3.8 | 4.7 |
| សរុប នៅពោធិចិនតុង | 38.3 | 53.2 | 74.3 | 63.8 | 53.2 | 69.7 | 81.7 | 72.3 | 73.0 | 86.3 | 88.4 | 81.1 |
| សរុប នៅសៀមរាប | - | - | - | - | 2.6 | 7.15 | 19.9 | 14.8 | 20.1 | 32.2 | 41.9 | 23.6 |
| | ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប នៅពោធិចិនតុង | 29.7 | 38.9 | 39.7 | -14.1 | -16.6 | 31.0 | 21.2 | 13.3 | 6.5 | 9.1 | 8.2 | 12.2 |
| សរុប នៅសៀមរាប | - | - | - | - | - | 175 | 342 | 202 | 183 | 166 | 111 | 59 |

*ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍ ។*

# តាមដានសេដ្ឋកិច្ច — សន្ទស្សន៍សេដ្ឋកិច្ច

## តារាង៤. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI), អត្រាប្ដូរប្រាក់, និង ថ្លៃមាស, ពីឆ្នាំ១៩៩៤-២០០១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | | | | 2001 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត | - | - | - | 6.1 | 16.3 | 6.2 | 0.6 | 4.0 | 6.5 | 10.4 | 4.8 | 1.3 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | -0.5 | 7.8 | 7.1 | 8.1 | 14.2 | 4.2 | 0.1 | -2.3 | -1.4 | 0.5 | -0.8 | 0.1 |
| - ម្ហូបអាហារ | -13.4 | 4.9 | 7.6 | 6.7 | 15.6 | 8 | -1.2 | -5.5 | -5.1 | -1.3 | -2.6 | -2.2 |
| - ថាមពល | -1.2 | 19.4 | 20.7 | 21.0 | 10.7 | 5.5 | 13.0 | 3.6 | 8.8 | 6.7 | 0.5 | 1.5 |
| | អត្រាប្ដូរប្រាក់, ថ្លៃមាស, ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 2,582 | 2,479 | 2,666 | 3,029 | 3824 | 3832 | 3,822 | 3,874 | 3,912 | 3,906 | 3,925 | 3,931 |
| រៀលក្នុង ១ បាត | 102 | 99 | 105 | 98 | 88 | 101 | 102 | 99 | 94 | 90.3 | 88.5 | 86.6 |
| រៀលក្នុង ១០០ ដុង | 23.5 | 22.3 | 24.0 | 25.6 | 28.6 | 27.8 | 27.4 | 27.3 | 27.5 | 27.3 | 26.9 | 26.8 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 45.8 | 45.9 | 46.3 | 40.4 | 36.0 | 34.0 | 32.8 | 33.8 | 34.0 | 32.6 | 32.0 | 32.0 |
| ថ្លៃប្រេងម៉ាស៊ូត (រៀល/លីត្រ) | 750 | 716 | 779 | 883 | 1,065 | 1,105 | 1,223 | 1,256 | 1,353 | 1,483 | 1,483 | 1,533 |
| ថ្លៃសាំង (រៀល/លីត្រ) | 698 | 847 | 1,118 | 1,378 | 1,613 | 1,760 | 1,975 | 2,043 | 2,200 | 2,233 | 2,100 | 2,100 |

*ប្រភព: វបសអ, IMF, NIS, ក្រសួងផែនការ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## តារាង៥. ចំណូលប្រចាំថ្ងៃជាមធ្យមរបស់ពលករ ពីឆ្នាំ១៩៩៧ -២០០១

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1997 | 1999 | 2000 | | | | 2001 | | | 2001 | 2001 | 2001 |
| | Pre-Jul | Nov | Feb | May | Aug | Nov | Feb | May | Aug | Feb | May | Aug |
| អ្នកធាក់ស៊ីក្លូ | 12,250 | 8,226 | 9,682 | 9,691 | 9,511 | 8,398 | 8,200 | 9,568 | 9,057 | -15.3 | -1.3 | -4.8 |
| អ្នកលីសែង | 9,675 | 6,143 | 8,275 | 8,002 | 8,068 | 6,893 | 7,300 | 7,058 | 7,189 | -11.8 | -11.8 | -10.9 |
| អ្នកលក់ដូរតូចតាច | 7,050 | 9,071 | 7,864 | 7,267 | 6,611 | 5,813 | 6,400 | 7,386 | 6,670 | -18.6 | 1.6 | 0.9 |
| អ្នករើសសំរាម | 4,155 | 2,600 | 4,750 | 4,969 | 4,186 | 3,006 | 3,900 | 2,670 | 2,686 | -17.9 | -46.3 | -35.8 |
| អ្នកបំរើតាមហាង* | – | – | 1,873 | 2,030 | 2,250 | 2,335 | 2,600 | 2,600 | 2,683 | 38.8 | 28.1 | 19.2 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | – | – | 3,600 | 4,000 | 4,443 | 4,184 | 4,100 | 3,613 | 4,500 | 13.9 | -9.7 | 1.3 |
| កម្មកររោងចក្រកាត់ដេរ | – | – | 7,283 | 8,272 | 8,500 | 7,410 | 8,300 | 7,500 | 9,165 | 14.0 | -9.3 | 7.8 |
| អ្នករត់ម៉ូតូឌុប | – | – | 9,200 | 12,100 | 11,044 | 9,522 | 10,000 | 12,050 | 10,559 | 8.7 | -0.4 | -4.4 |
| កម្មករសំណង់គ្មានជំនាញ | – | – | 9,193 | 6,900 | 8,220 | 5,970 | 7,500 | 8,261 | 5,625 | -18.4 | 19.7 | -31.6 |
| កម្មករសំណង់មានជំនាញ | – | – | 15,873 | 15,600 | 14,891 | 14,517 | 11,200 | 10,306 | 12,375 | -29.4 | -33.9 | -16.9 |

*សំគាល់: អង្កេតលើចំណូលរបស់ អ្នកបំរើតាមហាង, អ្នកស៊ីឈ្នួលធ្វើស្រែ, កម្មករកាត់ដេរ, អ្នករត់ម៉ូតូឌុប, និងកម្មករសំណង់មានជំនាញ និងគ្មានជំនាញ, ចាប់ផ្ដើមធ្វើនៅខែកុម្ភៈ ២០០០ ។*
** ចំណូលអ្នកបំរើតាមហាងមិនរាបានគិតបញ្ចូលទេនូវ អាហារ និងការស្នាក់នៅដែលម្ចាស់ហាងផ្ដល់ឱ្យ ។ ប្រភព: វបសអ ។*

## តារាង៦. ស្ថានភាពរូបិយវត្ថុ ពីឆ្នាំ១៩៩៤-២០០១ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | | | | 2001 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | គិតជាពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 391 | 550 | 881 | 1,172 | 1,550 | 1,961 | 2,373 | 2,510 | 2,448 | 2,589 | 2,733 | 2,807 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 59 | 99 | 31 | -109 | -435 | -591 | -640 | -679 | -656 | -759 | -834 | -821 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 143 | 148 | 128 | 54 | 141 | 111 | 94 | 41 | 6 | 3 | -69 | -82 |
| ឥណទានចំពោះផ្នែកឯកជន | 237 | 293 | 435 | 637 | 682 | 731 | 779 | 860 | 932 | 898 | 905 | 947 |
| រូបិយវត្ថុទូទៅ M2 | 450 | 650 | 912 | 1,063 | 1,116 | 1,370 | 1,733 | 1,831 | 1,792 | 1,831 | 1,899 | 1,985 |
| រូបិយវត្ថុ M1 | 200 | 279 | 329 | 385 | 466 | 515 | 550 | 546 | 540 | 540 | 548 | 544 |
| រូបិយវត្ថុផ្សេងៗ | 250 | 371 | 583 | 678 | 655 | 855 | 1,183 | 1,286 | 1,252 | 1,291 | 1,351 | 1,441 |
| | ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 35.1 | 44.3 | 40.3 | 16.6 | 4.9 | 22.7 | 31.8 | 39.1 | 27.4 | 26.8 | 9.6 | 8.4 |
| រូបិយវត្ថុ M1 | -1.9 | 39.5 | 17.9 | 17 | 21 | 10.5 | 4.4 | 9.2 | 7.8 | 1.5 | -0.4 | -0.4 |
| រូបិយវត្ថុផ្សេងៗ | 93.2 | 48.1 | 57.2 | 16.4 | -3.4 | 30.5 | 50.1 | 53.4 | 38.5 | 41.7 | 14.2 | 12.1 |

*ប្រភព: ធនាគារជាតិនៃកម្ពុជា ។ មធ្យមភាគប្រចាំត្រីមាស ។*

# តាមដានសេដ្ឋកិច្ច — សន្ទស្សន៍សេដ្ឋកិច្ច

**តារាង៧. ប្រតិបត្តិការថវិកាជាតិ ពីឆ្នាំ១៩៩៤-២០០១ (គិតជាពាន់លានរៀល)**

| | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | | | | 2001 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ចំណូលសរុប | 148 | 161 | 187 | 220 | 230 | 329 | 332 | 378 | 336 | 377 | 366 | 400 |
| ចំណូលពន្ធ | 91 | 111 | 134 | 149 | 169 | 239 | 244 | 281 | 246 | 268 | 263 | 291 |
| ពន្ធគយ | 70 | 80 | 86 | 87 | 94 | 108 | 98 | 106 | 83 | 104 | 98 | 105 |
| ចំណូលមិនមែនពន្ធ | 56 | 47 | 44 | 68 | 51 | 87 | 88 | 97 | 84 | 85 | 100 | 107 |
| អាជីវកម្មព្រៃឈើ | 22 | 13 | 7 | 9 | 5 | 9 | 11 | 11 | 7 | 13 | 10 | 9 |
| ប្រៃសណីយ៍ និង ទូរគមនាគមន៍ | 15 | 14 | 16 | 21 | 22 | 27 | 20 | 34 | 14 | 25 | 23 | 28 |
| ចំណូលជាមូលធន | 0 | 2 | 10 | 3 | 9 | 3 | 0 | 0 | 6 | 23 | 3 | 2 |
| ចំណាយសរុប | 252 | 300 | 360 | 315 | 324 | 448 | 353 | 483 | 514 | 653 | 453 | 517 |
| ចំណាយជាមូលធន | 84 | 128 | 157 | 113 | 92 | 156 | 167 | 209 | 280 | 223 | 198 | 210 |
| ចំណាយចរន្ត | 168 | 172 | 203 | 202 | 245 | 291 | 243 | 274 | 234 | 430 | 255 | 307 |
| អប់រំ និងសុខាភិបាល | 23 | 25 | 31 | 32 | 33 | 70 | 32 | 35 | 32 | 150 | 27 | 47 |
| ការពារជាតិ និងសន្តិសុខ | 98 | 106 | 102 | 105 | 110 | 116 | 86 | 118 | 74 | 164 | 63 | 88 |
| ក្រសួងផ្សេងៗ | 48 | 41 | 71 | 65 | 83 | 103 | 125 | 122 | 128 | 116 | 165 | 172 |
| ឱនភាពជាទូទៅ | -105 | -139 | -173 | -95 | -95 | -119 | -78 | -105 | -178 | -276 | -87 | -117 |
| ហិរញ្ញប្បទានក្រៅប្រទេស | 108 | 140 | 170 | 111 | 67 | 104 | 122 | 168 | 212 | 164 | 165 | 160 |
| ហិរញ្ញប្បទានក្នុងស្រុក | -3 | -1 | 3 | -16 | 31 | 1 | -44 | -63 | -34 | 112 | -78 | -43 |

*ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មធ្យមភាគប្រចាំត្រីមាស ។*

**តារាង៨. គំរោងវិនិយោគដែលបានអនុម័ត ពីឆ្នាំ១៩៩៤-២០០១ ***

| | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | | | | 2001 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ចំនួនគំរោងវិនិយោគ | | | | | | | | | | | |
| សរុប | 46 | 51 | 75 | 34 | 35 | 24 | 22 | 27 | 29 | 13 | 11 | 13 |
| កាត់ដេរ | 27 | 30 | 36 | 12 | 21 | 11 | 13 | 17 | 13 | 7 | 4 | 7 |
| | មូលធនដែលបានចុះបញ្ជី (គិតជាលានដុល្លារ) | | | | | | | | | | | |
| សរុប | 116.0 | 89.0 | 97.8 | 69.5 | 104.1 | 61.7 | 14.5 | 19.7 | 42.7 | 24.5 | 5.1 | 15.2 |
| កាត់ដេរ | 26.8 | 28.0 | 39.2 | 8.6 | 22.9 | 13.9 | 6.5 | 7.0 | 8.2 | 4.0 | 1.0 | 6.0 |
| | ទ្រព្យសកម្មជាប់លាប់ (គិតជាលានដុល្លារ) | | | | | | | | | | | |
| សរុប | 303.0 | 76.2 | 186.7 | 190.4 | 212.3 | 118.5 | 28.4 | 85.8 | 86.6 | 56.0 | 10.1 | 29.1 |
| កាត់ដេរ | 25.1 | 25.4 | 39.6 | 9.7 | 30.2 | 19.9 | 23.5 | 28.3 | 17.3 | 7.5 | 5.7 | 8.2 |

*ប្រភព: ក្រុមប្រឹក្សាវិនិយោគកម្ពុជា ។ មធ្យមភាគប្រចាំត្រីមាស ។ * ក្នុងនេះមានទាំងគំរោងពង្រីកគំរោងវិនិយោគដែលមានស្រាប់ ។*

*តពីទំព័រទី ២៤*

## ព័ត៌មានថ្មីៗពី វបសអ

### បណ្ណាល័យ

បណ្ណាល័យ វបសអ មានឯកសារ ៦៦១៥ចំណងជើង ដែលភាគច្រើនស្ដីពី សេដ្ឋកិច្ច និងអភិវឌ្ឍន៍សង្គម និងមានភ្ញៀវមកប្រើប្រាស់សេវាបណ្ណាល័យ ២៧១0នាក់ ក្នុងរយៈពេលពីខែកក្កដា ដល់ កញ្ញា ។ ភ្ញៀវភាគច្រើន ជា និស្សិតសាកលវិទ្យាល័យ និងអ្នកស្រាវជ្រាវអន្តរជាតិ ។ ប្រជុំសៀវភៅស្ដីពីកម្ពុជា មានប្រយោជន៍ខ្លាំងណាស់ ចំពោះអ្នកប្រើប្រាស់ ។ កញ្ញា សុខ សិទ្ធា អតីតអ្នកស្ម័គ្រចិត្ត បានចូលបំរើការជាបណ្ណារក្សនៅ វបសអ ក្នុងខែសីហា ។

### ផ្នែកបោះពុម្ពផ្សាយ

ឯកសារចេញផ្សាយថ្មីៗមានជាអាទិ *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ១៧) ជាភាសាខ្មែរ និង *ទីផ្សារពលកម្មកម្ពុជា: ការកាត់បន្ថយភាពក្រីក្រកំណើន និងការកែតំរូវតាមវិបត្តិ (ឯកសារពិភាក្សាលេខ១៨), របាយការណ៍ប្រចាំឆ្នាំស្ដីពីសេដ្ឋកិច្ចកម្ពុជា-២០០១* និង *របាយការណ៍ប្រចាំឆ្នាំ២000 នៃ វបសអ* ជាភាសាអង់គ្លេស ។ លោក អែម សូវ៉ានី បានបញ្ចប់ការសិក្សាក៏រិតបរិញ្ញាប័ត្រខាងគ្រប់គ្រងអាជីវកម្មឧបត្ថម្ភដោយ វបសអ ។ ក្នុងខែសីហា លោកស្រី Ann Bishop អ្នកសំរបសំរួលផ្នែកបោះពុម្ពផ្សាយបានចប់ការងារពី វបសអ ។

### សន្ទានុក្រម

## វាក្យសព្ទសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍

**នយោបាយរូបិយវត្ថុ** (monetary policy)

នយោបាយអនុវត្តដោយរដ្ឋាភិបាល ដើម្បីជំរុញសេដ្ឋកិច្ច ឬធ្វើឱ្យសេដ្ឋកិច្ចមានស្ថិរភាពដោយប្រើប្រាស់នូវឧបករណ៍ផ្សេងៗដូចជាការផ្គត់ផ្គង់សាច់ប្រាក់ និងការកំណត់ការប្រាក់ជាដើម ។

**អ្នកជាប់ពាក់ព័ន្ធ** (stakeholders)

អ្នកមានផលប្រយោជន៍នៅក្នុង អាជីវកម្ម ទ្រព្យសម្បត្តិ ឬសេដ្ឋពាណិជ្ជកម្មផ្សេងៗ ដែលតាមធម្មតាតែង មានផ្ដល់អត្ថប្រយោជន៍ជាប្រាក់កាស ។

**ការខ្ចីបុល** (borrowings)

ទឹកប្រាក់ទាំងឡាយដែលរដ្ឋាភិបាលបានទទួលជាបណ្ដោះអាសន្នអំពីប្រជាជនជាទូទៅ ឬពីអ្នកឱ្យខ្ចីជាបរទេស ដោយមានការសន្យាបង្វិលសងវិញ ។ តាមធម្មតាអ្នកសុំខ្ចីបានទទួលប្រាក់នេះ នៅពេលខ្លួនបានធ្វើលិខិតសន្យាសងប្រាក់ប្រគល់ទៅឱ្យម្ចាស់បំណុល ។

**សម្បទានដី** (land concession)

ការផ្ដល់ឱ្យ (ពិសេសដោយរដ្ឋាភិបាល ឬអង្គភាពផ្សេងរបស់រដ្ឋាភិបាល) នូវសិទ្ធិប្រើប្រាស់ដីក្នុងគោលដៅជាក់លាក់ណាមួយសំរាប់រយៈពេលមួយមានកំណត់និងស្របតាមលក្ខខណ្ឌមួយដែលបានព្រមព្រៀងគ្នាជាមុន ។

**ភាពទៅវិញទៅមក** (reciprocity)

កិរិយាបទរវាងបុគ្គល ឬក្រុមដែលក្នុងនោះ ភាគីនិមួយៗផ្ដល់ឱ្យភាគីម្ខាងទៀតនូវពលកម្ម, សំភារៈ, ទំនិញ, ឬបំណងល្អអ្វីមួយ ។

**ការកាន់កាប់ដី** (land tenure)

ស្ថានភាព បែបបទ ឬ ប័ណ្ណ ដែលបញ្ជាក់សិទ្ធិ ហើយដែលតាមនេះដីត្រូវបានកាន់កាប់ដោយម្ចាស់មួយនាក់ ឬច្រើននាក់ ។

**បន្ទាត់ក្រីក្រ** (poverty line)

កំរិតប្រាក់ចំណូលមួយ ដែលធម្មតានៅក្រោមកំរិតនេះ ប្រជាជនមិនអាចមានស្បៀងគ្រប់គ្រាន់សំរាប់បំពេញតំរូវការក្នុងការទ្រទ្រង់រូបរាងកាយបានទេ ។និយមន័យនេះភាគច្រើនត្រូវបានប្រើប្រាស់នៅក្នុងប្រទេសក្រីក្រ ។

**វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ** (informal sector)

វិស័យមួយនៃសេដ្ឋកិច្ចដែលតាមធម្មតានៅក្នុងនោះ បទប្បញ្ញត្តិច្បាប់ផ្សេងៗសំរាប់គ្រប់គ្រងប្រាក់កំរៃ (ឬប្រាក់ចំណូល) ពេលម៉ោងធ្វើការ, ឬលក្ខខណ្ឌធ្វើការងារ, ឬមួយគ្មានសោះ ឬមួយមិនត្រូវបានដាក់បង្ខំឱ្យអនុវត្ត ។

**អត្រាកំណើននិន្នាការ** (trend growth rate)

អត្រាកំណើន (តាមធម្មតារបស់កត្តាអថេរណាមួយដែលគេរំពឹងថា ត្រូវប្រែប្រួលទៅតាមពេលវេលា ដូចជា ចំណូលជាតិជាដើម) ដែលគណនាឡើងតាមការប៉ាន់ស្មានស្ថិតិនៃ exponential curve និងដោយប្រើកំរងទិន្នន័យតាមពេលវេលា ។

**ជាតិពន្ធុវិទ្យា** (ethnography)

ជាផ្នែកមួយមនុស្សសាស្ត្រ ដែលសិក្សាពីភាពផ្សេងៗគ្នានៃវប្បធមិ


## Cambodia Development Review – 2001 Subscription Rates

**Domestic Subscription (Individual)**

❐ English edition ($14) ❐ Khmer edition (5,000r) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed ..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❐ English edition ($60 for five copies) ❐ Khmer edition (20,000r for five copies) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges). Total payment enclosed ..........

**International Subscription (Individual)**

❐ Thailand, Laos, Vietnam ❐ English edition ($25)* ❐ Khmer edition ($15)*
❐ Asia and Europe ❐ English edition ($30)* ❐ Khmer edition ($20)*
❐ Americas and Africa ❐ English edition ($35)* ❐ Khmer edition ($25)*

* Subscription includes postage. Payment by ❐ cash (in Phnom Penh) or ❐ cheque (please add $20 to cover bank charges for processing US dollar cheques). At present CDRI can accept payment from overseas only by US-dollar denominated cheque or bankers draft. Total payment enclosed ..........

Title: ❐ Mr ❐ Ms ❐ Dr ❐ Other ..........
First name: .......... Last name:.......... Position: ..........
Organisation / Company: ..........
Address (CCC Box if applicable): ..........
City / Province: .......... Country: ..........
Telephone: .......... Fax: ..........
e-mail: .......... ❐ Tick to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Please make cheques payable to the Cambodia Development Resource Institute. Do not send cash through the post. Please inform the Publications Section at CDRI if your contact details change.

# ព័ត៌មានថ្មីៗពី វបសអ

## ផ្នែកគ្រប់គ្រង និងអភិវឌ្ឍន៍ស្ថាប័ន

នៅខែមិថុនា និង កក្កដា ឆ្នាំ២០០១ នាយករងរបស់វិទ្យាស្ថានបានទៅចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលមួយនៅ Georgetown University, Wahington, D.C. ។ វបសអ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយអង្គការ DIENSTE IN UBERSEE ដើម្បីទទួលយកបណ្ឌិត កង ច័ន្ទតារ៉ាវុត្ថ ដែលត្រឡប់មកពីប្រទេសអាល្លឺមង់វិញ ឱ្យចូលធ្វើការនៅក្នុងក្រុមស្រាវជ្រាវរបស់ វបសអ ។ ដូចគ្នាដែរ កញ្ញា ជឹម ចរិយា និងលោក គឹម សេតារា បានចូលធ្វើការក្នុងក្រុមស្រាវជ្រាវរបស់ វបសអ ក្នុងខែកក្កដា ។ ដោយសារមានអ្នកចំណូលថ្មី និងការពង្រីកផ្នែកផ្សេងៗទៀត, ការងារសាងសង់ដើម្បីពង្រីកកន្លែងធ្វើការក៏បានចាប់ផ្តើមឡើង ហើយរំពឹងថា នឹងត្រូវរួចរាល់នៅពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ២០០១ ។

## ផ្នែកស្រាវជ្រាវ

វបសអ បានបង្ហើយនូវការសិក្សាពីរដែលបានចុះកិច្ចសន្យាទទួលមកពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងដែលមានឈ្មោះថា *ការវាយតំលៃខាងសង្គមកិច្ចពីដីធ្លីនៅកម្ពុជា* និង *ការកាន់កាប់ដីធ្លីនៅកម្ពុជា-ការវិភាគលើទិន្នន័យចុងក្រោយ* ។ សព្វថ្ងៃកំពុងដំណើរការធ្វើការសិក្សាជាលក្ខណៈគុណភាពមួយ (qualitative study) ដើម្បីបំពេញអង្កេតជាលក្ខណៈបរិមាណ (quantitative surveys) ទាំងឡាយដែលបានធ្វើឡើងនៅក្នុងគំរោង *ដីធ្លី និង សន្តិសុខស្បៀង* ។ ក្នុងពេលជាមួយគ្នា ពង្រាងឯកសារ *របាយការណ៍អភិវឌ្ឍន៍ធនធានមនុស្សកម្ពុជា* ត្រូវបានដាក់ជូនក្រសួងផែនការពិនិត្យ និងផ្តល់យោបល់ មុននឹងចេញឯកសារសំរេច ។ សំណើមួយសំរាប់ដំណាក់កាលខាងមុខនៃការងារសហការអន្តរប្រទេសក្នុងក្របខ័ណ្ឌបណ្តាញវិភាគអភិវឌ្ឍន៍ DAN ក៏ត្រូវបានដាក់ស្នើឡើងហើយ ។ *របាយការណ៍ប្រចាំឆ្នាំស្តីពីសេដ្ឋកិច្ចកម្ពុជា* ដែលជាឯកសារដំបូងនៃកំរងឯកសារបោះពុម្ពផ្សាយថ្មីមួយ ហើយនិង*របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា* លេខ៨ ឆ្នាំ២០០១ ក៏បានចេញផ្សាយហើយដែរ ។

## មជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (CPD)

ពីខែកក្កដា ដល់ កញ្ញា ឆ្នាំ២០០១ ការប្រជុំខប់សែលដែលធ្វើប្រចាំខែនៅ វបសអ បានផ្តោតលើបញ្ហាបី ជាពិសេស ១-ជួយដល់ក្រសួងមហាផ្ទៃក្នុងការបង្កើតរចនាសម្ព័ន្ធមួយដើម្បីដោះស្រាយឱ្យបានស័ក្តិសិទ្ធនូវបញ្ហាសន្តិសុខនៅក្នុងដំណើរការបោះឆ្នោតឃុំ ២-ការចុះបញ្ជីអ្នកបោះឆ្នោត ៣-ជំនួយពីសហគមន៍អន្តរជាតិ ។ ក្នុងកិច្ចប្រជុំខប់សែលខែកក្កដា តំណាងរបស់សហភាពអឺរ៉ុបបានប្រកាសថា សហភាពអឺរ៉ុបនឹងផ្តល់ជំនួយហិរញ្ញវត្ថុសំរាប់ការបោះឆ្នោតឃុំនៅកម្ពុជា ។ នៅចុងខែសីហា កម្មវិធីបណ្តុះបណ្តាលនៅស្រុកត្រពាំងប្រាសាទ និងអន្លង់វែង (ខេត្តឧត្តរមានជ័យ) បានចប់សព្វគ្រប់ប្រកបដោយជោគជ័យ ។ សព្វថ្ងៃកំពុងរៀបចំវគ្គបណ្តុះបណ្តាលបន្ថែមសំរាប់ស្រុកអន្លង់វែងក្នុងខែតុលា និងត្រពាំងប្រាសាទក្នុងខែធ្នូ ។ CPD នឹងបើកវគ្គបណ្តុះបណ្តាលសំរាប់ស្ត្រីនៅក្នុងខែ វិច្ឆិកា និងដើមឆ្នាំក្រោយ ។ បច្ចុប្បន្ន CPD កំពុងរៀបចំធ្វើសិក្ខាសាលាពីរនៅចុងខែ កញ្ញា ស្តីពីតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយពត៌មាននៅក្នុងដំណើរការបោះឆ្នោត និងវិវាទពលកម្ម ។ ទស្សនកិច្ចសិក្សាទៅកាន់ប្រទេសអាហ្វ្រិកខាងត្បូងដែលគ្រោងធ្វើនៅក្នុងខែ វិច្ឆិកា ក៏កំពុងតែរៀបចំដែរ ។ ក្នុងខែសីហា អ្នកសំរបសំរួលនៃ CPD បានទទួលការអញ្ជើញឱ្យទៅឧ

(តទៅទំព័រទី ២២...)

ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា ក៏មានផ្សាយជាភាសាអង់គ្លេសដែរ ។

***Cambodia Development Review*** **is also available in English.**

ឯកសារបោះពុម្ពផ្សាយរបស់ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា**

ឆ្នាំទី៥ លេខ២៤ ខែតុលា-ធ្នូ ឆ្នាំ២០០១

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

អាសយដ្ឋានប្រៃសណីយ: ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (៨៥៥-២៣) ៣៦៨-០៥៣, ៨៨០-៧៣៤, ៨៨៣-៦០៩ ទូរសារ: (៨៥៥-២៣) ៣៦៦-០៩៤

e-mail: cdri@camnet.com.kh / pubs@cdri.forum.org.kh

website: http://www.cdri.org.kh

***ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា*** បោះពុម្ពដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង/មួយឆ្នាំ ជាភាសាខ្មែរ និងអង់គ្លេសក្នុងពេលដំណាលគ្នា ។

***ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា*** ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ ***អត្ថបទតាមដានសេដ្ឋកិច្ច*** ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

***ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា*** ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិតត្រូវចុះហត្ថលេខា ប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹង ត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

គ្រឹះស្ថានផ្សាយ: វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

គ្រប់គ្រងកែសំរួល: Sarthi Acharya, កែសំរួល: អែម សូវ៉ានី / អ៊ុំ ចាន់ថា

អ្នកបកប្រែ: យូ សិទ្ធិរិទ្ធ, រូបភាពក្របមុខ: ហេង ស៊ីនិត

រោងពុម្ព: រោងពុម្ពជប៉ុន ភ្នំពេញ

**រក្សាសិទ្ធិ ២០០១** វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

**ISSN 1560-7615**

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។